សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Économiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការប្រៀបធៀបសិទ្ធិប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំចលនវត្ថុ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **ផេង គឹមហេង**
កញ្ញា **ឆា វិនជីង**

ណែនាំដោយ
លោកស្រី **សំណាង ផលដេត**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩
ឆ្នាំសរសេរសារណា ២០២៣

# **សេចក្ដីថ្លែងអំណរគុណ**

យើងខ្ញុំទាំងពីរនាក់ឈ្មោះ **ផេង គឹមហេង** និង **ឆា ចិនជីង** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី ២៣ នៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ក្នុងឆ្នាំសិក្សា២០១៩-២០២៣។ ក្នុងនាមយើងខ្ញុំ ជាយុវជនជំនាន់ក្រោយ ជាទំពាំងស្នងឬស្សី និងជាសសរទ្រូងនៃប្រទេសជាតិ ក្រោយពីបានចំណាយពេលវេលា និងកម្លាំងកាយចិត្ត យកចិត្តទុកដាក់ក្នុងការសិក្សាផ្នែកនីតិសាស្ត្រ អស់រយៈពេលប្រមាណ៤ ឆ្នាំកន្លងមកនេះ នៅក្នុងឆ្នាំបញ្ចប់នៃថ្នាក់បរិញ្ញាបត្ររបស់យើងខ្ញុំ យើងខ្ញុំសម្រេចចិត្តធ្វើការស្រាវជ្រាវ និងសរសេរជាសារណា នូវប្រធានបទស្តីពី **ប្រៀបធៀបសិទ្ធិប្រាតិភោគដោយអនុប្បទាន និងការបញ្ជាំចលនវត្ថុ** ដើម្បីជាទុកជា ទុនបន្ថែមសម្រាប់ការសិក្សាស្រាវជ្រាវដល់ប្អូនៗជំនាន់ក្រោយ ក្នុងស្មារតីបង្កជាលក្ខណៈងាយស្រួល សម្រួលដល់ការសិក្សា ដើម្បីឈានទៅរកការទទួលបាននូវចំណេះដឹងជាមូលដ្ឋានបន្ថែមទៀត ក្នុងទិសដៅទទួលបាននូវភាពជោគជ័យក្នុងការសិក្សា។

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំសូមសំដែងនូវគារវកិច្ចដឹងគុណដ៏ខ្ពង់ខ្ពស់ជាអនេកប្បការ និងយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ៖

| | |
|---|---|
| **លោកឳពុក ផេង ណារ៉េត** | **លោកឳពុក សុខ តុង** |
| **អ្នកម្ដាយ លី យក់លាង** | **អ្នកម្ដាយ លឹម សុកឃួរ** |

ជាទីគោរពដ៏ខ្ពង់ខ្ពស់ និងជាទីស្រលាញ់នៃកូន ដែលបានផ្ដល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅ ប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងផ្ដល់នូវក្ដីស្រលាញ់ចំពោះកូនតាំងពីថ្ងៃដែលកូនទើបតែឃើញពន្លឺថ្ងៃដំបូង រហូតមកដល់ពេលកូនធំពេញវ័យ ដោយលោកទាំងពីរ បានលះបង់ទាំងកម្លាំងកាយ កម្លាំងចិត្ត សតិ បញ្ញា និងស្មារតី ក្នុងគោលដៅស្វែងរកថវិកា ដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូនឱ្យបានធំធាត់ប្រកបដោយសុខភាពល្អ កាយសម្បទាមាំមួន និងផ្គត់ផ្គង់ឱ្យកូនបានសិក្សារៀនសូត្ររហូតមក។ គុណូបការៈ ព្រហ្មវិហារធម៌ និងទឹកចិត្តស្រលាញ់ របស់លោកអ្នកមានគុណទាំងពីរ សម្រាប់យើងខ្ញុំទាំងពីរនាក់ គឺពិតជាធំធេងជាងមហាសមុទ្រដែលគ្មានកោះត្រើយ ធំជាងចក្រវាឡ ដែលរកអ្វីមកប្រៀបផ្ទឹមពុំបានឡើយ។ ទង្វើល្អរបស់លោកអ្នកមានគុណទាំងទ្វេ ដែលបានធ្វើមកកាន់កូន កូនមិនអាចរកអ្វីមកតបស្នង និងកាត់កងបាននោះទេនៅក្នុងជាតិនេះ ហើយកូនបានរក្សាទុកនៅក្នុងចិត្ត បេះដូង និងខួរក្បាលរបស់កូនជានិច្ចដរាប។

ជាងនេះទៅទៀត យើងខ្ញុំសូមធ្វើការថ្លែងអំណរគុណដល់ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានខិតខំផ្ទេរនូវពុទ្ធិ និងចំណេះជំនាញ

បទពិសោធន៍ ឯកសារ ដល់យើងខ្ញុំទាំងពីរក្នុងការក្រេបយកនូវចំណេះដឹង ដែលជាទុនដ៏សំខាន់សម្រាប់ឈានទៅរកភាពជោគជ័យនៃការសិក្សា។

ជាពិសេស សូមធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ **លោកស្រី សំណាង ផលដេត** ដែលជាគ្រូណែនាំ យើងខ្ញុំទាំងពីរ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងកម្លាំងកាយចិត្ត នៅក្នុងការបង្ហាត់បង្ហាញ ណែនាំ ជ្រោមជ្រែង កែតម្រូវ និងផ្តល់នូវអនុសាសន៍ដ៏ល្អ សម្រាប់យើងខ្ញុំ ដែលការណ៍នេះ បានអនុញ្ញាតឱ្យការស្រាវជ្រាវរបស់យើងខ្ញុំទាំងពីរនាក់ ប្រព្រឹត្តទៅដោយមានភាពរលូន និងប្រកបដោយលទ្ធផលប្រសើរ ។

# អារម្ភកថា

រយៈកាល ៤ឆ្នាំដែលយើងខ្ញុំទាំងពីរនាក់ បានសិក្សាក្នុងថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ នៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ក្រោមការដឹកនាំបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ របស់លោកគ្រូ និងអ្នកគ្រូសាស្ត្រាចារ្យដែលប្រកបទៅដោយចំណេះ ជំនាញ និងបទពិសោធន៍ជ្រៅជ្រះ ទៅលើមុខវិជ្ជាគោលជាមូលដ្ឋានទាំងផ្នែកនីតិសាធារណៈ និងនីតិឯកជន រួចមក ទើបយើងខ្ញុំបានមានឱកាសនៅក្នុងការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រជំនាន់ទី ២៣ និងជាការចូលរួមចំណែកមួយផ្នែកនៅក្នុងការសម្រួលដល់ការសិក្សាស្រាវជ្រាវរបស់ប្អូនៗ និស្សិតជំនាន់ក្រោយ ប្រកបដោយភាពងាយស្រួល និងច្បាស់លាស់។ ជាងនេះទៀតសោត ការសរសេរសារណា គឺជាការសិក្សាស្រាវជ្រាវទៅលើប្រធានបទណាមួយប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងទាមទារឱ្យអ្នកសរសេរមានភាពស៊ីជម្រៅ ទៅលើប្រធានបទនោះដោយការសរសេរ និងចងក្រងនេះគឺមិនមានលក្ខណៈងាយស្រួលដូចជា ការធ្វើកិច្ចការស្រាវជ្រាវធម្មតា ឬលំហាត់កិច្ចការ នោះឡើយ ពោលគឺវាតម្រូវឱ្យយើងទាំងពីរនាក់ ត្រូវចំណាយពេលវេលា ភាពអត់ធ្មត់ ការផ្ដោតនិងការផ្ដង់អារម្មណ៍ គួបផ្សំនិងការខិតខំដោះស្រាយចំពោះបញ្ហាប្រឈមនានា ដែលកើតមានឡើងក្នុងអំឡុងពេលនៃការស្រាវជ្រាវ និងសរសេរចងក្រង។

យើងខ្ញុំទាំងពីរនាក់ បានធ្វើការជ្រើសរើសប្រធានបទ **ការប្រៀបធៀបសិទ្ធិប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំចលនវត្ថុ** ដើម្បីយកមកធ្វើការស្រាវជ្រាវ និងសរសេរជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ដោយយើងខ្ញុំទាំងពីរនាក់បានសម្លឹងឃើញថា នៅក្នុងប្រព័ន្ធច្បាប់នៃនីតិឯកជនកម្ពុជាបច្ចុប្បន្នបានបញ្ញត្តិបន្ថែមនូវវិធានគតិយុត្តថ្មីៗ ជាច្រើនក្នុងន័យសម្របសម្រួលទៅតាមតម្រូវការរបស់សង្គម ស្របទៅតាមសេដ្ឋកិច្ចទីផ្សារសេរីដែលកម្ពុជាប្រកាន់ភ្ជាប់ ក៏ប៉ុន្តែដោយហេតុថាវិធានគតិយុត្តនេះ នៅមានលក្ខណៈមួយថ្មីនៅឡើយសម្រាប់ប្រជាពលរដ្ឋកម្ពុជា ដែលនៅក្នុងនោះរួមទាំង សិទ្ធិប្រាតិភោគដោយអនុប្បទាន ផងដែរ។ ប្រជាពលរដ្ឋកម្ពុជា ភាគច្រើន និងស្ទើរតែទាំងអស់មានការស្គាល់ និងយល់ដឹងទៅលើការបញ្ចាំ ដែលជាវិធានគតិយុត្តចាស់ ដែលបានជ្រាបទៅក្នុងវណ្ណៈសង្គមកម្ពុជា អស់រយៈកាលដ៏យូរ ក៏ប៉ុន្តែចំពោះ សិទ្ធិប្រាតិភោគដោយអនុប្បទាន ក៏ជាវិធានមួយនៅក្នុងការយកទ្រព្យសម្បត្តិទៅធានាបំណុលផងដែរ ដែលជាមានលក្ខណៈស្រដៀងគ្នាទៅនឹង ការបញ្ចាំចលនវត្ថុជាខ្លាំង ក៏ប៉ុន្តែសញ្ញាណនៃប្រាតិភោគដោយអនុប្បទាននេះ ហាក់ដូចជាមិនទាន់មានភាពទូលំទូលាយដូចការបញ្ចាំ នៅក្នុងស្រទាប់សង្គមកម្ពុជា នៅឡើយទេ។ អាស្រ័យហេតុនេះ ដើម្បីជាឯកសារមូលដ្ឋានមួយ នៅក្នុងការបង្កលក្ខណៈងាយស្រួល និងសម្រួលដល់ការសិក្សាស្រាវជ្រាវស្វែងយល់បន្ថែម ក៏ដូចជាដើម្បីផ្សព្វផ្សាយអំពីវិធានគតិយុត្តនេះ ទើបយើងខ្ញុំឯកភាពគ្នានៅក្នុងការជ្រើសរើសប្រធានបទនេះមកធ្វើការសិក្សាស្រាវជ្រាវ

និងសរសេរជាសារណានេះឡើង។

ជាកិច្ចបញ្ចប់ យើងខ្ញុំទាំងពីរនាក់សង្ឃឹមយ៉ាងមុតមាំថា ស្នាដៃស្រាវជ្រាវដ៏តូចមួយនេះ នឹងក្លាយជាឯកសារដែលមានប្រយោជន៍សម្រាប់ការសិក្សាអំពី សិទ្ធិប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំចលនវត្ថុ និងជាមូលដ្ឋាននៅក្នុងការបែងចែកពីលក្ខណៈដូចគ្នា និងលក្ខណៈខុសគ្នារវាង សិទ្ធិប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំចលនវត្ថុ ប្រកបដោយភាពច្បាស់លាស់ ជាពិសេសអំពីគុណសម្បត្តិ និងគុណវិបត្តិនៃប្រព័ន្ធនីមួយៗ ស្របទៅតាមការកំណត់របស់ក្រមរដ្ឋប្បវេណី និងច្បាប់ពាក់ព័ន្ធជាធរមានផ្សេងទៀត។ ទន្ទឹមនឹងនេះ ការស្រាវជ្រាវ និងសរសេរចងក្រងនេះអាចនឹងមានការខ្វះចន្លោះដោយប្រការណាមួយ ដែលអាចនឹងត្រូវកែសម្រួលឡើងវិញនាពេលខាងមុខ ដើម្បីជាការបំពេញបន្ថែម។ អាស្រ័យហេតុនេះ យើងខ្ញុំសូមធ្វើការខន្តីអភ័យទោសទុកជាមុននូវរាល់កំហុសឆ្គងចំពោះការសរសេរតាក់តែងមួយនេះ ហើយយើងខ្ញុំក៏សូមធ្វើការស្វាគមន៍ចំពោះមតិរិះគន់ដើម្បីស្ថាបនាកែលម្អពីសំណាក់ស្ថាប័ន អ្នកសិក្សាស្រាវជ្រាវ និងគ្រប់មជ្ឈដ្ឋាន ដើម្បីជាបច្ច័យធ្វើឱ្យឯកសារស្រាវជ្រាវនេះ កាន់តែមានភាពល្អប្រសើរបន្ថែមទៀត។

# មាតិកា

ទំព័រ

## សេចក្តីផ្តើម

១. គោលបំណងនៃការស្រាវជ្រាវ ........ ១
២. មូលហេតុនៃការជ្រើសរើសប្រធានបទ ........ ១
៣. អត្ថប្រយោជន៍នៃប្រធានបទ ........ ១
៤. វិសាលភាពនៃស្រាវជ្រាវ ........ ២
៥. វិធីសាស្រ្តនៃការស្រាវជ្រាវ និងចងក្រង ........ ២
៦. រចនាសម្ព័ន្ធនៃស្រាវជ្រាវ ........ ២

## ជំពូកទី១

## ការបញ្ចាំចលនវត្ថុ

១.១. សញ្ញាណទូទៅនៃការបញ្ចាំចលនវត្ថុ ........ ៣
១.១.១. និយមន័យ ........ ៣
១.១.២. កម្មវត្ថុនៃការបញ្ចាំចលនវត្ថុ ........ ៣
១.១.៣. ផលប្រយោជន៍ប្រព័ន្ធការបញ្ចាំចលនវត្ថុ ........ ៤
១.១.៤. ភាគីនៃសិទ្ធិលើការបញ្ចាំ ........ ៤
១.៤.១.១. ម្ចាស់សិទ្ធិលើការបញ្ចាំ ........ ៤
ក. រូបវន្តបុគ្គល ........ ៤
ខ. នីតិបុគ្គល ........ ៤
១.៤.១.២. អ្នកបង្កើតសិទ្ធិលើការបញ្ចាំ ........ ៦
១.២. ការបង្កើតការបញ្ចាំចលនវត្ថុ ........ ៧
១.២.១. លក្ខខណ្ឌសុពលភាព ........ ៧
១.២.២. លក្ខខណ្ឌតតាំង ........ ៩
១.៣. អានុភាពនៃការបញ្ចាំចលនវត្ថុ ........ ១០
១.៣.១. ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ........ ១១
១.៣.២. អានុភាពចំពោះផល ........ ១១
១.៣.៣.ការប្រើប្រាស់ និងអាស្រ័យផលពីវត្ថុបញ្ចាំ ........ ១២

១.៣.៤. សិទ្ធិ និងករណីយកិច្ចរបស់ម្ចាស់សិទ្ធិ នៅក្នុងអំឡុងពេលដែលខ្លួនកំពុងកាន់កាប់វត្ថុបញ្ចាំ.....១២
១.៣.៥. ការបញ្ចាំបន្ត....................................................................................១៣
១.៣.៦. អានុភាពនៃការឃាត់ទុកវត្ថុបញ្ចាំ.................................................................១៥
១.៣.៧. លំដាប់នៃសិទ្ធិលើការបញ្ចាំ.......................................................................១៥
១.៣.៨. ការហាមឃាត់ការបញ្ចាំផ្ដាច់........................................................................១៦
១.៤.ការអនុវត្តសិទ្ធិលើការបញ្ចាំ.............................................................................១៧
១.៤.១. ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប............................................................១៧
១.៤.១.១. លក្ខខណ្ឌនៃការអនុវត្ត...........................................................................១៧
១.៤.១.១. នីតិវិធីនៃការអនុវត្ត.............................................................................១៨
១.៤.២. ការអនុវត្តសិទ្ធិលើការបញ្ចាំដោយការលក់ដោយបង្ខំ..................................................១៩
១.៤.២.១. ពាក្យសុំអនុវត្តសិទ្ធិលើការបញ្ចាំ...............................................................១៩
១.៤.២.២. ការលក់ឡាយឡុង និងការចែកចំណែក........................................................២០

## ជំពូកទី២

## សិទ្ធិប្រាតិភោគដោយអនុប្បទាន

២.១. សញ្ញាណទូទៅនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន.................................................២១
២.១.១. អត្ថន័យនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន.........................................................២១
២.១.២. កម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន..........................................................២១
២.១.៣. ផលប្រយោជន៍នៃប្រព័ន្ធសិទ្ធិប្រាតិភោគដោយអនុប្បទាន...........................................២២
២.១.៤. ភាគីនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន..............................................................២២
២.១.៤.១. ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន...........................................................២២
ក. រូបវន្តបុគ្គល.........................................................................................២២
ខ. នីតិបុគ្គល...........................................................................................២២
២.១.៤.២. អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន.....................................................២៤
២.២. ការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន........................................................២៥
២.២.១. លក្ខខណ្ឌសុពលភាព..............................................................................២៥
២.២.២. លក្ខខណ្ឌតតាំង...................................................................................២៥
២.៣. អានុភាព.....................................................................................................២៧

២.៣.១. ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា........................................................២៧
២.៣.២. អានុភាពចំពោះផល ........................................................................................២៧
២.៣.៣. ឧបាទេសកម្មលើវត្ថុ..........................................................................................២៩
២.៣.៣.១. ឧបាទេសកម្មលើចលនវត្ថុដែលមិនមែនជាចលនវត្ថុផ្គុំគ្នា ..................................២៩
២.៣.៣.២. ឧបាទេសកម្មលើវត្ថុដែលជាចលនវត្ថុផ្គុំគ្នា.....................................................៣០
២.៣.៤. ការចាត់ចែងវត្ថុដែលជាកម្មវត្ថុ ..........................................................................៣០
២.៣.៤.១. ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ......៣០
ក. ករណីចលនវត្ថុធម្មតា ...............................................................................៣០
ខ. ករណីចលនវត្ថុផ្គុំគ្នា ...................................................................................៣១
២.៣.៤.២. ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន............៣២
២.៣.៥. ទំហំដែលមានអានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ..........................................៣៣
២.៣.៦. បញ្ញត្តិពិសេសនៅក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ ..................................................................................................... ៣៣
២.៤. ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន..............................................................៣៤
២.៤.១. ការចាត់ចែងប្តូរជាប្រាក់.....................................................................................៣៤
២.៤.២. អនុប្បទានស្ថាពរ ............................................................................................៣៤
២.៤.៣. ករណីយកិច្ចបង់ទឹកប្រាក់ដែលលើស ......................................................................៣៥
២.៤.៤. សិទ្ធិទទួលយកមកវិញរបស់អ្នកបង្កើត ....................................................................៣៥

## ជំពូកទី៣

## ប្រៀបធៀបសិទ្ធិប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំចលនវត្ថុ

៣.១. លក្ខណៈដូចគ្នា និងខុសគ្នា នៃការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំចលនវត្ថុ ....៣៦
៣.១.១. លក្ខណៈដូចគ្នា និងខុសគ្នានៃលក្ខខណ្ឌសុពលភាព ...............................................៣៦
៣.១.១.១ លក្ខណៈដូចគ្នានៃលក្ខខណ្ឌសុពលភាព ...............................................................៣៦
៣.១.១.២. លក្ខណៈខុសគ្នានៃលក្ខខណ្ឌសុពលភាព..............................................................៣៦
៣.១.២. លក្ខណៈដូចគ្នា និងខុសគ្នានៃលក្ខខណ្ឌតតាំង ........................................................៣៧
៣.១.២.១. លក្ខណៈដូចគ្នានៃលក្ខខណ្ឌតតាំង .....................................................................៣៧
៣.១.២.២. លក្ខណៈខុសគ្នានៃលក្ខខណ្ឌតតាំង.....................................................................៣៧

៣.២. លក្ខណៈដូចគ្នាទាំងស្រុង រវាងអានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន និងការបញ្ជាំចលនវត្ថុ .៣៨
៣.២.១. កត្តាដែលនាំឱ្យមានអានុភាពដូចគ្នា ........................................................................៣៨
៣.២.២. បញ្ញត្តិស្តីពីអានុភាពដែលត្រូវយកមកអនុវត្តដូចគ្នា........................................................៣៨
៣.៣. លក្ខណៈដូចគ្នា និងខុសគ្នានៃអានុភាពសិទ្ធិប្រាតិភោគដោយអនុប្បទាន និងការបញ្ជាំចលនវត្ថុ .....៣៩
៣.៣.១. លក្ខណៈដូចគ្នា និងខុសគ្នាចំពោះផលនៃវត្ថុដែលជាកម្មវត្ថុ.............................................៤០
៣.៣.១.១. លក្ខណៈដូចគ្នាចំពោះផលនៃវត្ថុដែលជាកម្មវត្ថុ................................................៤០
៣.៣.១.២. លក្ខណៈខុសគ្នាចំពោះផលនៃវត្ថុដែលជាកម្មវត្ថុ ...............................................៤០
៣.៣.២. លក្ខណៈដូចគ្នា និងខុសគ្នាចំពោះការប្រើប្រាស់លើវត្ថុដែលជាកម្មវត្ថុ...............................៤១
៣.៣.២.១. លក្ខណៈដូចគ្នា ចំពោះការប្រើប្រាស់លើវត្ថុដែលជាកម្មវត្ថុ..................................៤១
៣.៣.២.២. លក្ខណៈខុសគ្នា ចំពោះការប្រើប្រាស់លើវត្ថុដែលជាកម្មវត្ថុ ................................៤១
៣.៤. លក្ខណៈដូចគ្នា និងខុសគ្នានៃការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន និងការបញ្ជាំចលនវត្ថុ .....៤១
៣.៤.១. លក្ខណៈដូចគ្នាចំពោះការអនុវត្ត ..................................................................................៤១
៣.៤.២. លក្ខណៈខុសគ្នាចំពោះការអនុវត្ត ..................................................................................៤២
**សេចក្តីសន្និដ្ឋាន**..........................................................................................................**៤៤**
**អនុសាសន៍**....................................................................................................................**៤៦**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. គោលបំណងនៃការស្រាវជ្រាវ

ក្រោយពីបានសិក្សារៀនសូត្រអស់រយៈពេល ៤ឆ្នាំ នៅមហាវិទ្យាល័យនីតិសាស្ត្រ នៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ក្រោមការបង្ហាត់បង្ហាញបង្រៀន យ៉ាងយកចិត្តទុកដាក់ពីសំណាក់លោកគ្រូ និងអ្នកគ្រូសាស្ត្រាចារ្យ នៅក្នុងឱកាសបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ និស្សិតអាចធ្វើការស្រាវជ្រាវ និងចងក្រងឡើងជាសារណា ដើម្បីការពារបញ្ចប់ថ្នាក់បរិញ្ញាបត្ររបស់ខ្លួន និងត្រូវការពារនៅចំពោះមុខគណៈកម្មការ។ នៅក្នុងឱកាសនៃការសរសេរសារណា ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ យើងខ្ញុំបានជ្រើសរើសនូវប្រធានបទស្តីអំពី **ការប្រៀបធៀបសិទ្ធិប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំចលនវត្ថុ** ដើម្បីធ្វើការស្រាវជ្រាវ និងចងក្រងឡើងជាសារណា ក្រោមការដឹកនាំ និងត្រួតពិនិត្យដោយសាស្ត្រាចារ្យណែនាំ។ ការជ្រើសរើសនូវប្រធានបទនេះ គឺធ្វើឡើងក្នុងគោលបំណងស្វែងយល់ជាលក្ខណៈទ្រឹស្តី និងការអនុវត្តជាក់ស្តែងចំពោះវិធានគតិយុត្តទាំងពីរនេះ និងធ្វើការបែងចែកឱ្យបានច្បាស់លាស់អំពីផលប្រយោជន៍នៃវិធាននីមួយៗ ដោយហេតុថាសិទ្ធិប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំចលនវត្ថុ គឺជាវិធានដែលមានកម្មវត្ថុជាការធានាសិទ្ធិលើបំណុលដូចគ្នា ហើយចំពោះវត្ថុ ដែលជាកម្មវត្ថុនៃការដាក់ធានានោះគឺ ចលនវត្ថុ ដូចគ្នាថែមទៀត ក៏ប៉ុន្តែផលប្រយោជន៍ម្ចាស់បំណុល ឬកូនបំណុល ឬតតិយជនដែលជាភាគីនៃវិធាននេះ គឺទទួលបានអត្ថប្រយោជន៍ផ្សេងៗពីគ្នា។ លើសពីនេះទៅទៀត ចំពោះសិទ្ធិ និងកាតព្វកិច្ចដែលកើតចេញពីវិធាននីមួយៗ ក៏មានលក្ខណៈប្លែកគ្នាដែរ ដែលផ្តល់នូវផលប្រយោជន៍សម្រាប់ភាគីនីមួយៗផ្សេងៗគ្នា។

## ២. មូលហេតុនៃការជ្រើសរើសប្រធានបទ

បន្ទាប់ពីបានជាប់ឈ្មោះជានិស្សិត ដែលត្រូវសរសេរសារណាដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ យើងខ្ញុំបានធ្វើការស្នើសុំយោបល់ពីសាស្ត្រាចារ្យណែនាំ ដើម្បីសរសេរនូវប្រធានបទណាមួយនៅក្នុងនីតិជាតិឯកជនដែលទាក់ទងនឹងសិទ្ធិប្រាតិភោគប្រត្យក្ស។ បន្ទាប់យើងខ្ញុំបានទទួលការណែនាំ និងយោបល់ផ្សេងៗ ពីសាស្ត្រាចារ្យរួចមក ដោយមើលឃើញពីភាពខ្វះចន្លោះ និងងាយនឹងមានការភាន់ច្រឡំរវាង សិទ្ធប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំចលនវត្ថុ រួមផ្សំជាមួយនឹងការមើលឃើញពីអត្ថប្រយោជន៍ពិសេសៗ ភាពស្មុគស្មាញនៃបទបញ្ញត្តិពាក់ព័ន្ធនៃវិធានទាំងពីរនេះ រួមជាមួយនឹងប្រតិបត្តិការនៃការអនុវត្តជាក់ស្តែងនៃសិទ្ធិប្រាតិភាគដែលមានកម្មវត្ថុជាចលនវត្ថុនេះ ទើបយើងខ្ញុំសម្រេចចិត្តធ្វើការស្រាវជ្រាវ និងចងក្រងនូវប្រធានបទនេះឡើង។

## ៣. អត្ថប្រយោជន៍នៃប្រធានបទ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទ **ការប្រៀបធៀបសិទ្ធិប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំចលនវត្ថុ** នេះ គឺពិតជាបានផ្តល់នូវអត្ថប្រយោជន៍ដល់យើងខ្ញុំ ដែលជានិស្សិតច្បាប់ និងនិស្សិតជំនាន់ក្រោយផងដែរ

ដែលអនុញ្ញាតឱ្យមានការស្វែងយល់បន្ថែមទៅលើទ្រឹស្តីគតិយុត្តដែលមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី និង បទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធ និងអាចធ្វើការបែងចែកកាន់តែមានភាពច្បាស់លាស់ទៅលើចំណុចរួមគ្នា និងចំណុចប្លែកគ្នានៃសិទ្ធិប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំចលនវត្ថុ។ ផ្សាភ្ជាប់ជាមួយគ្នានេះគឺអាច យល់ដឹងកាន់តែច្បាស់អំពីសិទ្ធិ និងករណីយកិច្ចរបស់ភាគីនីមួយៗ ដែលអនុញ្ញាតឱ្យយើងអាចយកសិទ្ធិ និង ករណីយកិច្ចនោះទៅប្រើប្រាស់ក្នុងទំនាក់ទំនងជាក់ស្តែង ក្រោមការការពារដោយច្បាប់។

## ៤. វិសាលភាពនៃការស្រាវជ្រាវ

សារណាដែលមានស្រាវជ្រាវ និងចងក្រងឡើងនេះ គឺមានកម្រិតត្រឹមតែបទបញ្ញត្តិដែលមានចែងនៅក្នុង ក្រមរដ្ឋប្បវេណី និងបទដ្ឋានគតិយុត្តនានាដែលចេញដោយអង្គការនីតិប្រតិបត្តិមួយចំនួនតែប៉ុណ្ណោះ ដោយមិនមាន លក្ខណៈលម្អិតខ្លាំង ដល់នីតិវិធីមួយចំនួនដែលទាក់ទងនឹងការស្នើសុំបើកអាជីវកម្ម កិច្ចដំណើរការនៃអាជីវកម្ម ឬទណ្ឌកម្មនានា រាប់ទាំងទណ្ឌកម្មព្រហ្មទណ្ឌ ដែលត្រូវអនុវត្តចំពោះម្ចាស់អាជីវកម្មដែលមិនអនុវត្តទៅតាម សេចក្តីណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ចនោះទេ។ ដោយឡែកនៅក្នុងទំនាក់ទំនងអាជីវកម្ម ឬក្រុមហ៊ុន ដែល អនុវត្តសកម្មភាពនៃការបញ្ចាំ ឬប្រាតិភោគដោយអនុប្បទាន ក៏យើងខ្ញុំមិនបានចុះកម្មសិក្សា និងប្រមូលទិន្នន័យ ដោយផ្ទាល់នោះដែរ ហេតុនេះសារណានេះមានវិសាលភាពត្រឹមការស្រាវជ្រាវជាលក្ខណៈឯកសារ និងការ ពិភាក្សាជាមួយអ្នកធ្លាប់មានបទពិសោធន៍ប៉ុណ្ណោះ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ និងចងក្រង

ការស្រាវជ្រាវលើប្រធានបទនេះគឺជួបប្រទះនូវការលំបាក និងស្មុគស្មាញមួយចំនួន ដោយហេតុថា ប្រធាន បទនេះ គឺជាវិធានគតិយុត្តដែលមានកម្មវត្ថុជាការធានាបំណុល ដែលទើបតែកំណត់ដោយក្រមរដ្ឋប្បវេណី ក្នុងឆ្នាំ ២០០៧ នេះតែប៉ុណ្ណោះ ហើយពុំសូវមានឯកសារដែលពាក់ព័ន្ធទូលំទូលាយនោះទេ ហេតុដូច្នេះយើងខ្ញុំបានធ្វើ ការស្រាវជ្រាវ និងប្រមូលទិន្នន័យព័ត៌មាន ពីទ្រឹស្តីតាមរយៈបទដ្ឋានគតិយុត្តជាធរមាន ដែលមានជាអាទិ៍ដូចជា ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសរបស់ក្រសួងពាក់ព័ន្ធ សារាចរ សេចក្តីណែនាំ សៀវភៅមេរៀន ផ្សេងៗ និងឯកសារដែលពាក់ព័ន្ធមួយចំនួនផ្សេងទៀត។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះត្រូវបានបែងចែកចេញជាបីជំពូកធំៗ ស្របតាមការណែនាំរបស់សាស្ត្រាចារ្យដឹកនាំការសរសេរ ដែលរួមមានដូចជា៖

-ជំពូកទី១ ការបញ្ចាំចលនវត្ថុ

-ជំពូកទី២ សិទ្ធិប្រាតិភោគដោយអនុប្បទាន

-ជំពូកទី៣ ការប្រៀបធៀបសិទ្ធិប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំចលនវត្ថុ

# ជំពូកទី១
# សិទ្ធិលើការបញ្ជាំចលនវត្ថុ

# ជំពូកទី១

# ការបញ្ចាំចលនវត្ថុ

## ១.១. សញ្ញាណទូទៅនៃការបញ្ចាំចលនវត្ថុ

### ១.១.១. និយមន័យ

សិទ្ធិលើការបញ្ចាំ សំដៅទៅលើសិទ្ធិប្រាតិភោគប្រត្យក្សមួយ ដែលម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិកាន់កាប់វត្ថុដែលបានទទួលពីកូនបំណុល ឬតតិយជនដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន និងទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនពីវត្ថុនោះ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត[1]។

ចលនវត្ថុ សំដៅទៅលើវត្ថុក្រៅពីអចលនវត្ថុ[2]។ មានន័យថា ជាវត្ថុដែលអាចរំកិលបាន ឬផ្លាស់ប្តូរទីតាំងបាន ដូចជារបស់របរផ្ទាល់ខ្លួន ឬចលនវត្ថុដែលជាកម្មវត្ថុនៃកម្មសិទ្ធិ ហើយមិនត្រូវបានគេចាត់ជាប្រភេទអចលនវត្ថុ[3]។

ជារួមមកយើងអាចកំណត់នូវនិយមន័យនៃការបញ្ចាំចលនវត្ថុបានថា គឺជាសិទ្ធិប្រាតិភោគប្រត្យក្សមួយ ដែលម្ចាស់សិទ្ធិលើការបញ្ចាំ មានសិទ្ធិកាន់កាប់នូវចលនវត្ថុដែលបានទទួលពីកូនបំណុល ឬតតិយជនដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន និងទទួលការសងពីចលនវត្ថុនោះ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត។

### ១.១.២. កម្មវត្ថុនៃការបញ្ចាំចលនវត្ថុ

ការបញ្ចាំចលនវត្ថុ មានកម្មវត្ថុជាការយកចលនវត្ថុមកដាក់ធានា ចំពោះម្ចាស់បំណុលនៃការបញ្ចាំដោយចលនវត្ថុនេះ សំដៅទៅលើវត្ថុក្រៅពីអចលនវត្ថុ។ មានន័យថា ជាវត្ថុដែលអាចធ្វើការរំកិលបាន បំលាស់ទីបាន ប្តូរទីតាំងបាន[4]។ ឧទាហរណ៍ ម៉ូតូ ឡាន តុ ទូ កៅអី ជាដើម។

ចំពោះទ្រព្យសម្បត្តិដែលគ្មានរូបរាង ដែលអាចគ្រប់គ្រងបាន លើកលែងតែមានបញ្ញត្តិក្នុងច្បាប់ពិសេស បញ្ញត្តិស្តីពីចលនវត្ថុត្រូវយកមកអនុវត្តដូចគ្នាផងដែរ[5]។ ទ្រព្យសម្បត្តិ ដែលគ្មានរូបរាង គឺជាវត្ថុអរូបិយមានដូចជា សិទ្ធិ អគ្គិសនី កំដៅ ពន្លឺ ជាដើម[6]។

---

[1] មាត្រា៨១៦, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, ០៨ ធ្នូ ២០០៧។

[2] មាត្រា១២០ កថាខណ្ឌទី៤, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[3] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ២០១៧, ៣៥។

[4] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ២, ២០១៧, ៣៥។

[5] មាត្រា១២០ កថាខណ្ឌទី៤, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[6] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ២, ២០១៧, ៣៦។

### ១.១.៣. ផលប្រយោជន៍នៃប្រព័ន្ធការបញ្ចាំចលនវត្ថុ

ម្ចាស់សិទ្ធិលើការបញ្ចាំ មានសិទ្ធិកាន់កាប់វត្ថុដែលបានទទួលពីកូនបំណុល ឬតតិយជន ដើម្បីធានានូវសិទ្ធិលើបំណុលរបស់ខ្លួន និងទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនពីវត្ថុនោះ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងៗទៀត។ ក្នុងន័យនេះ ម្ចាស់សិទ្ធិលើការបញ្ចាំ បាននឹងកំពុងកាន់កាប់ដោយចំពោះលើចលនវត្ថុដែលកូនបំណុល ឬតតិយជនបានយកមកដាក់ធានាចំពោះកាតព្វកិច្ចរបស់ខ្លួន ដើម្បីជាការបង្កើនទំនុកចិត្តដល់ម្ចាស់បំណុលថាខ្លួននឹងអនុវត្តកាតព្វកិច្ចរបស់ខ្លួនចំពោះម្ចាស់បំណុល។ អាស្រ័យហេតុនេះ ម្ចាស់បំណុលអាចប្រគល់ឱ្យកូនបំណុលនូវប្រាក់ ឬវត្ថុផ្សេងទៀតដោយមានទំនុកចិត្តទៅកាន់កូនបំណុល ដោយសារការយកទ្រព្យមកធានានេះ។ នៅក្នុងអំឡុងពេលដែលម្ចាស់បំណុលកំពុងកាន់កាប់លើចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំដោយចំពោះ ម្ចាស់បំណុលអាចធ្វើការអាស្រ័យផល និងចាត់ចែងលើវត្ថុដែលជាកម្មវត្ថុនោះ ដោយគ្រាន់តែចាំបាច់ទទួលការអនុញ្ញាតពីកូនបំណុលប៉ុណ្ណោះ។ លើសពីនេះទៅទៀត នៅក្នុងករណីដែលកូនបំណុលមិនធ្វើអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅកាលបរិច្ឆេទដែលត្រូវអនុវត្តបានមកដល់ ម្ចាស់សិទ្ធិលើការបញ្ចាំអាចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើចលវត្ថុដែលដាក់ធានាដោយកូនបំណុល ឬតតិយជន ដើម្បីទូទាត់នូវសិទ្ធិលើបំណុលរបស់ខ្លួន។

### ១.១.៤. ភាគីនៃសិទ្ធិលើការបញ្ចាំ

#### ១.១.៤.១. ម្ចាស់សិទ្ធិលើការបញ្ចាំ

##### ក. រូបវន្តបុគ្គល

រូបវន្តបុគ្គល សំដៅទៅលើមនុស្សពិតតាមធម្មជាតិ ដែលផ្ទុយនឹងនីតិបុគ្គល[7]។ ដែលមានន័យថា ជាមនុស្សដែលមានសាច់ មានឈាម មានជីវិតកំពុងរស់នៅបច្ចុប្បន្ន។ នៅក្នុងទំនាក់ទំនងរដ្ឋប្បវេណី រូបវន្តបុគ្គលអាចក្លាយទៅជាម្ចាស់សិទ្ធិលើការបញ្ចាំបាន តាមរយៈការបង្កើតកិច្ចសន្យាបញ្ចាំរវាងម្ចាស់សិទ្ធិលើការបញ្ចាំ និងអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ស្របតាមការកំណត់របស់ក្រមរដ្ឋប្បវេណី។

##### ខ. នីតិបុគ្គល

នីតិបុគ្គល សំដៅទៅលើក្រុមមនុស្ស ឬមូលនិធិដែលមានបុគ្គលភាពគតិយុត្ត ហើយជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ច[8]។ នីតិបុគ្គល អាចក្លាយទៅជាម្ចាស់អាជីវកម្មទទួលបញ្ចាំបាន ដោយគោរពទៅតាមលក្ខខណ្ឌ

---

[7] គណកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, សន្ទានុក្រមផ្នែករដ្ឋប្បវេណី, បោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧, លេខ ១២៧។

[8] គណកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, សន្ទានុក្រមផ្នែករដ្ឋប្បវេណី, បោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧, លេខ ៧១។

ដែលបានកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយលក្ខខណ្ឌដែលអនុញ្ញាតឱ្យនីតិបុគ្គលអាចប្រកបអាជីវកម្មទទួលបញ្ចាំបាន ជាគោលការណ៍ត្រូវមានអាជ្ញាបណ្ណអនុញ្ញាត ហើយលក្ខខណ្ឌដើម្បីទទួលបានអាជ្ញាបណ្ណ គឺមានភាពខុសៗគ្នាអាស្រ័យទៅតាមអាជីវកម្មខ្នាតតូច ខ្នាតមធ្យម ឬខ្នាតធំ។

ចំពោះអាជីវកម្មខ្នាតមធ្យម និងខ្នាតធំ រាល់ការប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានខ្នាតមធ្យម និងខ្នាតធំ ត្រូវមានអាជ្ញាបណ្ណពីក្រសួង។ ដើម្បីទទួលបានអាជ្ញាបណ្ណក្រុមហ៊ុន/សហគ្រាស ត្រូវដាក់ពាក្យស្នើសុំនៅនាយកដ្ឋានដោយបំពេញលក្ខខណ្ឌដូចខាងក្រោម[9]៖

-ជានីតិបុគ្គលសញ្ជាតិខ្មែរ និងបានចុះបញ្ជីពាណិជ្ជកម្មស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា (ចំពោះអាជីវកម្មខ្នាតធំកម្រិត២ ត្រូវចុះបញ្ជីជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត)

-ត្រូវមានដើមទុនប្រកបអាជីវកម្មដូចមានចែងនៅក្នុងប្រការ៩ នៃប្រកាសនេះ

-ត្រូវតំកល់ប្រាក់ធានាអាជីវកម្ម ១០% នៃដើមទុន

-អ្នកកាន់កាប់អាជ្ញាបណ្ណត្រូវមានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រផ្សេងទៀតដែលទាក់ទងនឹងអាជីវកម្ម ឬមានបទពិសោធន៍ទាក់ទងទៅនឹងធុរកិច្ចស្រដៀងគ្នា ឬធ្លាប់បម្រើការងារផ្នែកនេះ។ ក្នុងករណីដែលអ្នកឈរឈ្មោះមិនមែនជាភាគហ៊ុននិក ត្រូវមានលិខិតបញ្ជាក់ពីក្រសួងពាណិជ្ជកម្ម។

-ត្រូវមានទីតាំងប្រកបអាជីវកម្មច្បាស់លាស់ដែលបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច។

នាយកដ្ឋានដែលត្រូវដាក់ពាក្យស្នើសុំដើម្បីទទួលបានអាជ្ញាបណ្ណក្រុមហ៊ុន/សហគ្រាស សំដៅដល់អគ្គនាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុបញ្ចាំ និងប្រាតិភោគដោយអនុប្បទាននៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

លក្ខខណ្ឌលម្អិតសម្រាប់ការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្ម ត្រូវបានកំណត់ក្នុងពាក្យស្នើសុំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ចំពោះអាជីវកម្មខ្នាតតូច រាល់ការប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬប្រាតិភោគដោយអនុប្បទានខ្នាតតូច ត្រូវមានលិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្មពីមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត។ ដើម្បីទទួលបានលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមហ៊ុន/សហគ្រាស ត្រូវដាក់ពាក្យស្នើសុំទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានី-ខេត្ត ដោយបំពេញលក្ខខណ្ឌដូចខាងក្រោម៖

-ជានីតិបុគ្គលសញ្ជាតិខ្មែរ និងបានចុះបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់នៅព្រះរាជាណាចក្រកម្ពុជា

[9] ប្រការ៦, ប្រកាសស្តីពីការគ្រប់គ្រងអាជីវម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន, លេខ០៣០ សហវ.ប្រក, ១៣ មករា ២០១៧។

-ត្រូវមានដើមទុនប្រកបអាជីវកម្មដូចមានចែងនៅក្នុងប្រការ៩ នៃប្រកាសនេះ

-ត្រូវតម្កល់ប្រាក់ធានាអាជីវកម្ម១០% នៃដើមទុន

-អ្នកកាន់កាប់អាជ្ញាប័ណ្ណត្រូវមានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រផ្សេង ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬមានបទពិសោធន៍ទាក់ទងទៅនឹងធុរកិច្ចស្រដៀងគ្នា ឬធ្លាប់បម្រើការងារផ្នែកនេះ។ ករណីដែលអ្នកឈរឈ្មោះមិនមែនជាភាគហ៊ុននិក ត្រូវមានលិខិតបញ្ជាក់ពីក្រសួងពាណិជ្ជកម្ម។

លក្ខខណ្ឌលម្អិតសម្រាប់ការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្ម ត្រូវបានកំណត់ក្នុងពាក្យស្នើសុំរបស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត។

ចំពោះដើមទុនដែលកំណត់ថាអាជីវកម្មទទួលបញ្ចាំមួយស្ថិតនៅខ្នាតតូច ឬខ្នាតមធ្យម ឬខ្នាតធំ គឺត្រូវអនុលោមទៅតាមខ្នាតដែលកំណត់ដោយប្រការ៩ នៃប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ស្របតាមប្រការ៩ នៃប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើមទុនសម្រាប់ការប្រកបអាជីវកម្មបញ្ចាំ ត្រូវបានកំណត់ដូចខាងក្រោម៖

-ខ្នាតតូច : ត្រូវមានដើមទុនចាប់ពី ២០ លានរៀល ដល់ ៤០ លានរៀល

-ខ្នាតមធ្យម : ត្រូវមានដើមទុនលើសពី ៤០ លានរៀល ដល់ ២០០ លានរៀល

-ខ្នាតធំ (កម្រិត១) : ត្រូវមានដើមទុនលើសពី ២០០ លានរៀល ដល់ ៨០០ លានរៀល

-ខ្នាតធំ (កម្រិត២) : ត្រូវមានដើមទុនលើសពី ៨០០ លានរៀលឡើងទៅ។

រាល់ការបន្ថែម ឬបន្ថយដើមទុនអាជីវកម្មខាងលើត្រូវមានការអនុញ្ញាតពីក្រសួង ឬមន្ទីរជាមុន។

### ១.១.៤.២. អ្នកបង្កើតសិទ្ធិលើការបញ្ចាំ

ស្របតាមមាត្រា ៨១៨ នៃក្រមរដ្ឋប្បវេណី បានចែងថា សិទ្ធិលើការបញ្ចាំត្រូវបានបង្កើតឡើងដោយ កូនបំណុល ឬតតិយជនដែលបង្កើតសិទ្ធិលើការបញ្ចាំនោះ ប្រគល់វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ។ ស្របតាមមាត្រានេះ អ្នកបង្កើតសិទ្ធិលើការបញ្ចាំ សំដៅទៅលើកូនបំណុល ឬតតិយជនដែលយកវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំប្រគល់ទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ។ កូនបំណុលសំដៅទៅលើបុគ្គលដែលមានករណីយកិច្ច[10]។ ដោយឡែក តតិយជនសំដៅទៅលើជនទីបី ឬជនដែលមិនមែនជាភាគីក្នុងទំនាក់ទំនងគតិយុត្ត។

[10] មាត្រា ៣០៨ កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

## ១.២. ការបង្កើតសិទ្ធិលើការបញ្ចាំ

### ១.២.១. លក្ខខណ្ឌសុពលភាព

សិទ្ធិលើការបញ្ចាំត្រូវបានបង្កើតឡើងដោយកូនបំណុល ឬតតិយជនដែលបង្កើតសិទ្ធិលើការបញ្ចាំនោះ ប្រគល់នូវវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ[11]។ ដែលមានន័យថា ការបញ្ចាំត្រូវបង្កើតឡើងតាមការព្រមព្រៀងរបស់ភាគីតែប៉ុណ្ណោះ ដោយមិនទាមទារឱ្យបំពេញទម្រង់ពិសេសណាមួយឡើយ[12]។ ក្នុងន័យនេះ ដើម្បីបង្កើតសិទ្ធិលើការបញ្ចាំចលនវត្ថុ គឺគ្រាន់តែម្ចាស់សិទ្ធិលើការបញ្ចាំ និងអ្នកបង្កើតសិទ្ធិលើការបញ្ចាំមានឆន្ទៈត្រូវគ្នាព្រមបង្កើតសិទ្ធិលើការបញ្ចាំ តាមរយៈកិច្ចសន្យាបញ្ចាំ។ កិច្ចសន្យាបញ្ចាំ ត្រូវបានបង្កើតឡើងដោយសំណើ និងស្ទីការត្រូវគ្នា ហើយភាគីនីមួយៗមានសមត្ថភាពបុគ្គល។

កិច្ចសន្យា ត្រូវមានអានុភាពដោយសារសំណើ និងស្ទីការត្រូវគ្នា[13]។ សំណើគឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្ត ក្នុងករណីដែលមានស្ទីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ។ សំណើត្រូវមានអានុភាពនៅពេលដែលសំណើនោះបានដល់ភាគីម្ខាងទៀត។ ដោយឡែកស្ទីការគឺជាការបង្ហាញឆន្ទៈ ដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ។ ស្ទីការត្រូវមានអានុភាពនៅពេលដែលស្ទីការនោះបានដល់អ្នកស្នើ[14]។

សមត្ថភាពបុគ្គល សំដៅទៅលើសមត្ថភាពដែលច្បាប់បានកំណត់ទៅលើភាគីនៃទំនាក់ទំនងគតិយុត្តមួយ ដើម្បីឱ្យទំនាក់ទំនងគតិយុត្តនោះត្រូវបានបង្កើតឡើងដោយមានសុពលភាពតាមផ្លូវច្បាប់។ សមត្ថភាពបុគ្គលរួមមានដូចជា សមត្ថភាពទទួលសិទ្ធិ សមត្ថភាពខាងឆន្ទៈ និងសមត្ថភាពក្នុងការធ្វើសកម្មភាព។

សមត្ថភាពទទួលសិទ្ធិ ជាពេលវេលាដែលមនុស្សម្នាក់ៗ ចាប់ផ្តើមទទួលបាននូវសមត្ថភាពទទួលសិទ្ធិ និងពេលវេលានៃការបាត់បង់សមត្ថភាពទទួលសិទ្ធិនេះទៅវិញ។ ជាក់ស្តែងយោងតាមមាត្រា៨ នៃក្រមរដ្ឋប្បវេណីបានចែងថា រូបវន្តបុគ្គលម្នាក់ៗមានសមត្ថភាពទទួលសិទ្ធិនៅពេលចាប់កំណើត ហើយបាត់បង់អស់នូវសមត្ថភាពទទួលសិទ្ធិនេះ នៅពេលទទួលមរណភាព។ ផ្អែកតាមបញ្ញត្តិនេះ មានន័យថាអំឡុងពេលដែលរូបវន្តបុគ្គលម្នាក់ៗមានសមត្ថភាពទទួលសិទ្ធិ គឺនៅចន្លោះចាប់ពីពេលចាប់កំណើតរហូតដល់ពេលទទួលមរណភាព។

សមត្ថភាពខាងឆន្ទៈ សំដៅទៅលើសមត្ថភាពដែលភាគីអាចយល់ដឹង និងវិនិច្ឆ័យបានពីលទ្ធផលតាម

---

[11] មាត្រា ៨១៨, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[12] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ២, ២០១៧, ១៤៨។

[13] មាត្រា ៣៣៦, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[14] មាត្រា ៣៧៧, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន។ សកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន អាចលុបចោលបាន[15]។

សមត្ថភាពក្នុងការធ្វើសកម្មភាព សំដៅទៅលើការកម្រិតនូវបុគ្គលដែលមានលក្ខណៈសម្បត្តិ ដែលច្បាប់កំណត់មិនឱ្យធ្វើសកម្មភាពណាមួយ។ បុគ្គលដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព រួមមាន អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ។

កិច្ចសន្យាដែលបានធ្វើឡើងដោយបុគ្គលដែលគ្មានសមត្ថភាពគ្រប់គ្រាន់ តាមការកំណត់របស់ច្បាប់ខាងលើនេះ នឹងនាំឱ្យមានការលុបចោលកិច្ចសន្យាបានដោយសារមូលហេតុកង្វះសមត្ថភាព។

លើសពីនេះ ការបង្កើតកិច្ចសន្យាបញ្ចាំ គឺមិនត្រូវបានកំណត់នូវលក្ខខណ្ឌទម្រង់ជាក់លាក់នោះទេ ពោល គឺមិនចាំបាច់ត្រូវបំពេញលក្ខខណ្ឌទម្រង់ណាមួយដូចជាការធ្វើជាលាយលក្ខណ៍អក្សរ ជាលិខិតឯកជន លិខិតយថាភូត ឬលិខិតដែលមានកាលបរិច្ឆេទស្ថាពរនោះឡើយ។

នៅក្នុងសកម្មភាពនៃការបង្កើតសិទ្ធិលើការបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំ និងអ្នកបង្កើតសិទ្ធិលើការបញ្ចាំអាចកំណត់ពីអត្រាការប្រាក់នៃកិច្ចសន្យា និងអត្រាការប្រាក់យឺតយ៉ាវជាមុនផងដែរ។ អត្រាការប្រាក់ សំដៅទៅលើអត្រាដែលកំណត់ជាភាគរយ ដែលត្រូវយកទៅគណនាជាមួយនឹងប្រាក់ដើម ដើម្បីកំណត់បានពីចំនួនការប្រាក់។ អត្រាការប្រាក់ អាចកំណត់បានតាមបញ្ញត្តិច្បាប់ ឬដោយការព្រមព្រៀងរបស់ភាគី[16]។ ក្នុងន័យនេះ អត្រាការប្រាក់អាចត្រូវបានបែងចែកជា២ ប្រភេទគឺ អត្រាការប្រាក់ដែលកំណត់ដោយច្បាប់ និងអត្រាការប្រាក់ដែលកំណត់ដោយការព្រមព្រៀង។

-អត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ជាអត្រាការប្រាក់ដែលត្រូវយកមកអនុវត្ត នៅក្នុងករណីដែលគូភាគីបានព្រមព្រៀងគ្នានៅក្នុងការបង់ការប្រាក់ ប៉ុន្តែមិនបានកំណត់អំពីអត្រាការប្រាក់។ ដូច្នេះ អត្រាការប្រាក់ដែលកំណត់ដោយក្រមរដ្ឋប្បវេណី ឬច្បាប់ពិសេសត្រូវយកមកអនុវត្ត។ ផ្អែកមាត្រា ៣១៨ នៃក្រមរដ្ឋប្បវេណី អត្រាការប្រាក់ដែលកំណត់ដោយច្បាប់គឺ ៥ ភាគរយនៅក្នុងមួយឆ្នាំ។

-អត្រាការប្រាក់ដែលកំណត់ដោយការព្រមព្រៀង សំដៅទៅលើអត្រាការប្រាក់ដែលគូភាគីបានព្រមព្រៀងគ្នានៅក្នុងការកំណត់ពីអត្រាការប្រាក់នេះ នៅក្នុងការបង្កើតកិច្ចសន្យា ប៉ុន្តែដើម្បីឱ្យអត្រាការប្រាក់ដែលកំណត់ដោយការព្រមព្រៀង ដែលលើសពីអត្រាការប្រាក់ដែលកំណត់ដោយច្បាប់មានអានុភាពលុះត្រាតែបានធ្វើជាលិខិតលាលក្ខណ៍អក្សរ។ អត្រាការប្រាក់ដែលបានព្រមព្រៀង អាចខ្ពស់ជាងអត្រាការប្រាក់ដែល

[15] មាត្រា ១៤, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[16] មាត្រា ៥៨៤ កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

កំណត់ដោយច្បាប់ ប៉ុន្តែមិនអាចខ្ពស់ជាងអត្រាការប្រាក់ដែលត្រូវបានកំរិតនោះទេ[17]។ អត្រាការប្រាក់ដែលត្រូវបានកំរិត សំដៅទៅលើអត្រាការប្រាក់អតិបរមា ដែលអាចកំណត់បានដោយស្របច្បាប់ តាមការព្រមព្រៀងរបស់គូភាគីដែលកំណត់ដោយច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត។ អត្រាការប្រាក់ដែលត្រូវបានកំរិតនឹងត្រូវបានកំណត់នៅក្នុងចន្លោះពី ១០ ភាគរយ ដល់ ៣០ ភាគរយ ក្នុង១ ឆ្នាំ និងត្រូវបានបញ្ញត្តិដោយប្រកាសរួមគ្នារវាងក្រសួងយុត្តិធម៌ និងធនាគារជាតិនៃកម្ពុជា[18]។ ជាក់ស្តែងស្របតាម ប្រកាសស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិតចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌ អត្រាការប្រាក់ដែលត្រូវបានកម្រិតនេះគឺត្រូវបានកំណត់មិនឱ្យលើសពី ១៨ ភាគរយនៅក្នុងមួយឆ្នាំ។ មានន័យថា គូភាគីអាចព្រមព្រៀងគ្នានៅក្នុងការកំណត់អំពីអត្រាការប្រាក់បាន ប៉ុន្តែអត្រាការប្រាក់ដែលកំណត់ដោយការព្រមព្រៀងនេះ គឺមិនអាចលើសពី ១៨ ភាគរយ នៅក្នុងមួយឆ្នាំនោះទេ។ នៅក្នុងករណីដែលភាគី បានកំណត់ពីអត្រាការប្រាក់លើសពីអត្រាការប្រាក់ដែលត្រូវបានកម្រិតកិច្ចសន្យានៃភាគដែលលើសពីកម្រិតនៃអត្រាការប្រាក់នោះ ត្រូវទុកជាមោឃៈរីឯអ្នកខ្ចីមានករណីយកិច្ចត្រូវសងតែចំពោះការប្រាក់ដែលត្រូវបានគណនា តាមអត្រាការប្រាក់ដែលត្រូវបានកម្រិតនោះតែប៉ុណ្ណោះ។

### ១.២.២. លក្ខខណ្ឌតតាំង

ម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ មិនអាចតតាំងសិទ្ធិលើការបញ្ចាំនោះចំពោះតតិយជនបានឡើយ ប្រសិនបើខ្លួនមិនបានកាន់កាប់ជានិរន្តន៍នូវវត្ថុបញ្ចាំនោះ[19]។ ការកាន់កាប់ជានិរន្តន៍ សំដៅទៅលើការណ៍ដែលម្ចាស់សិទ្ធិលើការបញ្ចាំ បានកាន់កាប់លើចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំជាប់នៅក្នុងដៃ តាមរយៈការផ្ទេរការកាន់កាប់ ពីសំណាក់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ ឬតតិយជន។

ចំពោះទម្រង់នៃការផ្ទេរការកាន់កាប់មានចំនួន៤[20] រួមមានដូចជា៖

-ការប្រគល់ដោយជាក់ស្តែង សំដៅទៅលើការកាន់កាប់ត្រូវបានផ្ទេរដោយការប្រគល់វត្ថុកាន់កាប់។ ដែលមានន័យថា អនុប្បទាយីបានផ្ទេរវត្ថុដែលខ្លួនកំពុងកាន់កាប់ជាប់នឹងដៃ ទៅឱ្យអនុប្បទានិកដោយផ្ទាល់ ហើយអនុប្បទានិក បានទទួលដោយផ្ទាល់ផងដែរ តាមរយៈការប្រគល់នេះ។

-ការប្តូរលក្ខណៈនៃការកាន់កាប់ សំដៅទៅលើករណីដែលការកាន់កាប់អាចត្រូវបានផ្ទេរតាមរយៈការព្រមព្រៀងរវាងគូភាគីតែប៉ុណ្ណោះ ដោយគ្មានការប្រគល់ដោយជាក់ស្តែង។ ក្នុងករណីនេះ អនុប្បទានិកនៃ

[17] មាត្រា ៥៨៤ កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[18] [18] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ២, ២០១៧, ១១៧។

[19] មាត្រា ៨២៩, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[20] មាត្រា ២២៩, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ការកាន់កាប់ ត្រូវទទួលការកាន់កាប់ដោយប្រយោលតាមរយៈអនុប្បទាយី។ មានន័យថាតាមរយៈការព្រមព្រៀងរវាងអនុប្បទាយី និងអនុប្បទានិក អនុប្បទាយីនៅតែកាន់កាប់ដោយចំពោះ ហើយអនុប្បទានិកជាអ្នកកាន់កាប់ដោយប្រយោល[21]។

-ការប្រគល់ដោយសង្ខេប សំដៅទៅលើករណីដែល អ្នកដែលនឹងទទួលអនុប្បទាននូវការកាន់កាប់ក្តាប់ទុកវត្ថុកាន់កាប់ដោយចំពោះ តាមការប្រគល់ជាក់ស្តែងហើយ ការកាន់កាប់អាចត្រូវបានផ្ទេរដោយការព្រមព្រៀងរវាងគូភាគីតែប៉ុណ្ណោះ។ ដោយសារហេតុនេះ អនុប្បទាយីនៃការកាន់កាប់ ត្រូវបាត់បង់សូម្បីតែការកាន់ដោយប្រយោលដែលខ្លួនធ្លាប់មាន តាមរយៈអ្នកក្តាប់ទុកវត្ថុកាន់កាប់។

-ការផ្ទេរការកាន់កាប់ដោយបញ្ជា សំដៅទៅលើទម្រង់មួយនៃការផ្ទេរការកាន់កាប់ ដែលអ្នកកាន់កាប់ដោយប្រយោលអាចធ្វើការផ្ទេរការកាន់កាប់ទៅឱ្យតតិយជន ដោយការព្រមព្រៀងជាមួយនឹងតតិយជន និងធ្វើការជូនដំណឹងអំពីហេតុនោះ ទៅឱ្យអ្នកកាន់កាប់ដោយចំពោះ ហើយឱ្យអ្នកកាន់កាប់ដោយចំពោះ ផ្ទេរការកាន់កាប់នោះទៅឱ្យតតិយជន។

ដើម្បីឱ្យម្ចាស់សិទ្ធិលើការបញ្ចាំអាចយកសិទ្ធិលើការបញ្ចាំរបស់ខ្លួន ទៅតតាំងជាមួយនឹងតតិយជនបានលុះត្រាតែម្ចាស់សិទ្ធិលើការបញ្ចាំនោះកំពុងក្តាប់ទុកវត្ថុបញ្ចាំនៅក្នុងដៃ។ ចំពោះទម្រង់នៃការទទួលការកាន់កាប់ដែលម្ចាស់សិទ្ធិលើការបញ្ចាំអាចធ្វើការកាន់កាប់ដោយចំពោះ គឺតាមរយៈការផ្ទេរការប្រគល់ដោយជាក់ស្តែង ការប្រគល់ដោយសង្ខេប និងការផ្ទេរការកាន់កាប់ដោយបញ្ជាប៉ុណ្ណោះ។ ដោយឡែកចំពោះ ការប្តូរលក្ខណៈនៃការកាន់កាប់ គឺម្ចាស់សិទ្ធិលើការបញ្ចាំនឹងមិនទទួលបាននូវការកាន់កាប់ដោយចំពោះនោះទេ ហើយមិនត្រូវបានក្រមរដ្ឋប្បវេណីអនុញ្ញាតចំពោះការបង្កើតសិទ្ធិលើការបញ្ចាំនោះឡើយ។

### ១.៣. អានុភាពនៃការបញ្ចាំចលនវត្ថុ

ក្រោយពេលដែលម្ចាស់សិទ្ធិលើការបញ្ចាំ និងអ្នកបង្កើតសិទ្ធិលើការបញ្ចាំបានព្រមព្រៀងគ្នាបង្កើតសិទ្ធិលើការបញ្ចាំចលនវត្ថុ ដោយធ្វើការផ្ទេរការកាន់កាប់នូវចលនវត្ថុដែលជាកម្មវត្ថុ នោះនឹងបង្កើតឱ្យមានអានុភាពរវាងម្ចាស់សិទ្ធិលើការបញ្ចាំ និងអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ដែលរួមមានដូចជា **ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា** (១.៣.១) **អានុភាពចំពោះផល** (១.៣.២) **ការប្រើប្រាស់ និងអាស្រ័យផលពីវត្ថុបញ្ចាំ** (១.៣.៣) **សិទ្ធិ និងករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ** (១.៣.៤) **ការបញ្ចាំបន្ត** (១.៣.៥) **អានុភាពនៃការឃាត់ទុក** (១.៣.៦) **លំដាប់នៃការបញ្ចាំ** (១.៣.៧) និង **ការហាមឃាត់ចំពោះការបញ្ចាំផ្តាច់** (១.៣.៨) ។

[21] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ១, ២០១៧, ៧២។

### ១.៣.១. ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

សិទ្ធិលើការបញ្ចាំត្រូវធានានូវប្រាក់ដើម ការប្រាក់ ប្រាក់ធានាសងក្នុងករណីដែលមិនគោរពកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិលើការបញ្ចាំ សោហ៊ុយដើម្បីថែរក្សាវត្ថុបញ្ចាំ ព្រមទាំងសំណងការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬវិការៈកំបាំងនៃវត្ថុបញ្ចាំ។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលកំណត់ផ្សេង ក្នុងសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំនោះ[22] ។ ដែលមានន័យថា ជាគោលការណ៍សិទ្ធិលើបំណុលដែលជាប្រាក់ដើម ការប្រាក់ ប្រាក់ធានាសងក្នុងករណីដែលមិនគោរពកិច្ចសន្យា និងសោហ៊ុយផ្សេងៗដែលម្ចាស់សិទ្ធិលើការបញ្ចាំបានចំណាយទៅលើវត្ថុបញ្ចាំ គឺត្រូវបានធានាដោយសិទ្ធិលើការបញ្ចាំ ដែលម្ចាស់សិទ្ធិមានភាពខុសប្លែកពីហ៊ីប៉ូតែក ដែលម្ចាស់បំណុលដែលមានលំដាប់ទាបជាងម្ចាស់សិទ្ធិលើការបញ្ចាំទំនងជាមានតិច។ ហេតុដូច្នេះ ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិលើការបញ្ចាំ មានទំហំធំជាងទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក[23]។ ប៉ុន្តែទំហំនៃការធានានេះមិនត្រូវយកមកអនុវត្តឡើយនៅក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំ និងអ្នកបង្កើតសិទ្ធិលើការបញ្ចាំបានធ្វើការកំណត់ផ្សេងនៅពេលដែលបង្កើតសិទ្ធិលើការបញ្ចាំ។

### ១.៣.២. អានុភាពចំពោះផល

ម្ចាស់សិទ្ធិលើការបញ្ចាំអាចទទួលផលដែលកើតចេញពីវត្ថុបញ្ចាំ និងអាចយកផលនោះមកកាត់សិទ្ធិលើបំណុលរបស់ខ្លួន ដោយមានអាទិភាពជាម្ចាស់បំណុលផ្សេងទៀតបាន។ ផលដែលបានទទួលនេះត្រូវយកមកកាត់ជាមួយនឹងការប្រាក់នៃសិទ្ធិលើបំណុលជាមុន ហើយប្រសិនបើមានសំណល់ត្រូវយកទៅកាត់ជាមួយនឹងប្រាក់ដើម[24]។ ក្នុងន័យនេះ ម្ចាស់សិទ្ធិលើការបញ្ចាំដែលទទួលបានផល ដែលកើតចេញពីវត្ថុបញ្ចាំត្រូវយកផលដែលបានទទួលនោះមកកាត់ជាមួយនឹងសិទ្ធិលើបំណុលរបស់ខ្លួន ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត ប៉ុន្តែក្នុងករណីដែលមានការប្រាក់ ត្រូវយកមកកាត់ជាមួយនឹងការប្រាក់ជាមុនសិន ហើយប្រសិនបើមានសំណល់ក្រោយពីការកាត់ការប្រាក់នៃសិទ្ធិលើបំណុលរួច នោះម្ចាស់សិទ្ធិលើការបញ្ចាំត្រូវយកផលនោះ មកកាត់ជាមួយនឹងប្រាក់ដើមបន្ថែមទៀត។

ស្របតាមក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ផល ត្រូវបានបែងជា២ ប្រភេទគឺ ផលធម្មជាតិ និងផលស៊ីវិល។ ផលធម្មជាតិ សំដៅទៅលើផលដែលកើតឡើងតាមសភាពធម្មជាតិ ហើយត្រូវបានធ្វើលទ្ធកម្ម

---

[22] មាត្រា ៨២០, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[23] មាត្រា ៨២០, ក្រសួងយុត្តិធម៌, សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី, ២០១០។

[24] មាត្រា៨២២, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

តាមវិធីប្រើធម្មតា ដែលមានដូចជា ដំណាំផ្លែឈើ ជាដើម។ ដោយឡែកផលស៊ីវិល សំដៅទៅលើផលដែលជាថ្នូរនឹងការប្រើប្រាស់វត្ថុណាមួយដែលមានដូចជាប្រាក់ថ្លៃឈ្នួល ការប្រាក់ ឬវត្ថុផ្សេងទៀតដែលទទួលបានជាថ្នូរចំពោះការប្រើប្រាស់វត្ថុ[25]។

### ១.៣.៣. ការប្រើប្រាស់ និងអាស្រ័យផលពីវត្ថុបញ្ចាំ

បើពុំមានការយល់ព្រមពីសំណាក់កូនបំណុលទេ ម្ចាស់សិទ្ធិលើការបញ្ចាំ មិនអាចប្រើប្រាស់ ឬជួលវត្ថុបញ្ចាំបានឡើយ។ ប៉ុន្តែ ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើប្រាស់បានត្រឹមតែកម្រិតដែលចាំបាច់ក្នុងការរក្សាវត្ថុបញ្ចាំនោះ[26]។ មានន័យថាជាគោលការណ៍ម្ចាស់សិទ្ធិលើការបញ្ចាំ មិនអាចយកវត្ថុបញ្ចាំដែលបានដាក់បញ្ចាំទៅប្រើប្រាស់ ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួន ឬជួល បានឡើយ ប៉ុន្តែបើមានការអនុញ្ញាត និងយល់ព្រមពីសំណាក់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ នោះម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើប្រាស់ និងជួលវត្ថុបញ្ចាំនោះបាន ពីព្រោះថាជាគោលការណ៍នៃការគោរពឆន្ទៈសេរីរបស់បុគ្គលឯកជន។ លើសពីនេះទៅទៀត ដើម្បីថែរក្សាវត្ថុបញ្ចាំ និងជៀសវាងនូវការខូចខាតផ្សេងៗ ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើប្រាស់វត្ថុបញ្ចាំ ត្រឹមកម្រិតចាំបាច់ក្នុងការថែរក្សាវត្ថុបញ្ចាំនោះ ដោយមិនចាំបាច់មានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះទេ ប៉ុន្តែមិនអាចជួលឬអាស្រ័យផលផ្សេងៗពីវត្ថុបញ្ចាំ នោះបានទេ។

បើម្ចាស់សិទ្ធិលើការបញ្ចាំបានប្រើប្រាស់ ឬជួលវត្ថុបញ្ចាំ ដោយគ្មានការអនុញ្ញាតពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំ នោះអ្នកបង្កើតសិទ្ធិលើការបញ្ចាំអាចទាមទារឱ្យរំលត់នូវសិទ្ធិលើការបញ្ចាំបាន។ ករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំបានលួចប្រើប្រាស់ ឬជួលវត្ថុបញ្ចាំដោយលួចលាក់ ឬដោយគ្មានការអនុញ្ញាតពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំ នោះអ្នកបង្កើតសិទ្ធិលើការបញ្ចាំ អាចទាមទារឱ្យរំលត់សិទ្ធិលើការបញ្ចាំនោះបាន។

### ១.៣.៤. សិទ្ធិ និងករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ នៅក្នុងអំឡុងពេលដែលខ្លួនកំពុងកាន់កាប់វត្ថុបញ្ចាំ

នៅក្នុងអំឡុងពេលដែលខ្លួនកំពុងកាន់កាប់លើវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ដោយអនុលោមទៅតាមមាត្រា ៨២៣ នៃក្រមរដ្ឋប្បវេណី ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវមានករណីយកិច្ច ត្រូវកាន់កាប់លើវត្ថុបញ្ចាំដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត។ ហើយប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំ មិនបានអនុវត្តករណីយកិច្ច នៅក្នុងការគ្រប់គ្រងលើវត្ថុបញ្ចាំដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិតទេនោះនោះអ្នកបង្កើតសិទ្ធិលើការបញ្ចាំនឹងអាចធ្វើការរំលត់នូវសិទ្ធិលើការបញ្ចាំនេះបាន។ ការកាន់កាប់ដោយប្រុង

[25] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទថៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ,សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ១, ២០១៧, ៣៨។

[26] មាត្រា ៨៣១ កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត សំដៅទៅលើការណ៍ដែលអ្នកកាន់កាប់លើវត្ថុបញ្ចាំនោះ បានធ្វើការគ្រប់គ្រង មើលថែរក្សាវត្ថុបញ្ចាំនោះ ហាក់បីដូចជាវត្ថុនោះជាកម្មសិទ្ធិរបស់ខ្លួន។

នៅក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំ បានចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និងថែរក្សាវត្ថុចំពោះវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះអាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងនូវការចំណាយនោះវិញបាន។ ផ្អែកតាមអត្ថន័យនៃសិទ្ធិលើការបញ្ចាំ កម្មសិទ្ធិករនៃវត្ថុបញ្ចាំអាចជា អ្នកបង្កើតសិទ្ធិលើការបញ្ចាំ ឬតតិយជន។ ហើយប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានចេញចំណាយបង្កើនតម្លៃនៃវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះអាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងនូវចំណាយដែលខ្លួនបានចេញ ឬសងនូវប្រាក់ដែលបានកើនឡើងនោះវិញ តាមការជ្រើសរើសរបស់ខ្លួនបាន ក្នុងករណីដែលកំណើននៃតម្លៃនោះនៅតែមាន[27]។ ហើយនៅក្នុងករណីដែលមានការទាមទារឱ្យសងនូវសោហ៊ុយចាំបាច់ ឬសោហ៊ុយបង្កើនតម្លៃពីសំណាក់ម្ចាស់សិទ្ធិលើការបញ្ចាំទៅតុលាការ នោះតុលាការអាចកំណត់ពេលសមរម្យដើម្បីឱ្យកម្មសិទ្ធិករនោះសង ដែលអំឡុងពេលសមរម្យនេះតុលាការនឹងធ្វើការកំណត់ទៅតាមការទាមទាររបស់កម្មសិទ្ធិករ។

ចំពោះម្ចាស់សិទ្ធិលើការបញ្ចាំដែលជានីតិបុគ្គល ត្រូវមានកាតព្វកិច្ចចំពោះអ្នកបង្កើតសិទ្ធិលើការបញ្ចាំដូចមានកំណត់នៅក្នុងប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន។ ស្របតាមប្រការ-៩ នៃប្រកាសនេះ បានបញ្ញត្តិថា អ្នកកាន់អាជ្ញាប័ណ្ណ និងអ្នកកាន់កាប់លិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្ម មានកាតព្វកិច្ចចំពោះវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំដូចជា ត្រូវរក្សាទុកទ្រព្យបញ្ចាំនៅកន្លែងដែលមានសុវត្ថិភាព និងមិនត្រូវយកទ្រព្យនោះទៅប្រើប្រាស់ឡើយ។ លើសពីនេះត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការខូចខាត ឬបាត់បង់លើទ្រព្យបញ្ចាំ កើតឡើងក្នុងអំឡុងពេលជាប់កិច្ចសន្យា។

### ១.៣.៥. ការបញ្ចាំបន្ត

សិទ្ធិលើការបញ្ចាំ ត្រូវបានបង្កើតឡើងដោយចាំបាច់ត្រូវឱ្យអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ផ្ទេរការកាន់កាប់ដោយចំពោះ ដល់ម្ចាស់សិទ្ធិលើការបញ្ចាំ ដែលការណ៍នេះបានអនុញ្ញាតឱ្យម្ចាស់សិទ្ធិលើការបញ្ចាំអាចកាន់កាប់ដោយផ្ទាល់លើវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំនោះ។ ការកាន់កាប់ដោយចំពោះលើវត្ថុដែលជាកម្មវត្ថុនេះ នៅពេលខ្លះម្ចាស់សិទ្ធិលើការបញ្ចាំអាចយកវត្ថុបញ្ចាំនោះ ទៅធ្វើការចាត់ចែងផ្សេងៗទៀតបានដូចជាយកទៅដាក់ប្រាតិភោគ ឬបញ្ចាំបន្តជាដើម។ ម្ចាស់សិទ្ធិលើការបញ្ចាំនឹងអាចយកវត្ថុ ទៅដាក់បញ្ចាំបន្តទៀតបាន ដោយទទួលការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះ ដើម្បីធានាកាតព្វកិច្ចរបស់ខ្លួន[28]។ មានន័យថា ម្ចាស់

[27] មាត្រា៨២៤, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[28] មាត្រា៨២៦ កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

សិទ្ធិលើការបញ្ចាំនឹងអាចយកវត្ថុបញ្ចាំទៅដាក់បញ្ចាំបន្ត ដើម្បីធានាកាតព្វកិច្ចរបស់ខ្លួនបានលុះត្រាតែមានការអនុញ្ញាតពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំជាមុនសិន។

ក្នុងអំឡុងពេលដែលសិទ្ធិលើការបញ្ចាំកំពុងមានអត្ថិភាព ម្ចាស់សិទ្ធិលើការបញ្ចាំអាចយកវត្ថុបញ្ចាំនោះទៅដាក់បញ្ចាំបន្តទៀតបាន ក្រោមការទទួលខុសត្រូវរបស់ខ្លួនបាន[29]។ ក្នុងន័យនេះ បើទោះបីជាគ្មានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំក៏ដោយ ក៏ម្ចាស់សិទ្ធិលើការបញ្ចាំអាចយកវត្ថុបញ្ចាំនោះទៅដាក់បញ្ចាំបន្តទៀតបាន បើទោះបីជាមានប្រធានសក្តិក៏ដោយ[30]។ មានន័យថា នៅក្នុងអំឡុងពេលដែលសិទ្ធិលើការបញ្ចាំនៅមានអត្ថិភាព នោះម្ចាស់សិទ្ធិលើការបញ្ចាំអាចយកវត្ថុបញ្ចាំទៅដាក់បញ្ចាំបន្តទៀតបាន បើទោះបីជាមិនបានទទួលការយល់ព្រមពីសំណាក់អ្នកបង្កើតសិទ្ធិលើការបញ្ចាំក៏ដោយ ក៏ប៉ុន្តែការបញ្ចាំបន្តនេះត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួន។ ម្ចាស់សិទ្ធិលើការបញ្ចាំ ក៏ត្រូវទទួលខុសត្រូវចំពោះការខូចខាតដោយប្រធានសក្តិ ដែលមិនអាចកើតមានឡើង ប្រសិនបើមិនបានដាក់បញ្ចាំបន្តទេ។ ប្រធានសក្តិ ជាព្រឹត្តិការណ៍ដែលកើតឡើងក្រៅពីឆន្ទៈ មិនអាចប៉ាន់ស្មានជាមុន និងមិនអាចជម្នះបាន[31]។ ម្ចាស់សិទ្ធិលើការបញ្ចាំ ដែលយកវត្ថុបញ្ចាំទៅបញ្ចាំបន្តដោយគ្មានការអនុញ្ញាត មិនអាចរួចផុតពីការទទួលខុសត្រូវចំពោះសំណងការខូចខាត លើវត្ថុបញ្ចាំដែលបានកើតឡើងដោយសារតែប្រធានសក្តិ ដែលការខូចខាតលើវត្ថុបញ្ចាំដោយសារប្រធានសក្តិនោះ នឹងមិនកើតឡើងឡើយ ប្រសិនបើមិនបានដាក់បញ្ចាំបន្តទេនោះ។

នៅពេលដែលធ្វើការបែងចែកចំណែកថ្លៃលក់ដោយបង្ខំនៃវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំបន្តអាចទទួលនូវការសងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនទាំងអស់ ដោយមានត្រឹមកម្រិតនៃចំនួនទឹកប្រាក់ដែលត្រូវចែកចំណែកទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ។ ប៉ុន្តែប្រសិនបើសិទ្ធិលើបំណុលរបស់ខ្លួនមិនទាន់ដល់ពេលកំណត់សងទេ ម្ចាស់សិទ្ធិលើការបញ្ចាំបន្តគ្រាន់តែអាចទាមទារឱ្យតម្កល់នូវចំនួនទឹកប្រាក់ដែលខ្លួនអាចទាមទារឱ្យសងបានប៉ុណ្ណោះ[32]។ តាមអត្ថន័យនៃបញ្ញត្តិនេះ ម្ចាស់សិទ្ធិលើការបញ្ចាំបន្ត អាចទទួលការសងចំពោះសិទ្ធិលើការបញ្ចាំរបស់ខ្លួន ត្រឹមទំហំនៃទឹកប្រាក់ដែលត្រូវចែកចំណែកទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំបន្ត ក្រោយពេលដែលបានលក់ដោយបង្ខំលើវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ។

[29] មាត្រា ៨២៦ កថាខណ្ឌទី១ វាក្យខណ្ឌទី១, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[30] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ,សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ២, ២០១៧, ១៥០។

[31] គណកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, សន្ទានុក្រមផ្នែករដ្ឋប្បវេណី, បោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រី។ ២០០៧, លេខ១០០។

[32] មាត្រា ៨២៦ កថាខណ្ឌ, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ឧទាហរណ៍[33]៖ **ក** បានដាក់បញ្ចាំគ្រឿងអលង្ការ (១) នៅនឹង **ខ** ដើម្បីធានាបំណុលរបស់ខ្លួនចំនួន ១,000 ដុល្លារ។ **ខ** បានយកគ្រឿងអលង្ការ (១) ទៅដាក់បញ្ចាំបន្តនឹង **គ** ដើម្បីធានាបំណុលចំនួន ២,000 ដុល្លារ ដោយគ្មានការយល់ព្រមពី **ក** ។

១. ប្រសិនបើ **ខ** មិនអាចអនុវត្តកាតព្វកិច្ចរបស់ខ្លួន ហើយ **គ** ក៏បានអនុវត្តសិទ្ធិលើការបញ្ចាំបន្តរបស់ខ្លួន តើ **គ** អាចទទួលបានប្រាក់ចំនួនប៉ុន្មាន? នៅក្នុងករណីនេះ **គ** ដែលជាម្ចាស់សិទ្ធិលើការបញ្ចាំបន្ត អាចទទួលបាននូវប្រាក់ដែលបានមកពីការអនុវត្តសិទ្ធិលើការបញ្ចាំ តែចំនួន ១000 ដុល្លារតែប៉ុណ្ណោះ ។

២. **គ** បានធ្វើឱ្យគ្រឿងអលង្ការនោះខូច ដោយសារតែកំហុសរបស់ខ្លួន។ តើ **ក** អាចទាមទារអ្វីខ្លះពី **ខ** ប្រសិនបើ **ក** ដឹងពីករណីនេះ? នៅក្នុងករណីនេះ **ខ** ត្រូវទទួលខុសត្រូវចំពោះការខូចខាតនេះ ចំពោះ **ក** ។

### ១.៣.៦. អានុភាពនៃការឃាត់ទុកវត្ថុបញ្ចាំ

សិទ្ធិលើការបញ្ចាំ ត្រូវបានបង្កើតឡើងដោយមានការផ្ទេរការកាន់កាប់ដោយចំពោះនៃវត្ថុបញ្ចាំ។ ដូច្នេះម្ចាស់សិទ្ធិលើការបញ្ចាំ គឺជាអ្នកកាន់កាប់លើវត្ថុបញ្ចាំនៅក្នុងដៃ។ ហេតុនេះម្ចាស់សិទ្ធិលើការបញ្ចាំ អាចធ្វើការឃាត់ទុកវត្ថុបញ្ចាំបាន រហូតដល់ពេលដែលទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួន ក្នុងទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ដែលរួមមានដូចជា ប្រាក់ដើម ការប្រាក់ ប្រាក់ធានាការសងក្នុងករណីដែលមិនអនុវត្តកិច្ចសន្យា សោហ៊ុយសម្រាប់អនុវត្តសិទ្ធិលើការបញ្ចាំ សោហ៊ុយដើម្បីថែរក្សាវត្ថុបញ្ចាំ ព្រមទាំងប្រាក់សំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ចផងដែរ។

ប៉ុន្តែ សិទ្ធិឃាត់ទុកនេះមិនអាចតតាំង ចំពោះម្ចាស់សិទ្ធិលើបំណុលដែលមានអាទិភាពជាងខ្លួនឡើយ[34]។ នៅក្នុងករណីដែលមានម្ចាស់សិទ្ធិលើបំណុលដែលមានអាទិភាពជាង នោះម្ចាស់សិទ្ធិលើការបញ្ចាំមិនអាចយកសិទ្ធិឃាត់ទុក លើវត្ថុបញ្ចាំរបស់ខ្លួនមកអះអាងជាមួយនឹងម្ចាស់បំណុលដែលមានអាទិភាពជាងខ្លួន ដូចជា ម្ចាស់បំណុលនៃឯកសិទ្ធិ ឬម្ចាស់បំណុលដែលមានលំដាប់ខ្ពស់ជាងខ្លួនឡើយ។

### ១.៣.៧. លំដាប់នៃសិទ្ធិលើការបញ្ចាំ

ជាគោលការណ៍ នៅពេលបង្កើតសិទ្ធិលើការបញ្ចាំ ដោយយកចលនវត្ថុទៅដាក់បញ្ចាំ ដើម្បីធានាបំណុល នោះចលនវត្ថុនោះត្រូវផ្ទេរទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំជាអ្នកកាន់កាប់ដោយចំពោះ។ ជាងនេះទៅទៀត ស្របតាមមាត្រា ៨១៩ នៃក្រមរដ្ឋប្បវេណីបានកម្រិតបន្ថែមទៀតថា ម្ចាស់សិទ្ធិលើការបញ្ចាំមិនអាចឱ្យអ្នកបង្កើត

[33] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ,សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ២ ២០១៧, ១៥០។

[34] មាត្រា ៨២១, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

សិទ្ធិលើការបញ្ចាំនោះ កាន់កាប់ដោយផ្ទាល់លើវត្ថុបញ្ចាំនោះឡើយ។ ស្របតាមអត្ថន័យនេះ គឺអ្នកបង្កើតសិទ្ធិលើការបញ្ចាំមិនអាចនឹងយកចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំនោះ ដើម្បីយកទៅធានាបំណុលរបស់ខ្លួនជាមួយនឹងម្ចាស់បំណុលផ្សេងទៀតនោះឡើយ។ ក៏ប៉ុន្តែ មានករណីខ្លះដែរគឺពុំមានការផ្ទេរការកាន់កាប់ដោយចំពោះនោះទេ ពោលគឺវត្ថុបញ្ចាំត្រូវបានកាន់កាប់ដោយផ្ទាល់ពីសំណាក់កូនបំណុល ហើយខណៈនោះកូនបំណុលបានយកវត្ថុបញ្ចាំទៅធានាបំណុលរបស់ខ្លួនជាមួយនឹងម្ចាស់បំណុលផ្សេងទៀត ដែលស្ថានភាពនេះ គឺត្រូវយកលំដាប់នៃការបញ្ចាំមកធ្វើការពិចារណា ដើម្បីកំណត់អំពីលំដាប់នៃម្ចាស់សិទ្ធិលើការបញ្ចាំដែលនឹងត្រូវទទួលបានការសងដែលមានអាទិភាព។

នៅក្នុងករណីដែលបានបង្កើតសិទ្ធិលើការបញ្ចាំចលនវត្ថុតែមួយ ដើម្បីធានាសិទ្ធិលើបំណុលច្រើន លំដាប់នៃសិទ្ធិលើការបញ្ចាំទាំងនោះត្រូវអនុលោមទៅតាមពេលវេលាដែលបានបង្កើតនោះ[35]។ មានន័យថា ពេលវេលានៃការបង្កើតសិទ្ធិលើការបញ្ចាំ ត្រូវបានយកមកធ្វើជាមូលដ្ឋាននៅក្នុងការកំណត់ពីលំដាប់នៃម្ចាស់សិទ្ធិលើការបញ្ចាំ ដែលមានសិទ្ធិទទួលបានជាអាទិភាពពីចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ។

## ១.៣.៨.ការហាមឃាត់ការបញ្ចាំផ្តាច់

អ្នកបង្កើតសិទ្ធិលើការបញ្ចាំ មិនអាចព្រមព្រៀងឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ទទួលកម្មសិទ្ធិលើវត្ថុបញ្ចាំ ឬចាត់ចែងវត្ថុបញ្ចាំ តាមវិធីផ្សេងពីវិធីដែលច្បាប់បានកំណត់ ដោយសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ ឬដោយកិច្ចសន្យាដែលធ្វើមុនកំណត់ពេលត្រូវសងបានទេ ប្រសិនបើពុំមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ឬច្បាប់ផ្សេងទៀត ដោយស្របតាមមាត្រា-៨២៧ នៃក្រមរដ្ឋប្បវេណី។ ក្នុងន័យនេះ ទោះបីជាសិទ្ធិលើការបញ្ចាំត្រូវបានបង្កើតឡើងតាមគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជនក៏ដោយ ក៏ច្បាប់បានធ្វើការកម្រិតនូវសិទ្ធិមួយចំនួនចំពោះម្ចាស់សិទ្ធិលើការបញ្ចាំ និងអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ដោយមិនអនុញ្ញាតឱ្យធ្វើកិច្ចសន្យាបញ្ចាំផ្តាច់ ដែលត្រូវបានធ្វើនៅមុនពេលកំណត់ត្រូវសង តាមការព្រមព្រៀងរបស់ភាគីទេ បើមិនមានកំណត់ពិសេសនៅក្នុងក្រមរដ្ឋប្បវេណី ឬច្បាប់ផ្សេងៗទេនោះ។ ការណ៍ដែលក្រមរដ្ឋប្បវេណី ហាមឃាត់មិនឱ្យធ្វើការបញ្ចាំផ្តាច់នៅមុនកំណត់ពេលត្រូវសង គឺក្នុងគោលបំណងដើម្បីការពារអ្នកបង្កើតសិទ្ធិលើការបញ្ចាំ និងបង្ការមិនឱ្យម្ចាស់សិទ្ធិលើការបញ្ចាំទទួលបានផលប្រយោជន៍ច្រើនហួសប្រមាណ។

ប៉ុន្តែប្រសិនបើកិច្ចសន្យា ឬសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ ដែលនាំឱ្យម្ចាស់សិទ្ធិទទួលបាននូវកម្មសិទ្ធិលើវត្ថុបញ្ចាំ ឬចាត់ចែងវត្ថុបញ្ចាំ នៅក្រោយពេលកំណត់សងនៃកិច្ចសន្យាបញ្ចាំ គឺមិនត្រូវបានហាមឃាត់

[35] មាត្រា ៨៣៣, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

នោះទេ[36]។ ដែលមានន័យថា ប្រសិនបើនៅក្រោយពេលដែលសិទ្ធិលើការបញ្ចាំបានដល់កាលកំណត់សង ហើយនោះ នៅក្រោយពេលនៃកាលកំណត់ត្រូវសងនោះ ម្ចាស់សិទ្ធិលើការបញ្ចាំ និងអ្នកបង្កើតសិទ្ធិលើការបញ្ចាំ អាចធ្វើកិច្ចសន្យាបញ្ចាំដែលនាំឱ្យម្ចាស់សិទ្ធិលើការបញ្ចាំអាចទទួលបាននូវកម្មសិទ្ធិ ឬការចាត់ចែងផ្សេងទៀត លើវត្ថុបញ្ចាំបាន។

## ១.៤. ការអនុវត្តសិទ្ធិលើការបញ្ចាំ

ប្រសិនបើដល់កាលកំណត់ដែលអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន ប៉ុន្តែអ្នកបង្កើត សិទ្ធិលើការបញ្ចាំនោះ មិនអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាបញ្ចាំរបស់ខ្លួនទេនោះ នោះម្ចាស់សិទ្ធិលើការបញ្ចាំអាច អនុវត្តសិទ្ធិលើការបញ្ចាំទៅលើចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំនោះបាន ដោយយកចលនវត្ថុដែលជាកម្មវត្ថុនៃ ការបញ្ចាំនោះមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ក៏ប៉ុន្តែការយកចលនវត្ថុដែលជាកម្មវត្ថុនោះមកធ្វើជាកម្មសិទ្ធិនេះ គឺត្រូវ តែឆ្លងកាត់តាមនីតិវិធីតុលាការ។ ក្រមរដ្ឋប្បវេណីបានកំណត់ថា ការអនុវត្តសិទ្ធិលើការបញ្ចាំចំពោះចលនវត្ថុយ៉ាង ដូច្នេះថា ជាការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប និងបានកំណត់អំពីនីតិវិធីដែលត្រូវអនុវត្តតាមផ្លូវតុលាការ ផងដែរ។

### ១.៤.១. ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប

#### ១.៤.១.១. លក្ខខណ្ឌនៃការអនុវត្ត

ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំចំពោះចលនវត្ថុមិនបានទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួន ទេ ម្ចាស់សិទ្ធិនោះអាចទាមទារទៅតុលាការឱ្យយកវត្ថុបញ្ចាំមកសងផ្ទាល់តែម្តង តាមការវាយតម្លៃរបស់អ្នកវាយ តម្លៃបាន លុះត្រាតែមានមូលហេតុត្រឹមត្រូវ។ ក្នុងករណីនេះ ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវជូនដំណឹងអំពីការទាម ទារនោះទៅកូនបំណុលជាមុន[37]។ តាមរយៈខ្លឹមសារនៃមាត្រានេះយើងឃើញថា ដើម្បីឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ អាចអនុវត្តសិទ្ធិលើការបញ្ចាំបានលុះត្រាបំពេញលក្ខខណ្ឌយ៉ាងតឹងរ៉ឹងចំនួន៤ ដូចជា[38]៖

-តាមរយៈតុលាការ

-ការវាយតម្លៃត្រឹមត្រូវពីសំណាក់អ្នកវាយតម្លៃ

-ការជូនដំណឹងដល់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ

[36] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ,សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ២, ទំព័រ១៥០។

[37] មាត្រា ៨៣២ កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[38] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ២, ២០១៧, ១៥២។

-មានមូលហេតុត្រឹមត្រូវ ។

ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប គឺហាក់បីដូចជាការបញ្ចាំផ្ដាច់ដែលត្រូវបានហាមឃាត់ដោយក្រមរដ្ឋប្បវេណី ប៉ុន្តែការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេបនេះ គឺមិនដូចគ្នានោះទេដោយហេតុថា ការហាមឃាត់ការបញ្ចាំផ្ដាច់ គឺហាមមិនឱ្យភាគីធ្វើកិច្ចសន្យាដែលនាំឱ្យម្ចាស់សិទ្ធិលើការបញ្ចាំទទួលបាននូវកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ដោយសារសកម្មភាពនៃការបង្កើតសិទ្ធិលើការបញ្ចាំ ឬដោយកិច្ចសន្យាដែលធ្វើនៅមុនពេលកំណត់សង ផ្ទុយទៅវិញការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប គឺម្ចាស់សិទ្ធិលើការបញ្ចាំទទួលបានកម្មសិទ្ធិលើវត្ថុបញ្ចាំតាមរយៈតុលាការ ហើយត្រូវបានបំពេញលក្ខខណ្ឌយ៉ាងតឹងរ៉ឹង ដូចដែលមានរៀបរាប់ខាងលើ។

### ១.៤.១.២. នីតិវិធីនៃការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប

នីតិវិធីនៃការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប គឺម្ចាស់សិទ្ធិលើការបញ្ចាំត្រូវធ្វើតាមរយៈតុលាការ។ យោងតាមមាត្រា ៥០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ស្ដីពីនីតិវិធីនៃការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប បានបញ្ញត្តិថា៖

១. ម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ អាចដាក់ពាក្យសុំឱ្យចេញដីកាសម្រេចអនុញ្ញាតឱ្យយកវត្ថុបញ្ចាំនោះមកសងផ្ទាល់តែម្ដង ទៅសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលត្រូវអនុវត្តកាតព្វកិច្ច ដោយផ្អែកលើបញ្ញត្តិស្ដីពីការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេបដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី។

២. ក្នុងការចេញដីកាសម្រេចអំពីពាក្យសុំដែលមានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ តុលាការត្រូវសួរម្ចាស់សិទ្ធិលើការបញ្ចាំ កម្មសិទ្ធិករនៃវត្ថុបញ្ចាំ និងកូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា។

៣. បើចេញដីកាសម្រេចអនុញ្ញាតដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ តុលាការត្រូវជ្រើសតាំងអ្នកវាយតម្លៃឱ្យវាយតម្លៃនូវវត្ថុបញ្ចាំជាមុន ដោយផ្អែកលើបញ្ញត្តិស្ដីពីការអនុវត្តសិទ្ធិលើការបញ្ចាំដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំបានដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ ដោយកំណត់តម្លៃនៃវត្ថុបញ្ចាំ តាមការវាយតម្លៃនៃវត្ថុបញ្ចាំដោយខ្លួនឯង ហើយកម្មសិទ្ធិករនៃវត្ថុបញ្ចាំបានយល់ព្រមនឹងតម្លៃនោះ។

៤. បើតុលាការចេញដីកាសម្រេចអនុញ្ញាតដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះ សោហ៊ុយសម្រាប់នីតិវិធីនោះ ត្រូវចាត់ទុកជាបន្ទុករបស់កម្មសិទ្ធិករនៃវត្ថុបញ្ចាំ។

៥. ក្នុងដីកាសម្រេចអនុញ្ញាតដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ តុលាការត្រូវប្រកាសអនុញ្ញាតឱ្យយកវត្ថុបញ្ចាំមកសងដោយផ្ទាល់ ក្នុងចំនួនទឹកប្រាក់ដែលអ្នកវាយតម្លៃបានវាយតម្លៃ ហើយព្រមជាមួយគ្នានេះ បើចំនួនដែលអ្នកវាយតម្លៃបានវាយតម្លៃនោះ លើសពីចំនួនទឹកប្រាក់សរុបនៃកាតព្វកិច្ចដែលត្រូវសង

និងសោហ៊ុយសម្រាប់នីតិវិធី តុលាការត្រូវបង្គាប់ឱ្យសងចំនួនដែលលើសនោះទៅឱ្យកម្មសិទ្ធិករនៃវត្ថុបញ្ចាំវិញ។

៦. ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ អាចប្តឹងជំទាស់បាន។

៧. ដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី៥ ខាងលើនេះ ពុំមានអានុភាពឡើយបើមិនបានចូលជាស្ថាពរ។

ស្របតាមនីតិវិធីដែលបានកំណត់ដោយមាត្រា ៥០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី នេះគឺថា កាលបើដល់កាលកំណត់ដែលត្រូវអនុវត្តកាតព្វកិច្ច ដើម្បីអាចឱ្យម្ចាស់សិទ្ធិលើការបញ្ចាំអនុវត្តសិទ្ធិលើការបញ្ចាំរបស់ខ្លួនគឺម្ចាស់សិទ្ធិត្រូវដាក់ពាក្យសុំទៅតុលាការឱ្យចេញដីកាសម្រេចអនុញ្ញាតឱ្យយកវត្ថុបញ្ចាំនោះមកសងផ្ទាល់ បន្ទាប់មកតុលាការនឹងធ្វើការសួរម្ចាស់សិទ្ធិលើការបញ្ចាំ កម្មសិទ្ធិករនៃវត្ថុបញ្ចាំ និងកូនបំណុល បន្ទាប់ពីបញ្ចប់ការសួរហើយ តុលាការអាចចេញដីកាសម្រេចអនុញ្ញាតឱ្យយកវត្ថុបញ្ចាំនោះមកសង និងជ្រើសតាំងអ្នកវាយតម្លៃ ដោយនៅក្នុងខ្លឹមសារនៃដីកាសម្រេចនេះ តុលាការនឹងប្រកាសឱ្យយកវត្ថុបញ្ចាំមកសងដោយផ្ទាល់ តាមចំនួនទឹកប្រាក់ដែលអ្នកវាយតម្លៃបានធ្វើការវាយតម្លៃ ហើយប្រសិនបើចំនួនទឹកប្រាក់ដែលបានវាយតម្លៃនោះលើស នោះតុលាការត្រូវបង្គាប់ឱ្យម្ចាស់សិទ្ធិលើការបញ្ចាំសងនូវចំនួនដែលលើសនេះទៅកម្មសិទ្ធិករវិញ។ លើសពីនេះ ដីកាសម្រេចដែលចេញដោយតុលាការនេះ ក៏បើកសិទ្ធិឱ្យភាគីម្ខាងទៀតប្តឹងជំទាស់បានផងដែរ។

### ១.៤.២. ការអនុវត្តសិទ្ធិលើការបញ្ចាំដោយការលក់ដោយបង្ខំ

#### ១.៤.២.១. ការដាក់ពាក្យសុំអនុវត្តសិទ្ធិលើការបញ្ចាំ

ពាក្យសុំអនុវត្តសិទ្ធិលើការបញ្ចាំចំពោះចលនវត្ថុ ត្រូវធ្វើទៅអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុបញ្ចាំស្ថិតនៅ[39]។

នៅក្នុងពាក្យសុំត្រូវសរសេរនូវចំណុចដូចជាៈ

ក. សញ្ញាណនៃម្ចាស់បំណុលនៃការអនុវត្ត កូនបំណុលនៃការអនុវត្ត កូនបំណុលនៃសិទ្ធិលើបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា។

ខ. សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវធានា

គ. សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើការបញ្ចាំ និងទីកន្លែងនៃចលនវត្ថុ

ឃ. ហេតុការណ៍ និងទំហំនៃផ្នែកនៃសិទ្ធិលើបំណុលដែលត្រូវបានធានា បើធ្វើការអនុវត្តសិទ្ធិលើការបញ្ចាំចំពោះផ្នែកមួយនៃសិទ្ធិលើបំណុលដែលត្រូវបានធានា។ ដោយសារម្ចាស់សិទ្ធិលើការបញ្ចាំកាន់កាប់

[39] មាត្រា ៣៨៤ កថាខណ្ឌទី១, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

ចលនវត្ថុ ដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំម្ចាស់សិទ្ធិលើការបញ្ចាំអាចដាក់ចលនវត្ថុនោះទៅអាជ្ញាសាលាដើម្បីធ្វើការលក់ដោយបង្ខំបានដោយមិនចាំបាច់មានលិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគទេ។

**១.៤.២.២. ការលក់ឡាយឡុង និងការចែកចំណែក**

បន្ទាប់ពីទទួលបានពាក្យសុំអនុវត្តសិទ្ធិលើការបញ្ចាំ អាជ្ញាសាលាត្រូវធ្វើការលក់ដោយបង្ខំតាមវិធីលក់ឡាយឡុង ដោយផ្ទាល់មាត់ ឬដោយស្រោមសំបុត្រ។ ហើយអាជ្ញាសាលាត្រូវជូនដំណឹងជាសាធារណៈអំពីចលនវត្ថុដែលត្រូវដាក់លក់ និង វិធីលក់ចលនវត្ថុនោះ ដោយបិទប្រកាសនៅកន្លែងសម្រាប់បិទប្រកាសរបស់តុលាការ។

បន្ទាប់ពីលក់ឡាយឡុងនូវចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ និងទទួលការបង់ប្រាក់ថ្លៃលក់ពីអ្នកទិញហើយ អាជ្ញាសាលាត្រូវធ្វើការចែកចំណែក ចំពោះម្ចាស់សិទ្ធិលើការបញ្ចាំ ហើយប្រសិនបើមាននៅសេសសល់ប្រាក់ថ្លៃលក់ត្រូវប្រគល់ទៅឱ្យកម្មសិទ្ធិករនៃវត្ថុបញ្ចាំ។ លើសពីនេះ ករណីម្ចាស់សិទ្ធិលើការបញ្ចាំកំពុងកាន់កាប់វត្ថុបញ្ចាំដោយសារម្ចាស់សិទ្ធិលើការបញ្ចាំអះអាងពីអានុភាពនៃការឃាត់ទុក នោះគឺអាចបដិសេធក្នុងការដាក់ចលនវត្ថុដែលជាកម្មវត្ថុទៅអាជ្ញាសាលាបាន។

# ជំពូកទី២
# សិទ្ធិប្រាតិភោគដោយអនុប្បទាន

# ជំពូកទី២

# សិទ្ធិប្រាតិភោគដោយអនុប្បទាន

## ២.១. សញ្ញាណទូទៅនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

### ២.១.១. និយមន័យនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

ប្រាតិភោគដោយអនុប្បទាន សំដៅទៅលើការណ៍ដែលកូនបំណុល ឬតតិយជនធ្វើអនុប្បទាននូវចលនវត្ថុរបស់ខ្លួនជាកំណត់ ទៅឱ្យម្ចាស់បំណុលដើម្បីធានាកាតព្វកិច្ច[40]។ ចំពោះប្រាតិភោគ សំដៅទៅលើការធានាដល់ម្ចាស់បំណុលក្នុងការប្រមូលឥណទេយ្យរបស់ខ្លួនមកវិញ ឬជាមធ្យោបាយមួយសម្រាប់ធានាការសងកាតព្វកិច្ច[41]។ ដោយឡែកអនុប្បទាន សំដៅទៅលើការផ្ទេរសិទ្ធិ ឬទ្រព្យសម្បត្តិរបស់បុគ្គលណាម្នាក់ដែលជាអនុប្បទាយីទៅឱ្យបុគ្គលម្នាក់ទៀតដែលជាអនុប្បទានិក[42]។ ក្នុងន័យនេះ ប្រាតិភោគដោយអនុប្បទាន សំដៅទៅលើមធ្យោបាយមួយក្នុងការធានាការអនុវត្តកាតព្វកិច្ចរបស់កូនបំណុលទៅកាន់ម្ចាស់បំណុល ដោយតម្រូវឱ្យកូនបំណុល ឬតតិយជនធ្វើការប្រគល់ចលនវត្ថុទៅឱ្យម្ចាស់បំណុល ដើម្បីធានាការអនុវត្តកាតព្វកិច្ចរបស់ខ្លួន។

### ២.១.២. កម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

ផ្អែកតាមនិយមន័យនៃប្រាតិភោគដោយអនុប្បទាន ដែលកំណត់ក្នុងមាត្រា ៨៤៨ នៃក្រមរដ្ឋប្បវេណី វត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទានគឺចលនវត្ថុ ដូចទៅនឹងការបញ្ចាំចលនវត្ថុដែរ។ ចលនវត្ថុសំដៅទៅលើវត្ថុក្រៅពីអចលនវត្ថុ[43]។ ដែលមានន័យថា វត្ថុដែលអាចធ្វើការបម្លាស់ទីបាន ក្រៅពីដីធ្លី វត្ថុដែលនៅជាប់នឹងដី ដែលមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជាអគារ សំណង់ ដំណាំ រុក្ខជាតិ ជាអាទិ៍ គឺជាចលនវត្ថុ។

ចលនវត្ថុអាចត្រូវបានបែងចែកជា២ ប្រភេទបន្ថែមទៀតដែលរួមមានដូចជា:

-វត្ថុរូបិយ ជាចលនវត្ថុដែលអាចមើលឃើញ និងសម្គាល់បានដោយចក្ខុ ដែលមានដូចជា តុ ទូ កៅអី ទូរស័ព្ទ ឡាន ម៉ូតូ ជាដើម។

-វត្ថុអរូបិយ សំដៅទៅលើវត្ថុដែលមិនអាចមើលឃើញ មិនអាចប៉ះបាន ប៉ុន្តែគេអាចគ្រប់គ្រងវាបាន ដែលមានជាអាទិ៍ដូចជា ចរន្តអគ្គិសនី កម្តៅ ពន្លឺ ជាដើម។

នៅក្នុងប្រាតិភោគដោយអនុប្បទាន ចលនវត្ថុដែលយកមកធ្វើជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន

---

[40] មាត្រា ៨៤៨, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[41] សន្ធានុក្រមក្រមរដ្ឋប្បវេណី, លេខ ១០១។

[42] សន្ធានុក្រមក្រមរដ្ឋប្បវេណី, លេខ១៨៩។

[43] មាត្រា១២០ កថាខណ្ឌទី៣, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ក៏អាចយកចលនវត្ថុច្រើន មកធានាកាតព្វកិច្ចផងដែរ។ អនុលោមតាមមាត្រា ៨៤៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីបានបញ្ញត្តិថា ចលនវត្ថុច្រើនដែលត្រូវបានកំណត់ទំហំតាមមាត្រដ្ឋាន ដូចជាប្រភេទ ឬទីកន្លែងស្ថិតនៅនៃចលនវត្ថុ អាចយកមកធ្វើជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន ដោយចាត់ទុកថាជាចលនវត្ថុផ្តុំគ្នាតែមួយបាន ទោះបីជាចលនវត្ថុនីមួយៗដែលផ្តុំគ្នានោះ មានការប្រែប្រួលក៏ដោយ។

ជាលក្ខណៈពិសេសនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន វត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទានអាចជា ចលនវត្ថុជម្មតា ឬចលនវត្ថុផ្តុំគ្នា។

### ២.១.៣. ផលប្រយោជន៍នៃប្រព័ន្ធប្រាតិភោគដោយអនុប្បទាន

ចំពោះអចលនវត្ថុ មានហ៊ីប៉ូតែក ដែលត្រូវបានបង្កើតឡើងដើម្បីធានាកាតព្វកិច្ច ដោយមិនមានការផ្ទេរការកាន់កាប់ដោយចំពោះ នូវអចលនវត្ថុដែលជាកម្មវត្ថុនោះ។ ដោយឡែកចំពោះចលនវត្ថុវិញ គឺមានប្រាតិភោគដោយអនុប្បទាន។ ប្រាតិភោគដោយអនុប្បទាន គឺជាមធ្យោបាយធានាកាតព្វកិច្ចមួយដែលអនុញ្ញាតឱ្យកូនបំណុលអាចយកចលនវត្ថុរបស់ខ្លួនដើម្បីមកធានាកាតព្វកិច្ចរបស់ខ្លួន ក្នុងករណីដែលកូនបំណុលនោះគ្មានអចលនវត្ថុ ហើយកូនបំណុលពុំចាំបាច់ធ្វើការផ្ទេរការកាន់កាប់ដោយចំពោះនូវចលនវត្ថុនោះទៅកាន់ម្ចាស់បំណុលនោះទេ។ លើសពីនេះ ចលនវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទានអាចជា ចលនវត្ថុច្រើនជាងមួយផងដែរ ដែលត្រូវកំណត់ទៅតាមមាត្រដ្ឋានដូចជាប្រភេទ ឬទីកន្លែងដែលចលនវត្ថុនោះស្ថិតនៅជាដើម។ ការអនុញ្ញាតបែបនេះ គឺផ្តល់នូវផលប្រយោជន៍សម្រាប់កូនបំណុលជាខ្លាំង ដោយហេតុថាកូនបំណុលនៅតែកាន់កាប់ដោយចំពោះលើចលនវត្ថុនោះជាដដែល ដែលការណ៍នេះអនុញ្ញាតឱ្យកូនបំណុលអាចបន្តសកម្មភាពចាត់ចែងផ្សេងៗ និងអនុវត្តនូវសិទ្ធិផ្សេងៗ ទៅលើចលនវត្ថុនោះតាមសេចក្តីត្រូវការរបស់ខ្លួនបានជាធម្មតា និងអាចទាញយកផលប្រយោជន៍ផ្សេងៗ ពីចលនវត្ថុនោះបានដដែល។

### ២.១.៤. ភាគីនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

#### ២.១.៤.១. ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន

##### ក. រូបវន្តបុគ្គល

ដូចគ្នាទៅនឹងករណីនៃម្ចាស់សិទ្ធិលើការបញ្ចាំដែរ រូបវន្តបុគ្គល ក៏ជាម្ចាស់សិទ្ធិលើការបញ្ចាំដែរ ក្នុងករណីដែលមានការព្រមព្រៀងគ្នាក្នុងការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានឡើង ដែលរូបវន្តបុគ្គលនេះជាមនុស្សដែលមានជីវិត មានសាច់មានឈាម និងជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច។

##### ខ. នីតិបុគ្គល

នីតិបុគ្គល សំដៅទៅលើក្រុមមនុស្ស ឬមូលនិធិដែលមានបុគ្គលភាពគតិយុត្ត ហើយជាប្រធាននៃសិទ្ធិ

និងកាតព្វកិច្ច។ ដូចគ្នាទៅនឹងករណីនៃការបញ្ចាំចលនវត្ថុដែរ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ក៏អាចជានីតិបុគ្គលដែរ ក៏ប៉ុន្តែត្រូវមានអាជ្ញាបណ្ណដើម្បីប្រកបអាជីវកម្ម តាមការកំណត់ក្នុងប្រកាសរបស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៧ ។

លក្ខខណ្ឌនៃការផ្តល់អាជ្ញាបណ្ណដើម្បីប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទាន គឺប្រែប្រួលទៅតាមទំហំនៃអាជីវកម្មដែលកំណត់ជាអាជីវកម្មខ្នាតតូច ខ្នាតមធ្យម ឬខ្នាតធំ។

ចំពោះអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានខ្នាតមធ្យម ឬខ្នាតធំ លក្ខខណ្ឌនៃការផ្តល់អាជ្ញា-បណ្ណគឺដូចគ្នាជាមួយនឹងអាជីវកម្មទទួលបញ្ចាំដែរ។ រាល់ការប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬប្រាតិភោគដោយអនុប្បទានខ្នាតមធ្យម និងខ្នាតធំត្រូវមានអាជ្ញាបណ្ណពីក្រសួង។ ដើម្បីទទួលបានអាជ្ញាបណ្ណក្រុមហ៊ុន/សហគ្រាស ត្រូវដាក់ពាក្យស្នើសុំនៅនាយកដ្ឋាន ដោយបំពេញលក្ខខណ្ឌដូចខាងក្រោម៖

-ជានីតិបុគ្គលសញ្ជាតិខ្មែរ និងបានចុះបញ្ជីពាណិជ្ជកម្មស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា (ចំពោះអាជីវកម្មខ្នាតធំកម្រិត២ ត្រូវចុះបញ្ជីជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត)

-ត្រូវមានដើមទុនប្រកបអាជីវកម្មដូចមានចែងនៅក្នុងប្រការ៩ នៃប្រកាសនេះ

-ត្រូវតម្កល់ប្រាក់ធានាអាជីវកម្ម១០% នៃដើមទុន

-អ្នកកាន់កាប់អាជ្ញាបណ្ណត្រូវមានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រផ្សេងទៀតដែលទាក់ទងនឹងអាជីវកម្ម ឬមានបទពិសោធន៍ទាក់ទងទៅនឹងធុរកិច្ចស្រដៀងគ្នា ឬធ្លាប់បម្រើការងារផ្នែកនេះ។ ក្នុងករណីដែលអ្នកឈរឈ្មោះមិនមែនជាភាគហ៊ុននិក ត្រូវមានលិខិតបញ្ជាក់ពីក្រសួងពាណិជ្ជកម្ម។

-ត្រូវមានទីតាំងប្រកបអាជីវកម្មច្បាស់លាស់ដែលបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច។

លក្ខខណ្ឌលម្អិតសម្រាប់ការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្ម ត្រូវបានកំណត់ក្នុងពាក្យស្នើសុំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ដោយឡែកចំពោះ ការប្រកបអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានដែលមានខ្នាតតូច គឺត្រូវមានលិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្មពីមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត។ ដូចគ្នាទៅនឹងការស្នើសុំលិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្មទទួលបញ្ចាំខ្នាតតូច ស្របតាមប្រការ ៧ នៃប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន គឺក្រុមហ៊ុន ឬសហគ្រាសត្រូវដាក់ពាក្យស្នើសុំនៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត ដោយបំពេញលក្ខខណ្ឌដូចខាងក្រោម៖

-ជានីតិបុគ្គលសញ្ជាតិខ្មែរ និងបានចុះបញ្ជីពាណិជ្ជកម្មស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា

-ត្រូវមានដើមទុនប្រកបអាជីវកម្មដូចមានចែងនៅក្នុងប្រការ៩ នៃប្រកាសនេះ

-ត្រូវតម្កល់ប្រាក់ធានាអាជីវកម្ម១០% នៃដើមទុន

-អ្នកកាន់កាប់អាជ្ញាបណ្ណត្រូវមានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រផ្សេង ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬមានបទពិសោធន៍ទាក់ទងទៅនឹងធុរកិច្ចស្រដៀងគ្នា ឬធ្លាប់បម្រើការងារផ្នែកនេះ។ ករណីដែលអ្នកឈរឈ្មោះមិនមែនជាភាគហ៊ុននិក ត្រូវមានលិខិតបញ្ជាក់ពីក្រសួងពាណិជ្ជកម្ម។

លក្ខខណ្ឌលម្អិតសម្រាប់ការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្ម ត្រូវបានកំណត់ក្នុងពាក្យស្នើសុំរបស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត។

ចំពោះដើមទុនដែលកំណត់ថាអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន មួយស្ថិតនៅខ្នាតតូច ឬខ្នាតមធ្យម ឬខ្នាតធំ គឺត្រូវអនុលោមទៅតាមខ្នាតដែលកំណត់ដោយប្រការ៩ នៃប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ស្របតាមប្រការ៩ នៃប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើមទុនសម្រាប់ការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទាន ត្រូវបានកំណត់ដូចខាងក្រោម៖

-ខ្នាតតូច : ត្រូវមានដើមទុនចាប់ពី ២០ លានរៀល ដល់ ៤០ លានរៀល

-ខ្នាតមធ្យម : ត្រូវមានដើមទុនលើសពី ៤០ លានរៀល ដល់ ២០០ លានរៀល

-ខ្នាតធំ (កម្រិត១) : ត្រូវមានដើមទុនលើសពី ២០០ លានរៀល ដល់ ៨០០ លានរៀល

-ខ្នាតធំ (កម្រិត២) : ត្រូវមានដើមទុនលើសពី ៨០០ លានរៀលឡើងទៅ

រាល់ការបន្ថែម ឬបន្ថយដើមទុនអាជីវកម្មខាងលើ ត្រូវមានការអនុញ្ញាតពីក្រសួង ឬមន្ទីរជាមុន។

### ២.១.៤.២. អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន

ស្របតាមបញ្ញត្តិស្តីពីការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន គឺសិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវបានបង្កើតឡើងដោយការព្រមព្រៀងរវាងម្ចាស់បំណុល និងកូនបំណុល ឬតតិយជនដែលផ្តល់ចលនវត្ថុសម្រាប់ប្រាតិភោគដោយអនុប្បទាន។ កូនបំណុល ឬតតិយជនដែលយកចលនវត្ថុមកដាក់ជាប្រាតិភោគដោយអនុប្បទានត្រូវបានកំណត់ថា ជាអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន។ ដូចគ្នាទៅនឹងអ្នកបង្កើតសិទ្ធិលើការបញ្ចាំដែរ កូនបំណុល សំដៅទៅលើបុគ្គលដែលមានករណីយកិច្ច។ ដោយឡែកចំពោះតតិយជន សំដៅទៅលើជនទីបី ឬជនដែលមិនមែនជាភាគីក្នុងទំនាក់ទំនងគតិយុត្ត ជនដែលមិនមែនជាភាគីក្នុងរឿងក្តីរដ្ឋប្បវេណី។ ដូច្នេះជារួម កូនបំណុល ឬតតិយជនដែលយកចលនវត្ថុដាក់ជាប្រាតិភោគដោយអនុប្បទានហៅថា អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន។

## ២.២. ការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន

### ២.២.១. លក្ខខណ្ឌសុពលភាព

សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវបានបង្កើតឡើងដោយការព្រមព្រៀងរវាងម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន និងកូនបំណុល ឬតតិយជនដែលផ្តល់ចលនវត្ថុសម្រាប់ប្រាតិភោគដោយអនុប្បទាន[44]។ ក្នុងន័យនេះ ដើម្បីបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន គឺគូភាគីត្រូវបង្កើតឡើងតាមរយៈកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន។ កិច្ចសន្យានេះ គឺត្រូវបង្កើតឡើងទៅតាមបទបញ្ញត្តិស្តីពីការបង្កើតកិច្ចសន្យាដែរ ដែលត្រូវបានបង្កើតឡើងដោយ សំណើ និងស្ទីការត្រូវគ្នា ហើយភាគីនីមួយៗមានសមត្ថភាពបុគ្គល។ លើសពីនេះ ច្បាប់ពុំបានកំណត់ពីទម្រង់ការណាមួយជាក់លាក់នោះទេ ពោលគឺឱ្យតែម្ចាស់សិទ្ធិប្រាតិភោគ-ដោយអនុប្បទាន និងអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន មានឆន្ទៈត្រូវគ្នាក្នុងការបង្កើតប្រាតិភោគដោយអនុប្បទានឡើង នោះសិទ្ធិប្រាតិភោគដោយអនុប្បទាននឹងមានសុពលភាពដោយមិនចាំបាច់ធ្វើជាលិខិតយថាភូត លិខិតដែលមានកាលបរិច្ឆេទស្ថាពរ ឬលិខិតឯកជននោះទេ។

ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន និងអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន អាចធ្វើការកំណត់អំពីអត្រាការប្រាក់ នៅក្នុងសកម្មភាពបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានផងដែរ។ ចំពោះអត្រាការប្រាក់នៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ក៏ជាគ្នាជាមួយនឹងអត្រាការប្រាក់នៃការបញ្ចាំចលនវត្ថុផងដែរ ដែលបានបកស្រាយនៅក្នុងចំណុច **១.២.១.** ស្តីពីលក្ខខណ្ឌសុពលភាព នៃការបង្កើតការបញ្ចាំចលនវត្ថុ។

### ២.២.២. លក្ខខណ្ឌតតាំងនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

ជាការពិតសិទ្ធិប្រាតិភោគដោយអនុប្បទាន គឺជាសិទ្ធិប្រាតិភោគមួយដែលម្ចាស់សិទ្ធិលើបំណុលត្រូវបានធានានូវការទទួលបានការសងតាមរយៈការយកចលនវត្ថុមកធានា។ ប៉ុន្តែនៅក្នុងករណីខ្លះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាននឹងមិនអាចទទួលបានការសងនោះទេ ដោយហេតុថាអាចនឹងមានតតិយជនណាមួយ មានសិទ្ធិផ្សេងៗទៅលើចលនវត្ថុដែលជាកម្មវត្ថុនោះ ហើយតតិយជននោះត្រូវបានការពារដោយច្បាប់។ ដើម្បីសម្របសម្រួលក្នុងករណីនេះ ក្រមរដ្ឋប្បវេណីបានកំណត់អំពីលក្ខខណ្ឌតតាំងនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ដែលអនុញ្ញាតឱ្យម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចយកសិទ្ធិរបស់ខ្លួនទៅតតាំងនឹងតតិយជនបាន។ ស្របតាមក្រមរដ្ឋប្បវេណីបានបញ្ញត្តិថា ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចតតាំងសិទ្ធិប្រាតិភោគដោយអនុប្បទាននោះ ចំពោះតតិយជនបានឡើយ បើមិនបានទទួលការផ្ទេរការកាន់កាប់វត្ថុដែលជា

[44] មាត្រា ៨៨៩, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

កម្មវត្ថុ ដោយយោងតាមបញ្ញត្តិមាត្រា ២២៩ (ការផ្ទេរការកាន់កាប់) នៃក្រមនេះ[45]។ មានន័យថាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន នឹងអាចយកសិទ្ធិរបស់ខ្លួនទៅតតាំងនឹងតតិយជនបាន លុះត្រាតែខ្លួនបានទទួលការផ្ទេរការកាន់កាប់ទៅតាមទម្រង់ណាមួយ ក្នុងចំណោមទម្រង់ទាំង ៤ ស្របតាមមាត្រា ២២៩ នៃក្រមរដ្ឋប្បវេណី។

យោងតាមមាត្រា ២២៩ នៃក្រមរដ្ឋប្បវេណី ស្ដីពីការផ្ទេរការកាន់កាប់ គឺត្រូវបានបែងចែកជា ៤ ទម្រង់ និងដូចដែលបានបកស្រាយនៅក្នុងជំពូកទី១ ចំណុច ២.២.២. ស្ដីពីលក្ខខណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំ ដែលរួមមានដូចជា៖

-ការប្រគល់ដោយជាក់ស្ដែង សំដៅទៅលើការកាន់កាប់ត្រូវបានផ្ទេរដោយការប្រគល់វត្ថុកាន់កាប់។ ដែលមានន័យថា អនុប្បទាយីបានផ្ទេរវត្ថុដែលខ្លួនកំពុងកាន់កាប់ជាប់នឹងដៃ ទៅឱ្យអនុប្បទានិកដោយផ្ទាល់ ហើយអនុប្បទានិកបានទទួលដោយផ្ទាល់ផងដែរតាមរយៈការប្រគល់នេះ។

-ការប្ដូរលក្ខណៈនៃការកាន់កាប់ សំដៅទៅលើករណីដែលការកាន់កាប់ អាចត្រូវបានផ្ទេរតាមរយៈការព្រមព្រៀងរវាងគូភាគីតែប៉ុណ្ណោះ ដោយគ្មានការប្រគល់ដោយជាក់ស្ដែងនោះទេ។ ក្នុងករណីនេះ អនុប្បនិកនៃការកាន់កាប់ត្រូវទទួលការកាន់កាប់ដោយប្រយោលតាមរយៈអនុប្បទាយី។ មានន័យថាតាមរយៈការព្រមព្រៀងរវាងអនុប្បទាយី និងអនុប្បទានិក អនុប្បទាយីនៅតែកាន់កាប់ដោយចំពោះ ហើយអនុប្បទានិកជាអ្នកកាន់កាប់ដោយប្រយោល[46]។

-ការប្រគល់ដោយសង្ខេប សំដៅទៅលើករណី អ្នកដែលនឹងទទួលអនុប្បទាននូវការកាន់កាប់បានក្ដាប់ទុកវត្ថុកាន់កាប់ដោយចំពោះ តាមការប្រគល់ជាក់ស្ដែងស្រាប់ហើយ ហើយការកាន់កាប់អាចត្រូវបានផ្ទេរដោយការព្រមព្រៀងរវាងគូភាគីតែប៉ុណ្ណោះ។ ដោយសារហេតុនេះ អនុប្បទាយីនៃការកាន់កាប់ ត្រូវបាត់បង់ការកាន់កាប់ដោយប្រយោលដែលខ្លួនធ្លាប់មាន តាមរយៈអ្នកក្ដាប់ទុកវត្ថុកាន់កាប់។ មានន័យថា តាមរយៈការព្រមព្រៀងរវាងរវាងអនុប្បទាយី និងអ្នកក្ដាប់ទុកវត្ថុកាន់កាប់ អនុប្បទានយីត្រូវបាត់បង់សូម្បីតែការកាន់កាប់ដោយប្រយោលរបស់ខ្លួន។

-ការផ្ទេរការកាន់កាប់ដោយបញ្ជា សំដៅទៅលើការផ្ទេរការកាន់កាប់ ដែលអ្នកកាន់កាប់ដោយប្រយោលតាមរយៈអ្នកដទៃ អាចផ្ទេរការកាន់កាប់ទៅឱ្យតតិយជនបាន ដោយការព្រមព្រៀងជាមួយនឹងតតិយជន និងធ្វើការជូនដំណឹងអំពីហេតុនោះ ទៅឱ្យអ្នកកាន់កាប់ដោយចំពោះ ហើយតាមរយៈការជូនដំណឹងនេះ អ្នកកាន់កាប់

[45] មាត្រា ៨៩០, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[46] ក្រុមការងារនៃគ្រូបណ្ដុះបណ្ដាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្ដីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ២ ២០១៧, ៧២។

ដោយចំពោះ ត្រូវធ្វើការផ្ទេរការកាន់កាប់ទៅឱ្យតតិយជននោះ។

## ២.៣. អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

នៅក្រោយពេលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន និងអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន បានព្រមព្រៀងគ្នាក្នុងការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានហើយ នោះនឹងបង្កើតឱ្យមាននូវសិទ្ធិផ្សេងៗ និងកាតព្វកិច្ចរវាងម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន និងអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានដែលរួមមានដូចជា៖ **ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា** (២.៣.១) **អានុភាពចំពោះផល**(២.៣.២) **ឧបាទេសកម្មលើវត្ថុ** (២.៣.៣) **ការចាត់ចែងលើវត្ថុដែលជាកម្មវត្ថុ** (២.៣.៤) **ទំហំដែលមានអានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន** (២.៣.៥) ។

### ២.៣.១. ទំហំអានុភាពនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវបានបង្កើតឡើងដើម្បីធានាការសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល។ ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានារួមមាន ប្រាក់ដើម ការប្រាក់ ប្រាក់ធានាសំណងក្នុងករណីមិនគោរពកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន សោហ៊ុយដើម្បីថែរក្សាវត្ថុដែលជាកម្មវត្ថុ ព្រមទាំងសំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬវិការៈកំបាំងនៃវត្ថុដែលជាកម្មវត្ថុ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ក្នុងករណីដែលមានកំណត់ផ្សេង ក្នុងសកម្មភាពបង្កើតនោះ[47]។ មានន័យថា វត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន គឺធានាការសងចំពោះម្ចាស់សិទ្ធិលើបំណុលទៅលើប្រាក់ដើម ការប្រាក់ ប្រាក់ធានាសំណងក្នុងករណីមិនគោរពកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិប្រាតិ-ភោគដោយអនុប្បទាន សោហ៊ុយដើម្បីថែរក្សាវត្ថុដែលជាកម្មវត្ថុ ព្រមទាំងសំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬវិការៈកំបាំងនៃវត្ថុដែលជាកម្មវត្ថុជាដើម តាមរយៈការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន ដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចធ្វើលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុដែលជាកម្មវត្ថុជាស្ថាពរ ឬចាត់ចែងប្តូរជាប្រាក់ បាន។

### ២.៣.២. អានុភាពចំពោះផល

ក្នុងករណីដែលអ្នកបង្កើត ឬតតិយជនដែលបានទទួលបញ្ជាពីអ្នកបង្កើតនោះ កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ បញ្ញត្តិនៃមាត្រា ៨៩១ (ទំហំដែលមានអានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន) មិនត្រូវយកមកអនុវត្តចំពោះផលឡើយ។ ប៉ុន្តែបញ្ញត្តិនៃវាក្យខណ្ឌទី១ នេះមិនត្រូវយកមកអនុវត្តឡើយ នៅក្រោយពេលដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ទាមទារឱ្យប្រគល់វត្ថុដែលជាកម្មវត្ថុ ដោយយោងតាមបញ្ញត្តិនៃកថា

[47] មាត្រា ៨៩៦, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ខណ្ឌទី២ នៃមាត្រា ៨៩៨ (ការចាត់ចែងប្តូរជាប្រាក់ ឬអនុប្បទានស្ពាព) នៃក្រមនេះ[48]។ មានន័យថា ក្នុងករណីដែលអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ឬតតិយជនដែលបានទទួលបញ្ញាពីអ្នកបង្កើតនោះកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ អានុភាពមិនមានចំពោះផលឡើយ[49]។ ដែលក្នុងករណីនេះ អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ឬតតិយជនដែលបានទទួលបញ្ញាពីអ្នកបង្កើត គឺជាអ្នកមានសិទ្ធិនៅក្នុងការប្រើប្រាស់ ឬទាញយកផលប្រយោជន៍ផ្សេងៗពីចលនវត្ថុដែលជាកម្មវត្ថុ ពីព្រោះថាអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ឬតតិយជនដែលទទួលបញ្ញានោះ គឺជាអ្នកកាន់កាប់ដោយចំពោះទៅលើចលនវត្ថុនោះ។ ផ្ទុយទៅវិញ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន គឺគ្រាន់តែមានការកាន់កាប់ដោយប្រយោលតែប៉ុណ្ណោះ ហេតុដូច្នេះខ្លួនពុំមានសិទ្ធិក្នុងការប្រើប្រាស់ ឬអាស្រ័យផល ឬទាញយកអត្ថប្រយោជន៍ផ្សេងៗទៀត ពីវត្ថុនោះបាននោះឡើយ។

ប៉ុន្តែក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬតតិយជនដែលបានទទួលបញ្ញាពីម្ចាស់សិទ្ធិ បានកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ បញ្ញត្តិនៃមាត្រា-៨២២ (សិទ្ធិទទួលការសងពីផលដោយមានអាទិភាព) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះផលដែលកើតឡើងពីវត្ថុដែលជាកម្មវត្ថុនោះ[50]។ ក្នុងន័យនេះកាលបើម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬតតិយជនដែលបានទទួលបញ្ញាពីម្ចាស់សិទ្ធិជាអ្នកកាន់កាប់ដោយចំពោះ លើវត្ថុដែលជាកម្មវត្ថុ នោះផលដែលកើតចេញពីវត្ថុជាកម្មវត្ថុនោះ ត្រូវយកមកកាត់នឹងសិទ្ធិលើបំណុលរបស់ម្ចាស់សិទ្ធិ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតបាន។ ចំពោះវិធីនៃការកាត់សិទ្ធិលើបំណុលនេះគឺត្រូវកាត់ជាមួយនឹងការប្រាក់ជាមុនសិន ហើយប្រសិនបើមានសល់ត្រូវកាត់ជាមួយនឹងប្រាក់ដើម។

ផល ដែលកំណត់ដោយក្រមរដ្ឋប្បវេណី ត្រូវបានបែងចែកជា ២ ប្រភេទគឺ ផលស៊ីវិល និងផលធម្មជាតិ ដូចដែលបានបកស្រាយនៅក្នុងចំណុច **២.៣.២. អានុភាពចំពោះផល នៃការបញ្ចាំចលនវត្ថុ** ដែរ ដោយផលធម្មជាតិសំដៅទៅលើផលដែលកើតឡើងតាមសភាពធម្មជាតិ ហើយត្រូវបានធ្វើលទ្ធកម្មតាមវិធីប្រើធម្មតាដែលមានដូចជា ដំណាំផ្លែឈើ ជាដើម។ ដោយឡែកផលស៊ីវិល សំដៅទៅលើផលដែលជាថ្នូរនឹងការប្រើប្រាស់វត្ថុណាមួយដែលមានដូចជា ប្រាក់ថ្លៃឈ្នួល ការប្រាក់ ឬវត្ថុផ្សេងទៀតដែលទទួលបានជាថ្នូរចំពោះការប្រើប្រាស់វត្ថុដើម។

---

[48] មាត្រា៨៩២ កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[49] ក្រុមការងារនៃគ្រូបណ្ដុះបណ្ដាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ,សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ២, ២០១៧, ១៦១។

[50] មាត្រា៨៩២ កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

### ២.៣.៣. ឧបាទេសកម្មលើវត្ថុ

ឧបាទេសកម្ម សំដៅទៅលើឋានៈមួយ ដែលបុគ្គលម្នាក់ទទួលជំនួសបុគ្គលណាមួយតាមផ្លូវច្បាប់ (ឧបាទេសកម្មអាចសំដៅទៅលើវត្ថុផងដែរ)[51]។ នៅក្នុងករណីសិទ្ធិប្រាតិភោគដោយអនុប្បទាន ឧបាទេសកម្មអាចត្រូវបានបែងចែកទៅតាមវត្ថុដែលជាកម្មវត្ថុ ដែលរួមមានចលនវត្ថុធម្មតា និងចលនវត្ថុផ្ដុំគ្នា។

#### ២.៣.៣.១. ឧបាទេសកម្មលើវត្ថុដែលមិនមែនជាចលនវត្ថុផ្ដុំគ្នា

ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចអនុវត្តសិទ្ធិរបស់ខ្លួនបានចំពោះទឹកប្រាក់ ឬវត្ថុផ្សេងដែលអ្នកបង្កើតបានទទួល ដោយការលក់ ការបាត់បង់ ឬការខូចខាតនូវវត្ថុដែលជាកម្មវត្ថុ។ ប៉ុន្តែម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចអនុវត្តសិទ្ធិរបស់ខ្លួនបានឡើយ នៅក្រោយពេលដែលប្រាក់ត្រូវបានបង់ ឬវត្ថុផ្សេងទៀតត្រូវបានប្រគល់ទៅឲ្យអ្នកបង្កើត[52]។ ក្នុងករណីដែលអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន បានយកចលនវត្ថុមកបង្កើតប្រាតិភោគដោយអនុប្បទាន នោះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានជាគោលការណ៍គឺអាចមានសិទ្ធិទទួលជំនួសនូវទឹកប្រាក់ ឬវត្ថុផ្សេងទៀតដែលកូនបំណុលនឹងត្រូវទទួលបានពីចលនវត្ថុដែលជាកម្មវត្ថុ ដែលមានដូចជា ទឹកប្រាក់ ឬវត្ថុផ្សេងទៀត ដែលជាថ្នូរនឹងការលក់ ការបាត់បង់ ឬការខូចខាតផ្សេងៗ។ ប៉ុន្តែនៅក្នុងករណីដែល ទឹកប្រាក់ ឬវត្ថុផ្សេងទៀតត្រូវបានបាត់បង់ ឬត្រូវបានប្រគល់ទៅឱ្យអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានរួចរាល់ហើយនោះ នោះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានពុំអាចប្រើប្រាស់សិទ្ធិនៅក្នុងការធ្វើឧបាទេសកម្មដែលផ្ដល់ឱ្យដោយច្បាប់ នៅក្នុងការទទួលជំនួសនូវទឹកប្រាក់ ឬវត្ថុដែលជាថ្នូរនឹងការលក់ ការបាត់បង់ ឬការខូចខាតពីវត្ថុដែលជាកម្មវត្ថុនោះទេ។

ឧទាហរណ៍៖ **ក** បានយកទំនិញរបស់ខ្លួនទៅបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានជាមួយ **ខ** ។ ក្រោយមក **ក** បានលក់ទំនិញនោះទៅឱ្យ **គ** ។ ករណីនេះ **ក** គឺជាអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន **ខ** ជាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន។

ជាគោលការណ៍ **ខ** អាចធ្វើឧបាទេសកម្មលើប្រាក់ដែលជាថ្លៃទំនិញនោះពី **គ** បាន។ មានន័យថា **ខ** អាចទទួលប្រាក់ពី **គ** ដែលជាថ្នូរនឹងការលក់ទិញរវាង **ក** និង **គ** ជំនួស **ក** បាន តាមរយៈសិទ្ធិឧបាទេសកម្ម។ ប៉ុន្តែប្រសិនបើ ក្រោយពេលដែលប្រាក់ថ្លៃទំនិញនោះត្រូវបានប្រគល់ទៅឱ្យ **ក** រួចហើយ នោះ **ខ** ពុំអាចប្រើសិទ្ធិធ្វើឧបាទេសកម្មលើប្រាក់នោះទៀតទេ។

[51] សន្ទានុក្រមក្រមរដ្ឋប្បវេណី, លេខ២០៨។

[52] មាត្រា ៨៩៣ កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

#### ២.៣.៣.២. ឧបាទេសកម្មលើវត្ថុដែលជាចលនវត្ថុផុំគ្នា

ចលនវត្ថុផុំគ្នា ក៏អាចយកមកធ្វើជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទានផងដែរ។ ក៏ប៉ុន្តែស្រប តាមមាត្រា៨៩៣ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចធ្វើឧបាទេសកម្ម ទៅលើប្រាក់ដែលទទួលបានពីចលនវត្ថុផុំគ្នានោះបានទេ ដោយហេតុថា អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្ប-ទានមានគម្រោងនឹងលក់វត្ថុដែលជាកម្មវត្ថុនោះទៅឱ្យអ្នកដទៃ តាំងពីដំបូង។

ឧទាហរណ៍៖ **ក** បានយកទំនិញនៅក្នុងឃ្លាំងរបស់ខ្លួនដែលជាចលនវត្ថុផុំគ្នាដែលគ្រោងនឹងលក់ ទៅ បង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានជាមួយ **ខ** ។ នៅក្នុងករណីនេះ មិនថាទំនិញដែលទើបនឹងនាំចូល ឬទំនិញ ដែលបានលក់ចេញនោះទេ គឺទំនិញដែលនៅក្នុងឃ្លាំងនាពេលនេះត្រូវចាត់ទុកថាជាចលនវត្ថុផុំគ្នា។ ក្នុងទំនាក់ ទំនងនេះ **ក** ជាអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ហើយ **ខ** ជាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ។ ក្នុងករណីនេះ ប្រសិនបើ **ក** បានលក់ទំនិញទាំងនេះចេញ នោះ **ខ** ពុំអាចធ្វើឧបាទេសកម្មទៅលើប្រាក់ដែលបាន ទទួលពីការលក់ទំនិញនេះជំនួស **ក** បាននោះទេ។

### ២.៣.៤. ការចាត់ចែងវត្ថុដែលជាកម្មវត្ថុ

#### ២.៣.៤.១. ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន

#### ក. ករណីចលនវត្ថុធម្មតា

នៅក្នុងករណីចលនវត្ថុធម្មតា ដែលត្រូវបានយកមកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានស្រប តាមគោលគំនិតនៃសិទ្ធិប្រាតិភោគដោយអនុប្បទានគឺ អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ជាអ្នក កាន់កាប់ដោយចំពោះទៅលើចលនវត្ថុដែលជាកម្មវត្ថុ។ នៅក្នុងអំឡុងពេលដែលខ្លួនកំពុងកាន់កាប់ អ្នកបង្កើត សិទ្ធិប្រាតិភោគដោយអនុប្បទានអាចនឹងធ្វើការចាត់ចែងទៅលើវត្ថុដែលជាកម្មវត្ថុនោះដូចជា ការធ្វើអនុប្បទាន ឬ ការយកទៅដាក់ជាប្រាតិភោគផ្សេងៗជាកិច្ចធានា។ នៅក្នុងករណីនេះ ក្រមរដ្ឋប្បវេណីបានចែងនូវបទបញ្ញត្តិដើម្បី សម្របសម្រួលរវាងម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន និងតតិយជនដែលទទួលចលនវត្ថុដែលជាកម្មវត្ថុ ដោយសារការចាត់ចែងរបស់អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន។ បើអ្នកបង្កើតដែលបន្តការកាន់កាប់ ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាននៅក្រោយពេលបង្កើតសិទ្ធិនោះ បានធ្វើ អនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ឬបានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើវត្ថុនោះ ដើម្បីតតិយជន ប្រសិនបើតតិយជននោះបានបំពេញគ្រប់លក្ខខណ្ឌដែលបានកំណត់នៅក្នុងមាត្រា-១៩៣ (លទ្ធកម្មដោយសុចរិត នូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ តតិយជននោះអាចយកសិទ្ធិរបស់ខ្លួនទៅតតាំងចំពោះម្ចាស់សិទ្ធិប្រាតិភោគ

ដោយអនុប្បទានបាន[53]។ ស្របតាមមាត្រា ១៩៣ នៃក្រមរដ្ឋប្បវេណីបានបញ្ញត្តិថា អ្នកដែលបានទទួលនូវការផ្ទេរការកាន់កាប់នូវចលនវត្ថុដោយកិច្ចសន្យាអនុប្បទានកម្មសិទ្ធិដែលមានសុពលភាព ហើយដោយសុចរិត និងគ្មានកំហុស ត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុនោះ ទោះបីជាអនុប្បទាយីគ្មានកម្មសិទ្ធិលើចលនវត្ថុនោះក៏ដោយ។ នៅក្នុងន័យនេះតតិយជនដែលជាអនុប្បទានិក ឬជាម្ចាស់សិទ្ធិប្រាតិភោគផ្សេងៗ ប្រសិនបើខ្លួនជាជនសុចរិត ហើយគ្មានកំហុស នោះតតិយជននោះអាចយកសិទ្ធិរបស់ខ្លួនដែលមានចំពោះវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ទៅតតាំងជាមួយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបាន។

ឧទាហរណ៍៖ **ក** បានជំពាក់បំណុល **ខ** បន្ទាប់មក **ក** បានយកឡានរបស់ខ្លួនមកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានចំពោះ **ខ** ដោយ **ក** នៅតែបន្តការកាន់កាប់ដោយចំពោះនៅលើឡាននោះដដែល។ បន្ទាប់មក **ក** បានលក់ឡាននោះទៅឱ្យ **គ** ដែលមិនបានដឹងអំពីការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានលើឡាននោះទេ។ នៅក្នុងករណីនេះផ្អែកតាមលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ **គ** អាចយកកម្មសិទ្ធិរបស់ខ្លួនលើឡានដែលបានទទួលតាមរយៈការលក់ទិញ ទៅតតាំងចំពោះ **ខ** បាន។ ហើយក្នុងករណីនេះ **ខ** ពុំអាចអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទានលើឡាននោះបានទេ ប៉ុន្តែការកំណត់បែបនេះគឺបានធ្វើឱ្យបំពានសិទ្ធិ និងផលប្រយោជន៍របស់ **ខ** ដែលជាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានដែលមិនអាចអនុវត្តសិទ្ធិរបស់ខ្លួនបាននោះទេ។ តើមានវិធីណាដើម្បីការពារ **ខ** ពីការណ៍ដែល **គ** ធ្វើលទ្ធកម្មនូវកម្មវត្ថុ? ចំពោះវិធីដែលអាចធ្វើបាន គឺអាចជាការដាក់សញ្ញាសម្គាល់លើឡាននោះ ដើម្បីបង្ហាញថា ឡាននោះ ជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន។ តាមរយៈការធ្វើបែបនេះ **ខ** អាចធ្វើឱ្យតតិយជនដែលមានបំណងទិញរថយន្តនោះក្លាយជាជនទុច្ចរិត និងមានកំហុស[54]។

លើសពីនេះទៅទៀត នៅក្នុងករណីដែលមានអ្នកដទៃដែលទទួលបញ្ជាពីអ្នកបង្កើតបន្តការកាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន នៅក្រោយពេលបង្កើតសិទ្ធិនោះហើយ អ្នកបង្កើតបានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ឬបានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើវត្ថុ ដើម្បីតតិយជន ប្រសិនបើតតិយជននោះជាជនសុចរិត និងគ្មានកំហុសចំពោះការធ្វើអនុប្បទាននូវកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនោះ គឺតតិយជននោះអាចតតាំងជាមួយនឹងម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបាន។

### ខ. ករណីចលនវត្ថុផ្តុំគ្នា

ចំពោះចលនវត្ថុដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ នៃមាត្រា ៨៨៨ (និយមន័យនៃសិទ្ធិប្រាតិភោគ

[53] មាត្រា-៨៩៤ កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[54] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ២, ២០១៧, ១៦៣។

ដោយអនុប្បទាន) នៃក្រមនេះ ហើយដែលអ្នកបង្កើតមានគម្រោងនឹងលក់ចលនវត្ថុទៅជនដទៃ ក្នុងករណីដែលអ្នកបង្កើតបន្តការកាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ នៅក្រោយពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានបានលក់វត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានពុំអាចយកសិទ្ធិប្រាតិភោគដោយអនុប្បទាននោះ ទៅតតាំងចំពោះតតិយជននោះបានឡើយ ទោះបីជាតតិយជននោះបំពេញ ឬមិនបំពេញគ្រប់លក្ខខណ្ឌដែលបានកំណត់នៅក្នុងមាត្រា ១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះក៏ដោយ[55]។ ក្នុងន័យនេះ ចលនវត្ថុផ្គុំគ្នា ដែលត្រូវបានយកមកធ្វើជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទានគឺមានគោលបំណងក្នុងការលក់តាំងពីដំបូង ដូច្នេះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមិនអាចយកសិទ្ធិប្រាតិភោគដោយអនុប្បទាន ទៅតតាំងជាមួយនឹងតតិយជនដែលបានធ្វើលទ្ធកម្មលើចលនវត្ថុផ្គុំគ្នានោះបានឡើយ បើទោះបីជាតតិយជននោះមិនបានបំពេញលក្ខខណ្ឌនៃការធ្វើលទ្ធកម្មដោយសុចរិត និងគ្មានកំហុស ក៏ដោយ។

### ២.៣.៤.២. ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន

នៅក្នុងករណីខ្លះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ជាអ្នកកាន់កាប់ដោយចំពោះទៅលើវត្ថុដែលជាកម្មវត្ថុ ហើយអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ជាអ្នកកាន់កាប់ដោយប្រយោល។ នៅក្នុងករណីនេះស្របតាមមាត្រា ៨៩៧ នៃក្រមរដ្ឋប្បវេណី បានចែងថា បើម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានដែលកាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ បានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ឬបានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើវត្ថុនោះដើម្បីតតិយជន ប្រសិនបើតតិយជននោះបានបំពេញគ្រប់លក្ខខណ្ឌនៃលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ តតិយជននោះអាចយកសិទ្ធិរបស់ខ្លួនទៅតតាំងចំពោះអ្នកបង្កើតបាន។ ហើយនៅក្នុងករណីនេះអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានអាច ធ្វើការទាមទារសំណងពីម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបាន។ ផ្ទុយទៅវិញ ប្រសិនបើតតិយជនជាជនទុច្ចរិត និងមានកំហុសចំពោះការធ្វើលទ្ធកម្ម នោះអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានអាចទទួលបានមកវិញនូវចលនវត្ថុដែលជាកម្មវត្ថុនោះ។

លើសពីនេះ ចំពោះករណីដែលមានអ្នកដទៃទទួលបញ្ញាពីម្ចាស់សិទ្ធិប្រាតិភោគ កាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ ហើយម្ចាស់សិទ្ធិបានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ឬបានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើវត្ថុនោះដើម្បីតតិយជន ប្រសិនបើតតិយជននោះជាជនសុចរិត និងគ្មានកំហុសចំពោះការធ្វើលទ្ធកម្មនោះ នោះតតិយជននោះអាចយកសិទ្ធិរបស់ខ្លួនទៅតតាំងជាមួយនឹងអ្នកបង្កើតសិទ្ធិប្រាតិ-ភោគដោយអនុប្បទានបាន។

[55] មាត្រា-៨៩៤ កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

### ២.៣.៥. ទំហំដែលមានអានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

សិទ្ធិប្រាតិភោគដោយអនុប្បទាន មានអានុភាពលើវត្ថុដែលភ្ជាប់នឹងវត្ថុដែលជាកម្មវត្ថុ និងជាផ្នែកមួយនៃវត្ថុដែលជាកម្មវត្ថុនោះ នៅពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន។ អានុភាពនេះក៏កើតមានលើវត្ថុដែលត្រូវបានភ្ជាប់នៅក្រោយពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានផងដែរ[56]។ ក្នុងន័យនេះ វត្ថុដែលត្រូវបានភ្ជាប់ទៅនឹងវត្ថុដែលអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានយកមកធានាកាតព្វកិច្ចគឺ សិទ្ធិប្រាតិភោគដោយអនុ-ប្បទានក៏ត្រូវមានអានុភាពទៅលើវត្ថុនោះផងដែរ ទោះបីជាវត្ថុនោះត្រូវបានភ្ជាប់នៅមុនពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ឬត្រូវបានភ្ជាប់ក្រោយការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ក៏ដោយ។

ផ្ទុយទៅវិញ ស្របតាមមាត្រា ៨៩១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ភាគីនៃកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន អាចធ្វើការកំណត់ផ្សេងនៅក្នុងកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានបានផងដែរ។ ដែលមានន័យថា ភាគីនៃកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន អាចធ្វើការព្រមព្រៀងគ្នាដោយធ្វើការកំណត់ផ្សេងអំពីវត្ថុ ដែលត្រូវបានភ្ជាប់ទៅនឹងវត្ថុដែលជាកម្មវត្ថុដែលអាចជាការកំណត់ថា សិទ្ធិប្រាតិភោគដោយអនុប្បទាននឹងពុំមានអានុភាពទៅលើវត្ថុដែលត្រូវបានភ្ជាប់ទៅនឹងវត្ថុដែលជាកម្មវត្ថុនោះទេ ទោះបីជាវត្ថុនោះត្រូវបានភ្ជាប់នៅមុនពេល ឬក្រោយពេលនៃការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានក៏ដោយ ហើយអានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាននឹងមានអានុភាពទៅលើតែវត្ថុដែលជាកម្មវត្ថុតែប៉ុណ្ណោះ។

### ២.៣.៦. បញ្ញត្តិពិសេសនៅក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ

នៅក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន កាន់កាប់ទៅលើវត្ថុដែលជាកម្មវត្ថុដោយចំពោះ នោះក្រមរដ្ឋប្បវេណីបានចែងនូវបញ្ញត្តិពិសេស ដែលផ្តល់ឱ្យដល់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាននូវសិទ្ធិ និងករណីយកិច្ចមួយចំនួនបន្ថែមទៀត។ ស្របតាមមាត្រា ៨៩៦ ស្តីពីបញ្ញត្តិពិសេសក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានកាន់កាប់វត្ថុដែលជាកម្មវត្ថុ បានចែងថា បញ្ញត្តិនៃមាត្រា ៨២១ ស្តីពីអានុភាពនៃការឃាត់ទុក មាត្រា ៨២៣ ស្តីពីករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ និងមាត្រា ៨២៤ ស្តីពីសិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិលើការបញ្ចាំនៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬតតិយជនដែលបានទទួលបញ្ជាពីម្ចាស់សិទ្ធិនោះ កាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ។ មាត្រានេះចែងថា បញ្ញត្តិពីសិទ្ធិលើការបញ្ចាំ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន កាន់កាប់នូវវត្ថុដែលជាកម្មវត្ថុដោយចំពោះ ពីព្រោះទំនាក់ទំនង

[56] មាត្រា-៨៩១ កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

រវាងម្ចាស់សិទ្ធិ និងវត្ថុដែលជាកម្មវត្ថុ គឺស្រដៀងគ្នាទៅនឹងទំនាក់ទំនងរវាងម្ចាស់សិទ្ធិលើការបញ្ចាំ និងវត្ថុដែលជាកម្មវត្ថុ[57]។

ចំពោះអានុភាពនៃការឃាត់ទុក ត្រូវបានបកស្រាយនៅក្នុងចំណុច **២.៣.៦** ក្នុងផ្នែកអានុភាពនៃសិទ្ធិលើការបញ្ចាំ ករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ និងសិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវបានបកស្រាយនៅក្នុងចំណុច **២.៣.៤** ក្នុងផ្នែកអានុភាពនៃសិទ្ធិលើការបញ្ចាំ។

## ២.៤. ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន

កាលបើដល់កាលបរិច្ឆេទដែលត្រូវអនុវត្តកាតព្វកិច្ចសងមកដល់ តែម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមិនបានទទួលការសងពីអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន នោះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទានរបស់ខ្លួនដែលមានលើវត្ថុដែលជាកម្មវត្ថុនោះ។ ការការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាននេះ គឺម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចសម្រេចសិទ្ធិប្រាតិភោគជាឯកជន ដោយមិនចាំបាច់ពឹងពាក់តុលាការឡើយ[58]។

ស្របតាមមាត្រា-៨៩៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទានគឺមានវិធី២ យ៉ាង រួមមាន៖ ការចាត់ចែងប្តូរជាប្រាក់ និង អនុប្បទានស្ថាពរ។

### ២.៤.១. ការចាត់ចែងប្តូរជាប្រាក់

ការចាត់ចែងប្តូរជាប្រាក់ សំដៅទៅលើករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ធ្វើការចាត់ចែងវត្ថុដែលជាកម្មវត្ថុ ប្តូរមកជាប្រាក់ដោយខ្លួនឯងផ្ទាល់ ដោយគ្រាន់តែជូនដំណឹងទៅអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន។

ឧទាហរណ៍៖ **ក** បានយកទំនិញក្នុងឃ្លាំងរបស់ខ្លួន ទៅបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានជាមួយនឹង **ខ** ។ នៅក្នុងករណីដែលដល់កាលកំណត់សង **ក** មិនអនុវត្តកាតព្វកិច្ចក្នុងការសងប្រាក់ទេនោះ នោះ **ខ** អាចធ្វើការលក់ទំនិញរបស់ **ក** ដែលនៅក្នុងឃ្លាំងប្តូរជាប្រាក់ ដើម្បីទូទាត់នូវកាតព្វកិច្ចជាប្រាក់របស់ **ក** បានដោយគ្រាន់តែធ្វើការជូនដំណឹងទៅកាន់ **ក** ។

### ២.៤.២. ការធ្វើអនុប្បទានស្ថាពរ

ការធ្វើអនុប្បទានស្ថាពរ សំដៅទៅលើករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុ ដោយគ្រាន់តែជូនដំណឹងទៅកាន់អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន។

---

[57] មាត្រា៨៩៦, ក្រសួងយុត្តិធម៌, សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី, ២០១០។

[58] ក្រសួងយុត្តិធម៌, នៃសៀវភៅមេរៀន ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ទំព័រ២៧។

### ២.៤.៣. ករណីយកិច្ចបង់ទឹកប្រាក់ដែលលើស

នៅក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ (ការចាត់ចែងប្តូរជាប្រាក់ ឬអនុប្បទានស្ថាពរ) ខាងលើនេះ បើតម្លៃនៃវត្ថុដែលជាកម្មវត្ថុមានចំនួនលើសពីចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលត្រូវសង ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវបង់ចំនួនទឹកប្រាក់ដែលលើសនោះទៅឱ្យអ្នកបង្កើត ដោយចាត់ទុកថាជាប្រាក់ជម្រះ[59]។ មានន័យថា ទោះបីជាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបានប្រើប្រាស់វិធីណាក៏ដោយ ក៏ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវមានករណីយកិច្ចបង់ចំនួនទឹកប្រាក់ដែលលើស ដោយចាត់ទុកថាប្រាក់ជម្រះ ប្រសិនបើតម្លៃនៃវត្ថុមានចំនួនលើសទឹកប្រាក់នៃកាតព្វកិច្ចដែលត្រូវសង។

### ២.៤.៤. សិទ្ធិទទួលយកមកវិញរបស់អ្នកបង្កើត

ជាគោលការណ៍ បើដល់កាលបរិច្ឆេទសងហើយ ប៉ុន្តែមិនទាន់ទទួលបានសំណងទេនោះ ម្ចាស់សិទ្ធិ-ប្រាតិភោគដោយអនុប្បទានអាចប្រើជម្រើសណាមួយក៏បាន ដើម្បីអនុវត្ត ប៉ុន្តែបើអ្នកបង្កើតបានសង ទោះបីជានៅក្រោយពេលកំណត់សងក៏ដោយ ប៉ុន្តែនៅមុនពេលបង់ប្រាក់ដែលលើស ដែលម្ចាស់សិទ្ធិមានករណីយកិច្ចត្រូវបង់ទៅអ្នកបង្កើតសិទ្ធិ នោះកម្មសិទ្ធិត្រូវផ្ទេរទៅឱ្យអ្នកបង្កើតវិញ[60]។ មានន័យថា អ្នកបង្កើតសិទ្ធិ អាចទទួលយកមកវិញនូវកម្មសិទ្ធិលើវត្ថុដែលខ្លួនដាក់ធានានោះមកវិញ ទោះបីជាក្រោយពេលម្ចាស់សិទ្ធិអនុវត្តសិទ្ធិរបស់ខ្លួនរួចហើយក៏ដោយ ប៉ុន្តែអាចធ្វើទៅបានលុះត្រាតែធ្វើនៅមុនពេលបង់ប្រាក់ជម្រះ។

---

[59] មាត្រា-៨៩៨ កថាខណ្ឌទី៣, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[60] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ២, ២០១៧, ១៦៣។

# ជំពូកទី ៣

# ការប្រៀបធៀប

# លក្ខណៈដូចគ្នា និងលក្ខណៈខុសគ្នា

# នៃសិទ្ធិលើការបញ្ចាំចលនវត្ថុ

# និងសិទ្ធិប្រាតិភោគដោយអនុប្បទាន

# ជំពូកទី៣
# ការប្រៀបធៀបលក្ខណៈដូចគ្នា និងលក្ខណៈខុសគ្នានៃសិទ្ធិលើការបញ្ចាំចលនវត្ថុ និងសិទ្ធិប្រាតិភោគដោយអនុប្បទាន

## ៣.១. លក្ខណៈដូចគ្នា និងខុសគ្នា នៃការបង្កើតសិទ្ធិលើការបញ្ចាំចលនវត្ថុ និងសិទ្ធិប្រាតិ-ភោគដោយអនុប្បទាន

### ៣.១.១. លក្ខណៈដូចគ្នា និងខុសគ្នានៃលក្ខខណ្ឌសុពលភាព

លក្ខខណ្ឌសុពលភាពនៃសិទ្ធិលើការបញ្ចាំ និងលក្ខខណ្ឌសុពលភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទានគឺមានលក្ខណៈដូចគ្នាផង និងលក្ខណៈខុសគ្នាផង ដោយហេតុថា សិទ្ធិប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំអចលនវត្ថុ គឺមានកម្មវត្ថុជាចលនវត្ថុដូចគ្នា។

#### ៣.១.១.១ លក្ខណៈដូចគ្នានៃលក្ខខណ្ឌសុពលភាព

សិទ្ធិលើការបញ្ចាំចលនវត្ថុក្តី សិទ្ធិប្រាតិភោគដោយអនុប្បទានក្តី គឺសុទ្ធតែជាសិទ្ធិដែលត្រូវបានបង្កើតឡើងដើម្បីធានាកាតព្វកិច្ចរបស់កូនបំណុល ហើយកម្មវត្ថុនៃការធានានេះជាចលនវត្ថុដូចគ្នា រីឯសិទ្ធិទាំងពីរនេះត្រូវបានបង្កើតឡើងមានសុពលភាពតាមផ្លូវច្បាប់ ដោយគ្រាន់តែមានការព្រមព្រៀងគ្នាក្នុងការបង្កើតរវាងម្ចាស់សិទ្ធិ និងអ្នកបង្កើត យកនូវចលនវត្ថុមកធ្វើការធានាចំពោះម្ចាស់សិទ្ធិ នោះសិទ្ធិនេះនឹងត្រូវបានបង្កើតឡើង និងមានអានុភាពតាមផ្លូវច្បាប់។

ក្នុងន័យនេះគឺ លក្ខណៈដូចគ្នានៃលក្ខខណ្ឌសុពលភាពរវាងសិទ្ធិប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំចលនវត្ថុគឺត្រង់ការព្រមព្រៀងដើម្បីធ្វើការបង្កើត និងកម្មវត្ថុនៃការធានាដែលសំដៅដល់ចលនវត្ថុ ដូចគ្នា។

#### ៣.១.១.២. លក្ខណៈខុសគ្នានៃលក្ខខណ្ឌសុពលភាព

ដូចដែលបានបកស្រាយនៅក្នុងចំណុច **៣.១.១.១** ខាងលើគឺ សិទ្ធិប្រាតិភោគដោយអនុប្បទានក្តី ការបញ្ចាំចលនវត្ថុក្តី គឺសុទ្ធតែត្រូវបានឱ្យមានសុពលភាពតាមផ្លូវច្បាប់ ដោយគ្រាន់តែមានការព្រមព្រៀងរវាងគូភាគីដោយភ្ជាប់ជាមួយនូវចលនវត្ថុដើម្បីជាការធានាជាការស្រេច។

នៅក្នុងប្រព័ន្ធប្រាតិភោគដោយអនុប្បទាន គឺក្រមរដ្ឋប្បវេណីបានអនុញ្ញាតឱ្យមានការយកចលនវត្ថុផ្តុំគ្នាមកធ្វើជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទានបាន ដោយឡែកនៅក្នុងប្រព័ន្ធនៃការបញ្ចាំចលនវត្ថុ គឺពុំមានបញ្ញត្តិយ៉ាងដូច្នេះនោះទេ ដែលនេះជាលក្ខណៈប្លែកគ្នារវាងសិទ្ធិប្រាតិភោគដោយអនុប្បទាន និងសិទ្ធិលើការបញ្ចាំដែលមានកម្មវត្ថុជាចលនវត្ថុ។ មានន័យថាក្នុងប្រព័ន្ធនៃការបញ្ចាំចលនវត្ថុ គឺចលនវត្ថុដែលអាចយកមកធ្វើជាកម្មវត្ថុនៃការបញ្ចាំគឺជាចលនវត្ថុធម្មតា ដោយឡែកនៅក្នុងប្រព័ន្ធនៃសិទ្ធិប្រាតិភោគដោយអនុប្បទានគឺ

ចលនវត្ថុដែលអាចយកមកធ្វើជាកម្មវត្ថុរួមមាន ចលនវត្ថុធម្មតាផង និងចលនវត្ថុផ្គុំគ្នាផង។

អនុលោមទៅតាមមាត្រា ៨៤៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី បានបញ្ញត្តិថា ចលនវត្ថុច្រើន ដែលត្រូវបានកំណត់ទំហំតាមមាត្រដ្ឋាន ដូចជាប្រភេទ ឬកន្លែងស្ថិតនៅនៃចលនវត្ថុ អាចយកមកធ្វើជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ដោយចាត់ទុកជាចលនវត្ថុផ្គុំគ្នាតែមួយបាន ទោះបីជាចលនវត្ថុនីមួយៗដែលផ្គុំគ្នានោះ មានការប្រែប្រួលក៏ដោយ។ ស្របតាមមាត្រានេះ គឺបញ្ជាក់យ៉ាងច្បាស់ថា ចលនវត្ថុផ្គុំគ្នាក៏អាចយកមកធ្វើជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទានបានដែរ។ ដោយហេតុថាសិទ្ធិប្រាតិភោគដោយអនុប្បទាននេះ គឺត្រូវបានបង្កើតឡើងដោយមិនមានការផ្ទេរការកាន់កាប់ដោយចំពោះនោះទេ។

## ៣.១.២. លក្ខណៈដូចគ្នា និងខុសគ្នានៃលក្ខខណ្ឌតតាំង

លក្ខខណ្ឌតតាំង ជាលក្ខខណ្ឌដ៏សំខាន់មួយដែលអនុញ្ញាតឱ្យគូភាគីនៃទំនាក់ទំនងសិទ្ធិលើការបញ្ចាំ ឬសិទ្ធិប្រាតិភោគដោយអនុប្បទាន ជាពិសេសសម្រាប់ម្ចាស់សិទ្ធិអាចយកអានុភាពនៃសិទ្ធិនេះទៅអះអាងជាមួយនឹងតតិយជន ដែលនៅក្រៅទំនាក់ទំនងគតិយុត្តនេះ។ លក្ខខណ្ឌតតាំងនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន និងលក្ខខណ្ឌតតាំងនៃការបញ្ចាំចលនវត្ថុគឺមានលក្ខណៈដូចគ្នាផង និងលក្ខណៈប្លែកគ្នាផង បើទោះបីជាប្រព័ន្ធទាំងពីរនេះមានកម្មវត្ថុជាចលនវត្ថុដូចគ្នាក្តី។

### ៣.១.២.១. លក្ខណៈដូចគ្នានៃលក្ខខណ្ឌតតាំង

ដើម្បីឱ្យម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ ក៏ដូចជាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចតតាំងជាមួយនឹងតតិយជនបានលុះត្រា តែខ្លួនបានទទួលការផ្ទេរការកាន់កាប់វត្ថុនោះ។ ចំពោះទម្រង់នៃការផ្ទេរការកាន់កាប់ដែលកំណត់ដោយក្រមរដ្ឋប្បវេណីចំពោះសិទ្ធិនីមួយៗ ក៏ដូចជាលក្ខណៈប្លែកគ្នារវាងសិទ្ធិទាំងពីរនេះដែរ គឺនឹងធ្វើការបកស្រាយនៅក្នុងចំណុច **៣.១.២.២.** ខាងក្រោម។

### ៣.១.២.២. លក្ខណៈខុសគ្នានៃលក្ខខណ្ឌតតាំង

អនុលោមតាមមាត្រា ៨២៩ នៃក្រមរដ្ឋប្បវេណី បានចែងថា ម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ មិនអាចតតាំងសិទ្ធិលើការបញ្ចាំនោះចំពោះតតិយជនបានឡើយ ប្រសិនបើខ្លួនមិនបានកាន់កាប់ជានិរន្តន៍នូវវត្ថុបញ្ចាំនោះ។ ផ្ទុយទៅវិញយោងតាមមាត្រា ៨៩០ នៃក្រមរដ្ឋប្បវេណី បានបញ្ញត្តិថា ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចតតាំងសិទ្ធិប្រាតិភោគដោយអនុប្បទាននោះ ចំពោះតតិយជនក្រៅពីអ្នកបង្កើតបានឡើយ បើមិនបានទទួលការផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុ ដោយយោងតាមបញ្ញត្តិនៃមាត្រា ២២៩ ស្តីពីការផ្ទេរការកាន់កាប់។

តាមស្មារតីនៃមាត្រាទាំង២ នេះ និងស្របតាមការបកស្រាយនៅក្នុងចំណុច **១.២.២.** ស្តីពីលក្ខខណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំចលនវត្ថុ និងចំណុច **២.២.២.** ស្តីពីលក្ខខណ្ឌតតាំងនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន គឺលក្ខណៈ

ខុសគ្នារវាងលក្ខខណ្ឌតតាំងនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន និងលក្ខខណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំចលនវត្ថុ គឺនៅត្រង់ថា

-លក្ខខណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំចលនវត្ថុ គឺដើម្បីឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ អាចតតាំងជាមួយនឹងតតិយជនបាន លុះត្រាតែម្ចាស់សិទ្ធិបានទទួលការផ្ទេរការកាន់កាប់តាមទម្រង់នៃការប្រគល់ដោយជាក់ស្តែងមួយតែប៉ុណ្ណោះ ដើម្បីឱ្យខ្លួនអាចធ្វើការកាន់កាប់ជានិរន្តន៍លើចលនវត្ថុដែលជាកម្មវត្ថុនោះ។

-លក្ខខណ្ឌតតាំងនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន គឺដើម្បីឱ្យម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចតតាំងជាមួយនឹងតតិយជនបាន លុះត្រាតែម្ចាស់សិទ្ធិបានទទួលការផ្ទេរការកាន់កាប់តាមមាត្រា ២២៩ នៃក្រមរដ្ឋប្បវេណី គឺទម្រង់នៃការផ្ទេរការកាន់កាប់គឺមានរហូតដល់ទៅ៤ ទម្រង់ដូចជា ការប្រគល់ដោយជាក់ស្តែង ការប្តូរលក្ខណៈនៃការកាន់កាប់ ការប្រគល់ដោយសង្ខេប និងការផ្ទេរកាន់កាប់ដោយបញ្ជា។ មានន័យថា ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចយកសិទ្ធិរបស់ខ្លួនទៅតតាំងជាមួយនឹងតតិយជនបាន ដោយគ្រាន់តែខ្លួនបានទទួលនូវការផ្ទេរការកាន់កាប់តាមទម្រង់ណាមួយ ក្នុងចំណោមទម្រង់នៃការផ្ទេរការកាន់កាប់ទាំង៤ នេះ។ ដែលនេះជាលក្ខណៈប្លែកយ៉ាងខ្លាំងរវាងលក្ខខណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំចលនវត្ថុ និងលក្ខខណ្ឌតតាំងនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន។

## ៣.២. លក្ខណៈដូចគ្នាទាំងស្រុង រវាងអានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំចលនវត្ថុ

### ៣.២.១. កត្តាដែលនាំឱ្យមានអានុភាពដូចគ្នា

ស្របតាមមាត្រា ៨៩៦ នៃក្រមរដ្ឋប្បវេណី កត្តាដែលនាំឱ្យមានការអនុវត្តដូចគ្នា រវាងបញ្ញត្តិស្តីពីអានុភាពនៃសិទ្ធិលើការបញ្ចាំ និងសិទ្ធិប្រាតិភោគដោយអនុប្បទាន គឺនៅក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬតតិយជនដែលទទួលបញ្ជាពីម្ចាស់សិទ្ធិនោះ កាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ។ ក្នុងន័យនេះ ប្រសិនបើម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬតតិយជនដែលទទួលបញ្ជាពីម្ចាស់សិទ្ធិ ជាអ្នកក្តាប់ទុកនូវវត្ថុដែលជាកម្មវត្ថុនៅក្នុងដៃ នោះបញ្ញត្តិស្តីពីអានុភាពមួយចំនួនដែលទាក់ទងនឹងការបញ្ចាំចលនវត្ថុ គឺត្រូវបានយកមកប្រើប្រាស់នៅក្នុងករណីនេះដែរ។

### ៣.២.២. បញ្ញត្តិស្តីពីអានុភាពដែលត្រូវយកមកអនុវត្តដូចគ្នា

កាលបើម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬតតិយជនដែលបានទទួលបញ្ជាពីអ្នកបង្កើត បានកាន់កាប់នូវវត្ថុដែលជាកម្មវត្ថុដោយចំពោះ នោះស្របតាមមាត្រា ៨៩៦ នៃក្រមរដ្ឋប្បវេណី បញ្ញត្តិស្តីពីអានុភាពដែលត្រូវយកមកអនុវត្តដូចគ្នារួមមាន អានុភាពនៃការឃាត់ទុក ករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំក្នុងការរក្សា

ទុកនូវវត្ថុបញ្ចាំ និងសិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវយកមកអនុវត្ត។

ចំពោះអានុភាពនៃការឃាត់ទុក គឺនៅក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬតតិយជនដែលទទួលបញ្ជាពីម្ចាស់សិទ្ធិ ជាអ្នកកាន់កាប់លើវត្ថុដែលជាកម្មវត្ថុដោយផ្ទាល់ នោះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចធ្វើការឃាត់ទុកនូវវត្ថុដែលខ្លួនកាន់កាប់រហូតដល់ពេលដែលទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួន ក្នុងទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ដែលរួមមានដូចជា ប្រាក់ដើម ការប្រាក់ ប្រាក់ធានាសងក្នុងករណីដែលមិនអនុវត្តកិច្ចសន្យា សោហ៊ុយសម្រាប់អនុវត្តសិទ្ធិលើការបញ្ចាំ សោហ៊ុយដើម្បីថែរក្សាវត្ថុបញ្ចាំ ព្រមទាំងប្រាក់សំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ចផងដែរ។

ចំពោះករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំក្នុងការរក្សាទុកនូវវត្ថុបញ្ចាំ គឺបញ្ញត្តិនេះត្រូវយកមកអនុវត្តនៅក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬតតិយជនដែលបានទទួលបញ្ជាពីអ្នកបង្កើត បានកាន់កាប់លើវត្ថុដែលជាកម្មវត្ថុដោយចំពោះផងដែរ ដោយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានត្រូវមានករណីយកិច្ចកាន់កាប់លើវត្ថុបញ្ចាំដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត។ ការកាន់កាប់ដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត សំដៅទៅលើការណ៍ដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន បានគ្រប់គ្រង ថែរក្សាលើវត្ថុនោះ ហាក់បីដូចជាវត្ថុនោះជាកម្មសិទ្ធិរបស់ខ្លួន។

ចំពោះសិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ គឺក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិ-ភោគដោយអនុប្បទានបានកាន់កាប់ដោយចំពោះលើវត្ថុ ហើយនៅក្នុងអំឡុងពេលដែលខ្លួនបានកាន់កាប់ ម្ចាស់សិទ្ធិបានចំណាយសោហ៊ុយផ្សេងៗនៅក្នុងការគ្រប់គ្រង និងថែរក្សាទៅលើវត្ថុដែលជាកម្មវត្ថុនោះ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចធ្វើការទាមទារនូវសោហ៊ុយដែលខ្លួនបានចំណាយនោះ ពីកម្មសិទ្ធិករនៃវត្ថុនោះមកវិញបាន។

## ៣.៣. លក្ខណៈដូចគ្នា និងលក្ខណៈខុសគ្នា នៃអានុភាពសិទ្ធិប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំចលនវត្ថុ

សិទ្ធិលើការបញ្ចាំចលនវត្ថុត្រូវបានបង្កើតឡើងដោយអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ផ្ទេរការកាន់កាប់ដោយចំពោះទៅកាន់ម្ចាស់សិទ្ធិលើការបញ្ចាំ ដើម្បីឱ្យម្ចាស់សិទ្ធិលើការបញ្ចាំអាចយកការកាន់កាប់ជាប់ជានិរន្តន៍នេះទៅតតាំងជាមួយនឹងតតិយជនបាន។ ដោយឡែកចំពោះសិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវបានបង្កើតឡើងដោយអនុញ្ញាតឱ្យអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន និងម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចជ្រើសរើសទម្រង់នៃការផ្ទេរការកាន់កាប់ណាមួយក៏បាន ក្នុងចំណោមទម្រង់នៃការផ្ទេរការកាន់កាប់ទាំង៤។ អាស្រ័យហេតុនេះ នៅខណៈពេលដែលសិទ្ធិលើការបញ្ចាំចលនវត្ថុ និងសិទ្ធិប្រាតិភោគដោយអនុប្បទាននៅ

មានអត្ថិភាព គឺមានលក្ខណៈដូចគ្នា និងលក្ខណៈប្លែកគ្នាចំពោះអានុភាពនៃសិទ្ធិទាំង២នេះ។ នៅក្នុងនោះយើងអាចប្រៀបធៀបពីលក្ខណៈដូចគ្នា និងលក្ខណៈខុសគ្នានៃអានុភាពនៃសិទ្ធិទាំង២នេះទៅលើផល ការប្រើប្រាស់ និងការអនុវត្តសិទ្ធិ។

## ៣.៣.១. លក្ខណៈដូចគ្នា និងខុសគ្នាចំពោះផលនៃវត្ថុដែលជាកម្មវត្ថុ

### ៣.៣.១.១ លក្ខណៈដូចគ្នាចំពោះផលនៃវត្ថុដែលជាកម្មវត្ថុ

ជាការពិតណាស់ចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ក៏ដូចជាសិទ្ធិប្រាតិភោគដោយអនុប្បទានសុទ្ធតែអាចបង្កើតបានជាផល រួមមាន ផលស៊ីវិល និងផលធម្មជាតិ។ ចំពោះលក្ខណៈដូចគ្នានៃអានុភាពចំពោះផលដែលកើតចេញពីចលនវត្ថុដែលជាកម្មវត្ថុនៃការធានា គឺចង់សំដៅដល់សិទ្ធិដែលម្ចាស់សិទ្ធិលើការបញ្ចាំ ក៏ដូចជាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមានចំពោះផលនោះ។

លក្ខណៈដូចគ្នានេះគឺកើតឡើងនៅក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន បានកាន់កាប់លើចលនវត្ថុដែលជាកម្មវត្ថុដោយចំពោះ ក្នុងករណីនេះគឺ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាននឹងមានសិទ្ធិដូចទៅនឹងម្ចាស់សិទ្ធិលើការបញ្ចាំដែរ។ ដោយម្ចាស់សិទ្ធិលើការបញ្ចាំ និងម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានដែលបានកាន់កាប់ដោយចំពោះលើវត្ថុ អាចយកផលដែលកើតចេញពីចលនវត្ថុជាកម្មវត្ថុនោះមកកាត់នឹងសិទ្ធិលើបំណុលរបស់ខ្លួនដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតបាន។ ផលដែលបានទទួលនេះត្រូវយកមកកាត់ជាមួយនឹងការប្រាក់នៃសិទ្ធិលើបំណុលជាមុន ហើយប្រសិនបើមានសំណល់ត្រូវយកទៅកាត់ជាមួយនឹងប្រាក់ដើម។

### ៣.៣.១.២. លក្ខណៈខុសគ្នាចំពោះផលនៃវត្ថុដែលជាកម្មវត្ថុ

លក្ខណៈខុសគ្នាចំពោះផលដែលកើតចេញពីវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន និងសិទ្ធិលើការបញ្ចាំនេះ សំដៅដល់ករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមិនអាចទទួលផលបានដោយសារខ្លួនមិនបានកាន់កាប់លើចលនវត្ថុដែលជាកម្មវត្ថុនោះដោយចំពោះ។ នៅក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមិនបានកាន់កាប់លើចលនវត្ថុដែលជាកម្មវត្ថុយ៉ាងដូច្នេះ ផលដែលកើតចេញពីចលនវត្ថុនោះ នឹងត្រូវបានអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ឬតតិយជនដែលទទួលបញ្ជាពីអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ក្នុងនាមជាអ្នកកាន់កាប់លើវត្ថុដែលជាកម្មវត្ថុនោះ ជាអ្នកមានសិទ្ធិនៅក្នុងការប្រើប្រាស់ ឬទាញយកផលប្រយោជន៍ផ្សេងៗ ពីចលនវត្ថុដែលជាកម្មវត្ថុនោះ។ ដែលនេះជាលក្ខណៈខុសគ្នាជាមួយនឹងការបញ្ចាំចលនវត្ថុ ដោយម្ចាស់សិទ្ធិត្រូវតែជាអ្នកកាន់កាប់លើវត្ថុបញ្ចាំ នៅក្នុងអំឡុងពេលដែលសិទ្ធិលើការបញ្ចាំនោះមានអត្ថិភាព។

### ៣.៣.២. លក្ខណៈដូចគ្នា និងខុសគ្នាចំពោះការប្រើប្រាស់វត្ថុដែលជាកម្មវត្ថុ

#### ៣.៣.២.១. លក្ខណៈដូចគ្នា ចំពោះការប្រើប្រាស់វត្ថុដែលជាកម្មវត្ថុ

សិទ្ធិប្រាតិភោគដោយអនុប្បទាន និងសិទ្ធិលើការបញ្ចាំចលនវត្ថុ មានលក្ខណៈដូចគ្នានៅពេលដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន បានទទួលការកាន់កាប់ដោយចំពោះទៅលើចលនវត្ថុ នៅក្នុងករណីនេះ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានក្តី ម្ចាស់សិទ្ធិលើការបញ្ចាំក្តី ដើម្បីអាចធ្វើការប្រើប្រាស់នូវវត្ថុដែលជាកម្មវត្ថុនោះបាន លុះត្រាតែខ្លួនបានទទួលការយល់ព្រមពីអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ឬអ្នកបង្កើតសិទ្ធិលើការបញ្ចាំ។

#### ៣.៣.២.២. លក្ខណៈខុសគ្នាចំពោះការប្រើប្រាស់វត្ថុដែលជាកម្មវត្ថុ

នៅក្នុងករណីដែលអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ជាអ្នកបន្តការកាន់កាប់ដោយចំពោះ នោះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមិនអាចធ្វើការប្រើប្រាស់ទៅលើវត្ថុដែលជាកម្មវត្ថុបាននោះទេ ពីព្រោះថា វត្ថុដែលជាកម្មវត្ថុស្ថិតនៅការក្តាប់ទុករបស់អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន។ ផ្ទុយពីការបញ្ចាំចលនវត្ថុ ដែលម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ អាចធ្វើការប្រើប្រាស់ចលនវត្ថុបាន ដោយគ្រាន់តែទទួលការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ពីព្រោះថាវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំចលនវត្ថុ ស្ថិតនៅក្នុងការក្តាប់ទុករបស់ម្ចាស់សិទ្ធិលើការបញ្ចាំជានិច្ច។

### ៣.៤. លក្ខណៈដូចគ្នា និងខុសគ្នាចំពោះការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំចលនវត្ថុ

ការអនុវត្តសិទ្ធិលើការបញ្ចាំចលនវត្ថុក្តី ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទានក្តី គឺសុទ្ធតែមានគោលបំណងនៅក្នុងការយកវត្ថុដែលជាកម្មវត្ថុនោះ មកសងចំពោះកាតព្វកិច្ចរបស់កូនបំណុល នៅក្នុងករណីដែលបានដល់កាលកំណត់សង កូនបំណុលមិនព្រមអនុវត្តកាតព្វកិច្ច។ ការអនុវត្តសិទ្ធិលើការបញ្ចាំចំពោះចលនវត្ថុ និងការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន គឺមានលក្ខណៈដូចគ្នាផង និងមានលក្ខណៈប្លែកគ្នាផង ដោយហេតុថាកម្មវត្ថុនៃសិទ្ធិប្រាតិភោគទាំង២នេះជាចលនវត្ថុដូចគ្នា។

#### ៣.៤.១. លក្ខណៈដូចគ្នាចំពោះការអនុវត្ត

លក្ខណៈដូចគ្នាចំពោះការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន និងការអនុវត្តសិទ្ធិលើការបញ្ចាំចលនវត្ថុគឺមានលក្ខណៈដូចគ្នាចំពោះ ៖ ការសងត្រឡប់មកវិញនូវប្រាក់ដែលនៅសល់ក្រោយពីការអនុវត្តសិទ្ធិ ករណីដែលមានការសងដោយវត្ថុជំនួស។

ចំពោះ ការសងត្រលប់មកវិញនូវប្រាក់ដែលនៅសល់ក្រោយពីការអនុវត្តសិទ្ធិ គឺសំដៅដល់ការណ៍

ដែលចំនួនទឹកប្រាក់បានមកពីការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ លើសពីចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលត្រូវសងចំពោះម្ចាស់សិទ្ធិ នៅក្នុងករណីបែបនេះ ទោះបីជាការអនុវត្តសិទ្ធិប្រាតិភោគធ្វើតាមរយៈការអនុវត្តសិទ្ធិលើការបញ្ចាំក្តី ឬការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទានក្តី ក៏ចំនួនទឹកប្រាក់ដែលលើសនោះ ម្ចាស់សិទ្ធិលើការបញ្ចាំ ឬម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវមានករណីយកិច្ចសងទៅកាន់អ្នកបង្កើតសិទ្ធិវិញនូវចំនួនដែលលើសនោះ។

ករណីដែលមានការសងដោយវត្ថុជំនួសចំពោះសិទ្ធិលើការបញ្ចាំ ដើម្បីអាចឱ្យម្ចាស់សិទ្ធិធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុបញ្ចាំបានចាំបាច់ត្រូវតែឆ្លងកាត់នីតិវិធីតុលាការ។ ក៏ប៉ុន្តែក៏មានករណីខ្លះ អនុញ្ញាតឱ្យម្ចាស់សិទ្ធិលើការបញ្ចាំអាចធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុនោះ ដោយពុំចាំបាច់ពឹងពាក់តុលាការដែរ ដែលលក្ខណៈនេះគឺស្រដៀងទៅនឹងការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទានផងដែរ។ ករណីនេះសំដៅដល់ករណី ការសងដោយវត្ថុជំនួស។ ស្របតាមមាត្រា ៨៤២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីបានបញ្ញត្តិថា ក្នុងករណីដែលកូនបំណុលផ្តល់តាវកាលិកផ្សេងពីតាវកាលិកដែលជាបន្ទុកដើមរបស់ខ្លួនជំនួសវិញ ដោយទទួលការយល់ព្រមពីម្ចាស់បំណុល តាវកាលិកនោះមានអានុភាពដូចគ្នានឹងការសងដែរ មានន័យថា ប្រសិនបើក្រោយពេលកំណត់សងមកដល់ ភាគីអាចធ្វើការសងវត្ថុបញ្ចាំ តាមការព្រមព្រៀងបាន ដែលនេះជាការសងដោយវត្ថុជំនួស[61]។ តាមរយៈការសងដោយវត្ថុជំនួសនេះ ម្ចាស់សិទ្ធិលើការបញ្ចាំអាចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំបាន ដោយមិនចាំបាច់ឆ្លងកាត់តាមនីតិវិធីរបស់តុលាការនោះទេ នេះជាលក្ខណៈប្រហាក់ប្រហែលទៅនឹងការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទានដែរ ដែលម្ចាស់សិទ្ធិពុំចាំបាច់ពឹងពាក់តុលាការក្នុងការទទួលបាននូវកម្មសិទ្ធិលើវត្ថុជាកម្មវត្ថុនោះទេ។

### ៣.៤.២. លក្ខណៈខុសគ្នាចំពោះការអនុវត្ត

ចំណុចទាំងពីរនេះខុសគ្នាយ៉ាងខ្លាំងគឺត្រង់ នីតិវិធីនៃការអនុវត្តសិទ្ធិ ដើម្បីសម្រេចគោលបំណងនៃការសង។ ចំពោះនីតិវិធីនៃការអនុវត្តសិទ្ធិលើការបញ្ចាំចំពោះចលនវត្ថុ គឺដាច់ខាតត្រូវតែឆ្លងកាត់នីតិវិធីតាមផ្លូវតុលាការ ដោយឡែកចំពោះការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន គឺពុំចាំបាច់ឆ្លងកាត់នីតិវិធីតុលាការនោះទេ។

ការអនុវត្តសិទ្ធិលើការបញ្ចាំចំពោះចលនវត្ថុ ត្រូវតែឆ្លងកាត់នីតិវិធីតុលាការ ដើម្បីឱ្យម្ចាស់សិទ្ធិអាចទទួលបាននូវការសងពីវត្ថុដែលជាកម្មវត្ថុ ក្រោយកាលកំណត់សងបានមកដល់ ប៉ុន្តែអ្នកបង្កើតសិទ្ធិលើការបញ្ចាំ មិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ ការអនុវត្តនេះធ្វើឡើងតាមនីតិវិធីអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប

[61] ក្រសួងយុត្តិធម៌, សៀវភៅមេរៀនក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ៣, ១៧

ដែលមិនចាំបាច់ឆ្លងកាត់នីតិវិធីអនុវត្តដោយបង្ខំនោះទេ និងត្រូវអនុលោមទៅតាមក្រមនីតិវិធីរដ្ឋប្បវេណី។

ផ្ទុយទៅវិញ ចំពោះការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន មិនចាំបាច់ឆ្លងកាត់នីតិវិធីតុលាការនោះទេ។ កាលបើដល់កាលកំណត់សង អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនទេនោះ នោះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចចាត់ចែងប្តូរជាប្រាក់ ឬធ្វើអនុប្បទានស្ថាពរទៅលើវត្ថុដែលជាកម្មវត្ថុនោះ ដោយធ្វើការជូនដំណឹងអំពីការចាត់ចែងនេះទៅកាន់អ្នកបង្កើត និងពុំចាំបាច់ត្រូវឆ្លងកាត់នីតិវិធីតុលាការនោះទេ ពោលគឺម្ចាស់សិទ្ធិសម្រេចនូវការសង របស់ខ្លួនជាលក្ខណៈឯកជន។

# សេចក្តីសន្និដ្ឋាន

ជារួមមក សិទ្ធិប្រាតិភោគដោយអនុប្បទាននៅប្រទេសកម្ពុជាយើង គឺជាប្រភេទថ្មីមួយដែលទើបតែកើតមានឡើងក្រោយពេលដែលក្រមរដ្ឋប្បវេណីប្រកាសឱ្យប្រើនៅក្នុងឆ្នាំ២០០៧ និងមានអានុភាពអនុវត្តនៅឆ្នាំ២០១១ ដែលខុសប្លែកពីសិទ្ធិលើការបញ្ចាំចលនវត្ថុ ដែលមានវត្តមាននៅក្នុងប្រទេសកម្ពុជាអស់កាលជាយូរមកហើយ និងត្រូវបានប្រជាជនកម្ពុជាស្គាល់យ៉ាងជាក់ច្បាស់។ ក៏ប៉ុន្តែ ប្រព័ន្ធនៃសិទ្ធិប្រាតិភោគដោយអនុប្បទានក្តី ការបញ្ចាំចលនវត្ថុក្តី គឺសុទ្ធតែជាប្រព័ន្ធដែលមានគោលបំណងនៅក្នុងការសម្របសម្រួលដល់ការកម្ចីប្រាក់ដោយយកចលនវត្ថុ មកធ្វើការធានាដល់ម្ចាស់បំណុល និងត្រូវប្រព្រឹត្តទៅតាមការកំណត់របស់ច្បាប់។ បុគ្គលទាំងឡាយណាដែលមានគោលបំណងចង់បង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន គឺត្រូវតែបំពេញនូវលក្ខខណ្ឌជាមូលដ្ឋានមួយចំនួនដូចជា ការព្រមព្រៀងបង្កើត មានសមត្ថភាពបុគ្គល និងកម្មវត្ថុ។ ដោយឡែកចំពោះការបញ្ចាំវិញក៏មិនខុសគ្នាដែរ ពោលគឺដើម្បីបង្កើតកិច្ចសន្យាបញ្ចាំគឺត្រូវបំពេញនូវលក្ខខណ្ឌមូលដ្ឋានមួយចំនួនដែលរួមមាន ការព្រមព្រៀងបង្កើត មានសមត្ថភាពបុគ្គល និងកម្មវត្ថុ។ ដោយឡែកចំពោះលក្ខខណ្ឌទម្រង់នៃការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានក្តី ឬសិទ្ធិលើការបញ្ចាំចលនវត្ថុក្តី គឺមានលក្ខណៈដូចគ្នាផងដែរ ដោយក្រមរដ្ឋប្បវេណីមិនបានកំណត់អំពីលក្ខខណ្ឌទម្រង់ជាក់លាក់ដើម្បីឱ្យភាគីប្រតិបត្តិតាមនោះទេ ពោលគឺភាគីអាចធ្វើជាទម្រង់លិខិតឯកជនជាលាយលក្ខណ៍អក្សរ ឬត្រឹមការព្រមព្រៀងដោយផ្ទាល់មាត់ក៏បាន។ ប៉ុន្តែចំពោះលក្ខខណ្ឌតតាំងនៃសិទ្ធិដែលមានកម្មវត្ថុជាការធានាដោយចលនវត្ថុទាំងពីរនេះ គឺមានលក្ខណៈប្លែកគ្នាខ្លាំង ដោយហេតុថា ច្បាប់បានធ្វើការកំណត់ថា ចំពោះការបញ្ចាំចលនវត្ថុ ដើម្បីអាចឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ អាចតតាំងជាមួយនឹងតតិយជនបានលុះត្រាតែម្ចាស់សិទ្ធិលើការបញ្ចាំក្តាប់ទុកនូវវត្ថុបញ្ចាំនៅក្នុងដៃ តាមរយៈការប្រគល់ដោយជាក់ស្តែង។ ផ្ទុយទៅវិញ ចំពោះសិទ្ធិប្រាតិភោគដោយអនុប្បទានវិញ ដើម្បីអាចឱ្យម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចតតាំងជាមួយនឹងតតិយជនបាន លុះត្រាតែម្ចាស់សិទ្ធិបានទទួលការផ្ទេរការកាន់កាប់ណាមួយក្នុងចំណោមការផ្ទេរការកាន់កាប់ទាំងបួនទម្រង់ដូចជា ការប្រគល់ដោយជាក់ស្តែង ការប្តូរលក្ខណៈនៃការកាន់កាប់ ការប្រគល់ដោយសង្ខេប និងការផ្ទេរការកាន់កាប់ដោយបញ្ជា។ យ៉ាងណាមិញដោយហេតុថា សិទ្ធិប្រាតិភោគទាំងពីរនេះ មានកម្មវត្ថុនៃការធានាជាចលនវត្ថុដូចគ្នា ដូច្នេះនៅក្រោយពេលកិច្ចសន្យានៃការបង្កើតសិទ្ធិទាំងពីរនេះត្រូវបានបង្កើតឡើង នោះអានុភាពដែលកើតឡើងរវាងម្ចាស់បំណុលនិងកូនបំណុល គឺមានលក្ខណៈប្រហាក់ប្រហែលគ្នា នៅពេលដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានក្តាប់ទុកនូវចលនវត្ថុដែលជាកម្មវត្ថុនៅក្នុងដៃ ដូចទៅនឹងម្ចាស់សិទ្ធិលើការបញ្ចាំ ក៏ប៉ុន្តែលក្ខណៈប្លែកគ្នាខ្លាំងនៃសិទ្ធិទាំងពីរនេះគឺម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន មិនបានកាន់កាប់លើវត្ថុដែលជាកម្មវត្ថុដោយចំពោះឡើយ។

សរុបសេចក្តីមក យើងសង្កេតឃើញថាបទប្បញ្ញត្តិនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន គឺសិទ្ធិប្រាតិភោគប្រត្យក្សមួយ ដូចទៅនឹងការបញ្ចាំចលនវត្ថុដែរ ក៏ប៉ុន្តែ សិទ្ធិប្រាតិភោគដោយអនុប្បទាននេះ ជារបបគតិយុត្តថ្មីមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមិនទាន់មានការជ្រួតជ្រាបនៅក្នុងស្រទាប់សង្គមកម្ពុជាទូលំទូលាយនៅឡើយទេ ហើយសិទ្ធិប្រាតិភោគដោយអនុប្បទាន គឺមានចំណុចដែលរួមគ្នាជាមួយនឹងការបញ្ចាំចលនវត្ថុ ផង និងចំណុចដែលប្លែកគ្នាផង ដែលយើងនាំឱ្យមានការភាន់ច្រលំដោយងាយ ក៏ប៉ុន្តែ ប្រព័ន្ធនីមួយៗបង្កើតឱ្យមាននូវអត្ថប្រយោជន៍ចំពោះគូភាគីផ្សេងពីគ្នាផងដែរ។

# អនុសាសន៍

ប្រទេសកម្ពុជាធ្លាប់បានជួបប្រទះនូវសោកនាដកម្មយ៉ាងជូរចត់ ជាហេតុដែលបណ្តាលឱ្យឯកសារមួយចំនួនត្រូវបានបាត់បង់។ មិនត្រឹមតែប៉ុណ្ណោះ អ្នកប្រាជ្ញ អ្នកអក្សរសាស្ត្រ អ្នកវិទ្យាសាស្ត្រ និងសាស្ត្រាចារ្យដែលមានចំណេះដឹងទាំងឡាយក៏បានលាចាកលោកផងដែរ ដែលជាហេតុធ្វើឱ្យប្រទេសយើងមានការខ្វះខាតនូវឯកសារ ហើយក៏ជាហេតុដែលប្រទេសយើងបានទទួលជំនួយពីបរទេសដែរ។ ប្រព័ន្ធ និងអត្ថបទច្បាប់របស់ប្រទេសកម្ពុជាភាគច្រើនបានទទួលឥទ្ធិពលពីប្រទេស បារាំង និងជប៉ុន ដោយសារតែប្រទេសទាំងពីរនេះបានផ្តល់ជំនួយយ៉ាងច្រើនសន្ធឹកសន្ធាប់មកកម្ពុជា។ ដោយឡែកចំពោះប្រធានបទសារណាមួយនេះស្តីពីការប្រៀបធៀបសិទ្ធិប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំចលនវត្ថុ គឺជាប្រធានបទដែលបានដកស្រង់ចេញពីក្រមរដ្ឋប្បវេណី ដែលជាអត្ថបទច្បាប់ដែលមានប្រភពចេញពីប្រទេសជប៉ុន ដែលមានចំណុចមួយចំនួន មិនសូវជាស្របជាមួយនឹងបរិបទនៃប្រទេសកម្ពុជាយើងនោះឡើយ។

ហេតុដូចដែលបានរៀបរាប់ខាងលើនេះ ច្បាប់នៃព្រះរាជាណាចក្រកម្ពុជាបានយកនូវគោលគំនិតនៃបញ្ញត្តិស្តីពីប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំនៃច្បាប់របស់ប្រទេសជប៉ុន មកធ្វើការកែប្រែ ធ្វើយ៉ាងណាឱ្យមានលក្ខណៈសមស្របទៅនឹងបរិបទនៃប្រទេសកម្ពុជាយើង។ ទោះបីជាយ៉ាងណាក៏ដោយសារបញ្ញត្តិមួយនេះជាបញ្ញត្តិដែលមានលក្ខណៈថ្មីសម្រាប់ប្រជាពលរដ្ឋកម្ពុជា ជាហេតុនាំឱ្យវិសាលភាពនៃប្រាតិភោគ-ដោយអនុប្បទាន នៅមានភាពមិនទាន់ទូលំទូលាយ និងមិនទាន់គ្រប់ដណ្តប់គ្រប់ជ្រុងជ្រោយ ដែលខុសប្លែកពីសិទ្ធិលើការបញ្ចាំចលនវត្ថុ ជាបញ្ញត្តិដែលមានភាពទូលំទូលាយ និងការជ្រួតជ្រាបពីសំណាក់ប្រជាពលរដ្ឋខ្មែរបានច្រើនជាងប្រាតិភោគដោយអនុប្បទាន។ យ៉ាងណាមិញ សិទ្ធិប្រាតិភោគដោយអនុប្បទាន ក៏ជាប្រភេទមួយនៃសិទ្ធិប្រាតិភោគប្រត្យក្ស ដែលមានកម្មវត្ថុនៃការធានាជាចលនវត្ថុដូចទៅនឹងការបញ្ចាំចលនវត្ថុដែរ ក៏ប៉ុន្តែដោយហេតុថា ប្រជាពលរដ្ឋទូទៅ ក៏ដូចជាអ្នកដែលប្រកបអាជីវកម្មដែលពាក់ព័ន្ធ មិនសូវបានយល់ដឹងអំពីសិទ្ធិប្រាតិភោគប្រត្យក្សថ្មីនេះច្បាស់លាស់ និងបែងចែកឱ្យបានដាច់ស្រេចរវាងការបញ្ចាំចលនវត្ថុ និងប្រាតិភោគ-ដោយអនុប្បទាន ទើបបណ្តាលឱ្យការអនុវត្តសិទ្ធិទាំងពីរនេះនៅមានភាពខ្វះចន្លោះ និងតែងតែមានកំហុសខុសឆ្គងជារឿយៗ។

ឆ្លងតាមការសិក្សាស្រាវជ្រាវលើប្រធានបទនៃសារណានេះ យើងឃើញថា ប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំចលនវត្ថុគឺមានលក្ខណៈដូចគ្នាច្រើន និងមានចំណុចមួយចំនួនត្រូវយកបញ្ញត្តិស្តីពីការបញ្ចាំចលនវត្ថុមកអនុវត្តផងដែរ ក៏ប៉ុន្តែចំណុចដែលមានលក្ខណៈប្លែកគ្នានៅតែមាន និងអាចកត់សម្គាល់បាន។ ជាងនេះទៅទៀត សិទ្ធិប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំចលនវត្ថុ នៅមានចំណុចមួយចំនួនដែលមាន

ការខ្វះខាត ដែលនិស្សិត អ្នកសិក្សាស្រាវជ្រាវ អ្នកបំពេញវិជ្ជាជីវៈខាងផ្នែកច្បាប់ទាំងឡាយ គួរគប្បីយកចិត្តទុកដាក់ទៅលើបញ្ហាដែលចោទឡើង ជុំវិញសិទ្ធិប្រាតិភោគប្រត្យក្សទាំងពីរនេះ ដើម្បីបង្កជាភាពងាយស្រួលក្នុងការអនុវត្តទៅថ្ងៃក្រោយ និងជៀសឱ្យផុតពីបញ្ហាដែលនឹងអាចបង្កទៅជាវិវាទដែលនឹងអាចកើតមានដោយសារតែកត្តាខ្វះចន្លោះនេះ។

សរុបមកវិញ ជាអនុសាសន៍រួម ប្រទេសកម្ពុជាគប្បី ៖

១- ធ្វើការផ្សព្វផ្សាយពីបញ្ញត្តិ ដែលទាក់ទិននឹងសិទ្ធិប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំចលនវត្ថុ ក៏ដូចជាបង្ហាញនូវចំណុចដែលដូចគ្នា និងខុសគ្នានៃសិទ្ធិប្រាតិភោគប្រត្យក្សទាំងពីរនេះ ដើម្បីឱ្យប្រជាពលរដ្ឋក្នុងសង្គមមានការយល់ដឹងឱ្យកាន់តែបានច្បាស់លាស់ លម្អិត និងស៊ីជម្រៅ ក្នុងគោលដៅកាត់បន្ថយនូវការភាន់ច្រឡំ ក៏ដូចជា ការអនុវត្តខុសពីបញ្ញត្តិក្នុងច្បាប់ដែលអាចបណ្តាលឱ្យបង្កជាវិវាទ និងក្នុងគោលបំណងបញ្ចៀសនូវវិវាទ ដែលអាចកើតមានដោយសារតែការភាន់ច្រឡំ និងមិនមានការយល់ដឹងពីបញ្ញត្តិដែលពាក់ព័ន្ធបានច្បាស់លាស់។

២- ធ្វើការបំពេញបន្ថែម និងពង្រឹងនូវលក្ខខណ្ឌក្នុងការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំចលនវត្ថុ ដែលក្នុងន័យនេះ សំដៅទៅលើលក្ខខណ្ឌតតាំង ដោយហេតុថា ក្នុងការតតាំងនឹងតតិយជន ម្ចាស់សិទ្ធិនៅក្នុងរឿងប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំចលនវត្ថុ ពុំសូវជាទទួលបាននូវការធានាមួយដែលជាក់លាក់នោះទេ ពោលគឺក្នុងករណីមានភាគីច្រើន គឺនៅតែពុំអាចតតាំងជាមួយនឹងតតិយជនបានដដែល។ ដូចករណីដែលការកាន់កាប់វត្ថុនៅក្នុងដៃរបស់កូនបំណុល ម្ចាស់បំណុលហាក់ដូចជាមិនបានទទួលអ្វើជាការធានាទាល់តែសោះ ដែលការដាក់ប្រាតិភោគនេះពុំមានជាការចុះបញ្ជីអ្វីឡើយ។

ក្នុងពេលអនាគត ប្រសិនបើកម្ពុជាយើងអាចធ្វើការកែប្រែ ពង្រីក និងពង្រឹង នូវបទប្បញ្ញត្តិទាំងឡាយស្តីពីប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំចលនវត្ថុ និងអាចធ្វើការកែតម្រូវបន្ថែមដូចដែលបានលើកឡើងខាងលើ យើងខ្ញុំប្រាកដថា នីតិវិធីនៃប្រាតិភោគដោយអនុប្បទាននឹងមានភាពច្បាស់លាស់ និងទទួលបានការធានាកាន់តែប្រសើរ។ ម៉្យាងវិញទៀត ការកែតម្រូវទៅលើបញ្ញត្តិទាំងនេះនឹងអាចជួយសម្រួលដល់ការអនុវត្ត និងចំណេះដឹងរបស់ប្រជាពលរដ្ឋក្នុងសង្គម ក៏ដូចជាអាចកាត់បន្ថយនូវវិវាទកាន់តែច្រើនផងដែរ៕

# បញ្ជីឯកសារពិគ្រោះ


## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦

ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១

ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគ ដោយអនុប្បទាន, លេខ ០៣០ សហវ ប្រក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៧

## ឯកសារយោងជាស្លាដៃស្រាវជ្រាវ និងរៀបរៀងផ្សេងទៀត

ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ. ២០១៧. សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ២

គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការក្រសួងយុត្តិធម៌. ខែធ្នូ ឆ្នាំ២០១៥. មេរៀនស្តីពីក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី

គណៈកម្មការទទួលបន្ទុកសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រម រដ្ឋប្បវេណី. ២០១០. សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៤ គន្លឹទី៦

ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារ សេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី. ២០០៧. សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី

គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់. ២០០៧. សន្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី. ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី

## សៀវភៅមេរៀន

មេធាវី អ៊ីវ ប៉ូលី. ២១ ធ្នូ ២០១១. នីតិរដ្ឋប្បវេណី. មេរៀនសង្ខេប. គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

# ឧបសម្ព័ន្ធ

# ជំពូកទី ៤
# សិទ្ធិលើការបញ្ចាំ

## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ៨១៦.-** អត្ថន័យនៃសិទ្ធិលើការបញ្ចាំ

ម្ចាស់សិទ្ធិលើការបញ្ចាំ មានសិទ្ធិកាន់កាប់វត្ថុដែលបានទទួលពីកូនបំណុល ឬ តតិយជនដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន និង ទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនពីវត្ថុនោះ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត ។

**មាត្រា ៨១៧.-** ឧបាទេសកម្មលើវត្ថុ

១-សិទ្ធិលើការបញ្ចាំអាចអនុវត្តបានចំពោះទឹកប្រាក់ ឬ វត្ថុផ្សេងទៀតដែលអ្នកបង្កើតត្រូវទទួល ដោយការលក់ ការបាត់បង់ ឬ ការខូចខាតនូវវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ។ ប៉ុន្តែ ម្ចាស់សិទ្ធិលើការបញ្ចាំពុំអាចអនុវត្តសិទ្ធិរបស់ខ្លួនបានឡើយ នៅក្រោយពេលដែលទឹកប្រាក់ត្រូវបានបង់ ឬ វត្ថុផ្សេងត្រូវបានប្រគល់ ទៅឱ្យអ្នកបង្កើត ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះតម្លៃថ្នូរនឹងសិទ្ធិប្រត្យក្សដែលបង្កើតឡើង ដោយអ្នកបង្កើតសិទ្ធិលើការបញ្ចាំ លើវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ ។

**មាត្រា ៨១៨.-** ការបង្កើតសិទ្ធិលើការបញ្ចាំ និង ការប្រគល់វត្ថុជាចាំបាច់

១-សិទ្ធិលើការបញ្ចាំត្រូវកើតឡើង ដោយកូនបំណុល ឬ តតិយជនដែលបង្កើតសិទ្ធិលើការបញ្ចាំនោះ ប្រគល់នូវវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ។

២-ការប្រគល់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវរាប់បញ្ចូលទាំងការប្រគល់ដោយសង្ខេប ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រា ២២៩

(ការផ្ទេរការកាន់កាប់) នៃក្រមនេះ ។

**មាត្រា ៨១៩.-** ការហាមការកាន់កាប់ដោយផ្ទាល់ ដោយអ្នកបង្កើតសិទ្ធិលើការបញ្ចាំ

ម្ចាស់សិទ្ធិលើការបញ្ចាំមិនអាចឱ្យអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះកាន់កាប់ដោយផ្ទាល់លើវត្ថុបញ្ចាំនោះបានឡើយ ។

**មាត្រា ៨២០.-** ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

សិទ្ធិលើការបញ្ចាំត្រូវធានានូវ ប្រាក់ដើម ការប្រាក់ ប្រាក់ធានាសងក្នុងករណីមិនគោរពកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិលើការបញ្ចាំ សោហ៊ុយដើម្បីថែរក្សាវត្ថុបញ្ចាំ ព្រមទាំងសំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬ វិការៈកំបាំងនៃវត្ថុបញ្ចាំ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានកំណត់ផ្សេង ក្នុងសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំនោះ ។

**មាត្រា ៨២១.-** អានុភាពនៃការឃាត់ទុក

ម្ចាស់សិទ្ធិលើការបញ្ចាំអាចឃាត់ទុកវត្ថុបញ្ចាំបាន រហូតដល់ពេលដែលទទួលការសងចំពោះសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងមាត្រា ៨២០ (ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា) ខាងលើនេះ ។ ប៉ុន្តែ សិទ្ធិនេះមិនអាចតតាំង ចំពោះម្ចាស់បំណុលដែលមានអាទិភាពជាងខ្លួនបានឡើយ ។

**មាត្រា ៨២២.-** សិទ្ធិទទួលការសងពីផលដោយមានអាទិភាព

១-ម្ចាស់សិទ្ធិលើការបញ្ចាំអាចទទួលផលដែលកើតពីវត្ថុបញ្ចាំ និង អាចយកផលនោះមកកាត់សិទ្ធិលើបំណុលរបស់ខ្លួន ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតបាន ។

២-ផលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកកាត់ការប្រាក់នៃសិទ្ធិលើបំណុលជាមុនសិន ហើយ ប្រសិនបើមានសំណល់ ត្រូវយកទៅកាត់ប្រាក់ដើម ។

**មាត្រា ៨២៣.-** ករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំក្នុងការរក្សាទុកនូវវត្ថុបញ្ចាំ

១-ម្ចាស់សិទ្ធិលើការបញ្ចាំ ត្រូវកាន់កាប់វត្ថុបញ្ចាំនោះដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

២-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានធ្វើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ កូនបំណុលអាចទាមទាររំលត់សិទ្ធិលើការបញ្ចាំនោះបាន ។

**មាត្រា ៨២៤.-** សិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

១-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានចេញចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សាវត្ថុ ចំពោះវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះ អាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងនូវចំណាយនោះវិញបាន ។

២-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានចេញចំណាយបង្កើនតម្លៃនៃវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះអាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងនូវចំណាយទាំងអស់ដែលខ្លួនបានចេញ ឬ សងនូវតម្លៃប្រាក់ដែលកើននោះវិញ តាមការជ្រើសរើសរបស់ខ្លួនបាន ក្នុងករណីដែលកំណើនតម្លៃនោះនៅតែមាន ។ ប៉ុន្តែ តុលាការអាចកំណត់ពេលសមរម្យដើម្បីសង តាមការទាមទាររបស់កម្មសិទ្ធិករបាន ។

**មាត្រា ៨២៥.-** អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ការប្រើសិទ្ធិលើការបញ្ចាំ មិនរារាំងដំណើរការនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ ។

**មាត្រា ៨២៦.-** ការបញ្ចាំបន្ត

១-ម្ចាស់សិទ្ធិលើការបញ្ចាំអាចយកវត្ថុបញ្ចាំនោះទៅដាក់បញ្ចាំបន្តទៀតបាន ដោយទទួលការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះ ដើម្បីធានានូវកាតព្វកិច្ចរបស់ខ្លួន ។

២-ក្នុងអំឡុងពេលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំ ម្ចាស់សិទ្ធិនោះអាចយកវត្ថុបញ្ចាំនោះទៅដាក់បញ្ចាំបន្តទៀត ក្រោមការទទួលខុសត្រូវរបស់ខ្លួនបាន ។ ក្នុងករណី

នេះ ម្ចាស់សិទ្ធិលើការបញ្ចាំនោះក៏ត្រូវទទួលខុសត្រូវ ចំពោះការខូចខាតដោយប្រធានសក្តិដែលមិនអាចកើតមានឡើងប្រសិនបើមិនបានដាក់បញ្ចាំបន្តទេ ។

៣-នៅពេលចែកចំណែកថ្លៃលក់ដោយបង្ខំនៃវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំបន្តអាចទទួលនូវការសងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនទាំងអស់ ដោយមានកម្រិតនៃចំនួនទឹកប្រាក់ដែលត្រូវចែកចំណែកទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ។ ប៉ុន្តែ ប្រសិនបើសិទ្ធិលើបំណុលរបស់ខ្លួន មិនទាន់ដល់ពេលកំណត់ត្រូវសងទេ ម្ចាស់សិទ្ធិលើការបញ្ចាំបន្តគ្រាន់តែអាចទាមទារឱ្យតម្កល់នូវចំនួនទឹកប្រាក់ដែលខ្លួនអាចទទួលការសងបានប៉ុណ្ណោះ ។

**មាត្រា ៨២៧.–** ការហាមកិច្ចសន្យាបញ្ចាំផ្ដាច់

បើពុំមានបញ្ញត្តិពិសេសនៅក្នុងក្រមនេះ ឬ ច្បាប់ផ្សេងទៀតទេ អ្នកដែលបង្កើតសិទ្ធិលើការបញ្ចាំ មិនអាចព្រមព្រៀង ឱ្យម្ចាស់សិទ្ធិលើការបញ្ចាំទទួលកម្មសិទ្ធិលើវត្ថុបញ្ចាំ ឬ ចាត់ចែងវត្ថុបញ្ចាំ តាមវិធីផ្សេងពីវិធីដែលច្បាប់បានកំណត់ ដោយសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ ឬ ដោយកិច្ចសន្យាដែលធ្វើមុនកំណត់ពេលត្រូវសងបានទេ ។

**មាត្រា ៨២៨.–** សិទ្ធិទាមទារសំណងរបស់អ្នកធានាដោយវត្ថុ

ប្រសិនបើអ្នកដែលបង្កើតសិទ្ធិលើការបញ្ចាំដើម្បីធានាកាតព្វកិច្ចរបស់អ្នកដទៃ បានសងចំពោះកាតព្វកិច្ចនោះ ឬ បានបាត់បង់នូវកម្មសិទ្ធិលើវត្ថុបញ្ចាំ ដោយសារការអនុវត្តសិទ្ធិលើការបញ្ចាំនោះ អ្នកនោះត្រូវមានសិទ្ធិទាមទារសំណង ចំពោះកូនបំណុលដោយយោងទៅតាមបញ្ញត្តិស្ដីពីការធានា ។

## ផ្នែកទី ២
## ការបញ្ចាំចលនវត្ថុ

**មាត្រា ៨២៩.–** ល័ក្ខខ័ណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំ

ម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ មិនអាចតតាំងសិទ្ធិលើការបញ្ចាំនោះចំពោះតតិយ-

ជនបានឡើយ ប្រសិនបើខ្លួនមិនបានកាន់កាប់ជានិរន្តរ៍នូវវត្ថុបញ្ចាំនោះ ។

**មាត្រា ៨៣០.–** ករណីដែលការកាន់កាប់ត្រូវបានដកយក

ក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុត្រូវបានដកយកនូវការកាន់កាប់វត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះ អាចយកវត្ថុបញ្ចាំមកវិញបាន តាមរយៈបណ្ដឹងទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ តែប៉ុណ្ណោះ ។

**មាត្រា ៨៣១.–** ការប្រើប្រាស់ និង អាស្រ័យផលពីវត្ថុបញ្ចាំ ដោយម្ចាស់សិទ្ធិលើការបញ្ចាំ

១-បើពុំមានការយល់ព្រមពីសំណាក់កូនបំណុលទេ ម្ចាស់សិទ្ធិលើការបញ្ចាំ មិនអាចប្រើប្រាស់ ឬ ជួលវត្ថុបញ្ចាំបានឡើយ ។ ប៉ុន្តែ ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើប្រាស់បាន ត្រឹមតែកម្រិតដែលចាំបាច់ក្នុងការរក្សាវត្ថុបញ្ចាំនោះ ។

២-បើម្ចាស់សិទ្ធិលើការបញ្ចាំបានប្រព្រឹត្តផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ កូនបំណុលអាចទាមទារឱ្យរំលត់សិទ្ធិលើការបញ្ចាំបាន ។

**មាត្រា ៨៣២.–** ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប

១-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុមិនបានទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនទេ ម្ចាស់សិទ្ធិនោះអាចទាមទារទៅតុលាការឱ្យយកវត្ថុបញ្ចាំមកសងផ្ទាល់តែម្ដង តាមការវាយតម្លៃរបស់អ្នកវាយតម្លៃបាន លុះត្រាតែមានមូលហេតុត្រឹមត្រូវ ។ ក្នុងករណីនេះ ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវជូនដំណឹងអំពីការទាមទារនោះទៅកូនបំណុលជាមុន ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើចំនួនទឹកប្រាក់ដែលវាយតម្លៃដោយអ្នកវាយតម្លៃនោះ លើសពីចំនួននៃកាតព្វកិច្ចដែលត្រូវសងម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ ត្រូវសងនូវចំនួនទឹកប្រាក់ដែលនៅសល់ ទៅកម្មសិទ្ធិករនៃវត្ថុបញ្ចាំនោះវិញ ។

**មាត្រា ៨៣៣.-** លំដាប់នៃសិទ្ធិលើការបញ្ចាំចលនវត្ថុ

ក្នុងករណីដែលបានបង្កើតសិទ្ធិលើការបញ្ចាំលើចលនវត្ថុតែមួយ ដើម្បីធានាសិទ្ធិលើបំណុលច្រើន លំដាប់នៃសិទ្ធិលើការបញ្ចាំទាំងនោះត្រូវអនុលោមតាមពេលវេលាដែលបានបង្កើតនោះ ។

# ជំពូកទី ៦
# ប្រាតិភោគដោយអនុប្បទាន

## ផ្នែកទី ១
## និយមន័យនៃប្រាតិភោគដោយអនុប្បទាន

**មាត្រា ៨៨៨.-** និយមន័យនៃប្រាតិភោគដោយអនុប្បទាន

១-ប្រាតិភោគដោយអនុប្បទាន សំដៅទៅលើការណ៍ដែលកូនបំណុល ឬ តតិយជន ធ្វើអនុប្បទាននូវចលនវត្ថុរបស់ខ្លួនជាកំណត់ ទៅឱ្យម្ចាស់បំណុល ដើម្បីធានាកាតព្វកិច្ច ។ ក្នុងករណីនេះ បើកាតព្វកិច្ចត្រូវបានសងរួចហើយ កម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុ ត្រូវផ្ទេរទៅអ្នកបង្កើត ។

២-ចលនវត្ថុច្រើន ដែលត្រូវបានកំណត់ទំហំតាមមាត្រដ្ឋាន ដូចជាប្រភេទ ឬ កន្លែងស្ថិតនៅនៃចលនវត្ថុ អាចយកមកធ្វើជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ដោយចាត់ទុកជាចលនវត្ថុផ្តុំគ្នាតែមួយបាន ទោះបីជាចលនវត្ថុនីមួយៗដែលផ្តុំគ្នានោះ មានការប្រែប្រួលក៏ដោយ ។

## ផ្នែកទី ២
## ការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន

**មាត្រា ៨៨៩.-** ការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន

សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវបានបង្កើតឡើង ដោយការព្រមព្រៀងរវាង

ម្ចាស់បំណុល និង កូនបំណុល ឬ តតិយជន ដែលផ្តល់ចលនវត្ថុសម្រាប់ប្រាតិភោគដោយអនុប្បទាន ។

**មាត្រា ៨៩០.-** អានុភាពតតាំងនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចតតាំងសិទ្ធិប្រាតិភោគដោយអនុប្បទាននោះ ចំពោះតតិយជនក្រៅពីអ្នកបង្កើតបានឡើយ បើមិនបានទទួលការផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុ ដោយយោងតាមបញ្ញត្តិនៃមាត្រា ២២៩ (ការផ្ទេរការកាន់កាប់) នៃក្រមនេះទេ ។

## ផ្នែកទី ៣
## អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

**មាត្រា ៨៩១.-** ទំហំដែលមានអានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

១-សិទ្ធិប្រាតិភោគដោយអនុប្បទាន មានអានុភាពលើវត្ថុដែលភ្ជាប់នឹងវត្ថុដែលជាកម្មវត្ថុ និង ជាផ្នែកមួយនៃវត្ថុដែលជាកម្មវត្ថុនោះ នៅពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ។ អានុភាពនេះក៏មានលើវត្ថុដែលត្រូវបានភ្ជាប់នៅក្រោយពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានផងដែរ ។

២-ភាគីអាចកំណត់ផ្សេងពីបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបាន នៅក្នុងកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ។

**មាត្រា ៨៩២.-** អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទានចំពោះផល

១-ក្នុងករណីដែលអ្នកបង្កើត ឬ តតិយជនដែលបានទទួលការបញ្ជាពីអ្នកបង្កើតនោះ កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ បញ្ញត្តិនៃមាត្រា ៨៩១ (ទំហំដែលមានអានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន) ខាងលើនេះ មិនត្រូវយកមកអនុវត្តចំពោះផលឡើយ ។ ប៉ុន្តែ បញ្ញត្តិនៃវាក្យខណ្ឌទី ១ នេះមិនត្រូវយកមកអនុវត្តឡើយ នៅក្រោយពេលដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន បានទាមទារឱ្យប្រគល់វត្ថុដែលជាកម្មវត្ថុ

ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៨៩៨ (ការចាត់ចែងប្តូរជាប្រាក់ ឬ អនុប្បទានជាស្ថាពរ) នៃក្រមនេះ ។

២-ក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានទទួលការបញ្ជាពីម្ចាស់សិទ្ធិនោះ កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ បញ្ញត្តិនៃមាត្រា ៨២២ (សិទ្ធិទទួលការសងពីផលដោយមានអាទិភាព) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះផលដែលកើតឡើងពីវត្ថុដែលជាកម្មវត្ថុនោះ ។

**មាត្រា ៨៩៣.-** ឧបាទេសកម្មលើវត្ថុ

១-ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចអនុវត្តសិទ្ធិរបស់ខ្លួនបាន ចំពោះទឹកប្រាក់ ឬ វត្ថុផ្សេង ដែលអ្នកបង្កើតត្រូវទទួល ដោយការលក់ ការបាត់បង់ ឬ ការខូចខាតនូវវត្ថុដែលជាកម្មវត្ថុ ។ ប៉ុន្តែ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចអនុវត្តសិទ្ធិរបស់ខ្លួនបានឡើយ នៅក្រោយពេលដែលប្រាក់ត្រូវបានបង់ ឬ វត្ថុផ្សេងត្រូវបានប្រគល់ទៅឱ្យអ្នកបង្កើត ។

២-ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បើវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ជាចលនវត្ថុដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៨៨៨ (និយមន័យនៃប្រាតិភោគដោយអនុប្បទាន) នៃក្រមនេះ ហើយបើអ្នកបង្កើតមានគម្រោងនឹងលក់វត្ថុដែលជាកម្មវត្ថុនេះទៅជនដទៃ សិទ្ធិប្រាតិភោគដោយអនុប្បទានពុំអាចអនុវត្តចំពោះទឹកប្រាក់ដែលបានមកពីការលក់នោះឡើយ ។

**មាត្រា ៨៩៤.-** ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយអ្នកបង្កើត

១-បើអ្នកបង្កើតដែលបន្តការកាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន នៅក្រោយពេលបង្កើតសិទ្ធិនោះ បានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ឬ បានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើវត្ថុនោះដើម្បីតតិយជន ប្រសិនបើតតិយជននោះបំពេញគ្រប់ល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងមាត្រា ១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ តតិយជននោះអាចយកសិទ្ធិរបស់ខ្លួន ទៅតតាំងចំពោះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបាន ។

២-ចំពោះចលនវត្ថុដែលបានកំណត់នៅក្នុងកថាខណ្ឌទី២នៃមាត្រា៨៨៨ (និយមន័យនៃប្រាតិភោគដោយអនុប្បទាន) នៃក្រមនេះ ហើយដែលអ្នកបង្កើតមានគម្រោងនឹងលក់ទៅជនដទៃ ក្នុងករណីដែលអ្នកបង្កើតដែលបន្តការកាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ នៅក្រោយពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន បានលក់វត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចយកសិទ្ធិប្រាតិភោគដោយអនុប្បទាននោះ ទៅតតាំងចំពោះតតិយជននោះ បានឡើយ ទោះបីជាតតិយជននោះបំពេញ ឬ មិនបំពេញគ្រប់ល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងមាត្រា ១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ ក៏ដោយ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកដទៃដែលទទួលការបញ្ញាពីអ្នកបង្កើត បន្តការកាន់កាប់ដោយចំពោះ នូវវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន នៅក្រោយពេលបង្កើតសិទ្ធិនោះ ហើយអ្នកបង្កើតបានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ឬ បានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើវត្ថុនោះដើម្បីតតិយជន ។

**មាត្រា ៨៩៥.-** ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវធានានូវប្រាក់ដើម ការប្រាក់ ប្រាក់ធានាសងក្នុងករណីមិនគោរពកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន សោហ៊ុយដើម្បីថែរក្សាវត្ថុដែលជាកម្មវត្ថុ ព្រមទាំងសំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬ វិការៈកំបាំងនៃវត្ថុដែលជាកម្មវត្ថុ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានកំណត់ផ្សេង ក្នុងសកម្មភាពបង្កើតនោះ ។

**មាត្រា ៨៩៦.-** បញ្ញត្តិពិសេសក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន កាន់កាប់វត្ថុដែលជាកម្មវត្ថុ

បញ្ញត្តិនៃមាត្រា៨២១ (អានុភាពនៃការឃាត់ទុក) មាត្រា៨២៣ (ករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ញាំក្នុងការរក្សាទុកនូវវត្ថុបញ្ញាំ) និង មាត្រា ៨២៤ (សិទ្ធិទាមទារឱ្យសង

សោហ៊ុយរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានទទួលការបញ្ជាពីម្ចាស់សិទ្ធិនោះ កាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ ។

**មាត្រា ៨៩៧.-** ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន

១-បើម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានដែលកាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ បានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ឬ បានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើវត្ថុនោះដើម្បីតតិយជន ប្រសិនបើតតិយជននោះ បំពេញគ្រប់ល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងមាត្រា ១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ តតិយជននោះអាចយកសិទ្ធិរបស់ខ្លួន ទៅតតាំងចំពោះអ្នកបង្កើតបាន ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកដទៃដែលទទួលការបញ្ជាពីម្ចាស់សិទ្ធិប្រាតិភោគ កាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ ហើយម្ចាស់សិទ្ធិនោះបានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ឬ បានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើវត្ថុនោះដើម្បីតតិយជន ។

## ផ្នែកទី ៤
## ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន

**មាត្រា ៨៩៨.-** ការចាត់ចែងប្តូរជាប្រាក់ ឬ អនុប្បទានជាស្ថាពរ

១-បើកាតព្វកិច្ចពុំត្រូវបានអនុវត្ត ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចប្តូរវត្ថុដែលជាកម្មវត្ថុនោះជាប្រាក់ ដោយផ្ទាល់ខ្លួន ឬ ធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុជាស្ថាពរបាន ដោយជូនដំណឹងទៅអ្នកបង្កើត ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានទទួលការបញ្ជាពីអ្នកបង្កើតនេះ

កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចទាមទារឱ្យជននោះប្រគល់វត្ថុដែលជាកម្មវត្ថុនោះបាន ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើតម្លៃនៃវត្ថុដែលជាកម្មវត្ថុមានចំនួនលើសពីចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលត្រូវសង ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានត្រូវបង់ចំនួនទឹកប្រាក់ដែលលើសនោះ ទៅឱ្យអ្នកបង្កើត ដោយចាត់ជាប្រាក់ជម្រះ ។

**មាត្រា ៨៩៩.-** សិទ្ធិទទួលយកមកវិញរបស់អ្នកបង្កើត

ទោះបីជាពេលកំណត់ត្រូវសងកាតព្វកិច្ចបានកន្លងផុតក៏ដោយ ក៏អ្នកបង្កើតអាចទទួលយកមកវិញនូវវត្ថុដែលជាកម្មវត្ថុ ដោយផ្តល់នូវកាតព្វកិច្ចគ្រប់ចំនួន និង បង្ហាញអំពីការផ្តល់នោះទៅម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបាន នៅមុនពេលមានការផ្តល់ប្រាក់ជម្រះដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រា ៨៩៨ (ការចាត់ចែងប្តូរជាប្រាក់ ឬ អនុប្បទានជាស្ថាពរ) ខាងលើនេះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះករណីតម្លៃវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាននោះ មិនលើសពីចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលត្រូវសង ក្រោយពេលដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន បានជូនដំណឹងអំពីចំនួនដែលមិនលើសនោះ ទៅឱ្យអ្នកបង្កើតហើយ ។

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..០៣០.......សហវ..ប្រក

# ប្រកាស

## ស្តីពី

## ការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខនស/រកម/១២០៨/០២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤
- បានឃើញព្រះរាជក្រមលេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណីឆ្នាំ២០០៨
- បានឃើញអនុក្រឹត្យលេខ៤៨៨អនក្រ/បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ១៣៣០ សហវ.ប្រក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានក្រោមចំណុះអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងដូចខាងក្រោម÷

- ធានាប្រសិទ្ធភាពនៃការគ្រប់គ្រង និងការត្រួតពិនិត្យអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន
- ធានាសមធម៌ និងតុល្យភាពនៃផលប្រយោជន៍រវាងអ្នកដាក់បញ្ចាំ និងអ្នកទទួលទ្រព្យបញ្ចាំ
- បង្កើតឱ្យមានប្រព័ន្ធផ្គត់ផ្គង់សាច់ប្រាក់ឆាប់រហ័សដោយស្របច្បាប់ក្រៅពីប្រព័ន្ធធនាគារ
- រួមចំណែកទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានក្នុងវិស័យទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានដើម្បីធានានូវសន្តិសុខនិងសណ្តាប់ធ្នាប់សង្គម។

**ប្រការ២.-**

ប្រកាសនេះមានគោលដៅកំណត់ យន្តការ វិធាន និងនីតិវិធីនៃការគ្រប់គ្រង និងការត្រួតពិនិត្យប្រតិបត្តិការអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះសកម្មភាពពាក់ព័ន្ធនឹងអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយ-អនុប្បទាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.-**

ពាក្យបច្ចេកសព្ទដែលបានប្រើនៅក្នុងប្រកាសនេះត្រូវបានកំណត់ដូចខាងក្រោម÷

- **ក្រសួង** សំដៅដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- **អគ្គនាយកដ្ឋាន** សំដៅដល់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- **នាយកដ្ឋាន** សំដៅដល់នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុបញ្ចាំ និងប្រាតិភោគដោយអនុប្បទាននៃអគ្គ-នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- **មន្ទីរ** សំដៅដល់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត
- **អាជ្ញាបណ្ណ** សំដៅដល់លិខិតគតិយុត្តិដែលចេញដោយក្រសួង ដើម្បីអនុញ្ញាតឱ្យក្រុមហ៊ុន/សហគ្រាសណាមួយប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាននៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយស្របតាមលក្ខខណ្ឌដូចមានចែងក្នុងប្រកាសនេះ
- **លិខិតអនុញ្ញាតប្រកបអាជីវកម្ម** សំដៅដល់លិខិតដែលចេញដោយមន្ទីរ ដើម្បីអនុញ្ញាតឱ្យ ក្រុមហ៊ុន/សហគ្រាសណាមួយប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានខ្នាតតូចនៅក្នុងព្រះរាជាណា-ចក្រកម្ពុជាដោយស្របតាមលក្ខខណ្ឌដូចមានចែងក្នុងប្រកាសនេះ
- **អាជីវកម្មទទួលបញ្ចាំ** សំដៅដល់សកម្មភាពពាណិជ្ជកម្មដែលអតិថិជនយកទ្រព្យទៅដាក់បញ្ចាំ ដើម្បីទទួលបានប្រាក់កម្ចីដោយសន្យាថាទូទាត់សងប្រាក់ដើម និងការប្រាក់ទៅតាមកិច្ចសន្យាដែលបានកំណត់
- **អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន** សំដៅដល់សកម្មភាពពាណិជ្ជកម្មដែលអតិថិជនធ្វើអនុប្បទានសិទ្ធិលើចលនវត្ថុ របស់ខ្លួនជូនដល់អ្នកទទួលប្រាតិភោគដោយអនុប្បទាន ដើម្បីទទួលបានប្រាក់កម្ចីដោយសន្យាទូទាត់សងប្រាក់ដើម និងការប្រាក់ទៅតាមកិច្ចសន្យាដែលបានកំណត់
- **អ្នកទទួលបញ្ចាំ** សំដៅដល់នីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណ/ លិខិតអនុញ្ញាតប្រកបអាជីវកម្មទទួលទ្រព្យបញ្ចាំពីក្រសួង/ មន្ទីរ

- **អ្នកទទួលប្រាតិភោគដោយអនុប្បទាន** សំដៅដល់នីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណ/ លិខិតអនុញ្ញាតប្រកបអាជីវកម្មទទួលទ្រព្យប្រាតិភោគដោយអនុប្បទានពីក្រសួង/ មន្ទីរ
- **អ្នកដាក់បញ្ចាំ** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលយកទ្រព្យទៅដាក់បញ្ចាំជាមួយអ្នកទទួលបញ្ចាំ ដើម្បីទទួលបានប្រាក់កម្ចី
- **អ្នកដាក់ប្រាតិភោគដោយអនុប្បទាន** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលយកទ្រព្យទៅដាក់ប្រាតិភោគដោយ-អនុប្បទានជាមួយអ្នកទទួលប្រាតិភោគដោយអនុប្បទាន ដើម្បីទទួលបានប្រាក់កម្ចី
- **ទ្រព្យ** សំដៅដល់ចលនវត្ថុ ឬអចលនវត្ថុដែលជាកម្មវត្ថុយកទៅដាក់បញ្ចាំ
- **លោះ** សំដៅដល់ការទទួលយកមកវិញនូវទ្រព្យដែលបានដាក់បញ្ចាំ ឬដែលបានដាក់ប្រាតិភោគដោយអនុប្បទានក្រោយពីបានសងប្រាក់ដើម (ប្រាក់កម្ចី) និងការប្រាក់គ្រប់ចំនួនទៅតាមកិច្ចសន្យាដែលបានកំណត់ជូនទៅអ្នកទទួលបញ្ចាំ ឬអ្នកទទួលប្រាតិភោគដោយអនុប្បទានវិញ
- **កិច្ចសន្យា** សំដៅដល់កិច្ចសន្យាទទួលបញ្ចាំ ឬទទួលប្រាតិភោគដោយអនុប្បទានដែលធ្វើឡើងរវាងអ្នកដាក់បញ្ចាំ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទាន និងអ្នកទទួលបញ្ចាំ ឬអ្នកទទួលប្រាតិភោគដោយអនុប្បទាន។

## ជំពូកទី២
## ស្ថាប័នគ្រប់គ្រង

**ប្រការ៥.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាបញ្ញត្តិករក្នុងការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយ-អនុប្បទាន។ ក្រសួងមាននាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាននៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុជាសេនាធិការ។

មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត បំពេញតួនាទី និងភារកិច្ចសម្របសម្រួល និងគាំទ្រការងារគ្រប់គ្រង និងត្រួតពិនិត្យអាជីវកម្មទទួលបញ្ចាំ និង/ឬទទួលប្រាតិភោគដោយអនុប្បទានខ្នាតតូចនៅតាមរាជធានី-ខេត្ត ក្នុងនាមជាសេនាធិ-ការរបស់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៣
## អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មទទួលបញ្ចាំ និង/ឬ ទទួលប្រាតិភោគដោយអនុប្បទាន

**ប្រការ៦.-**

រាល់ការប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានខ្នាតមធ្យម និងខ្នាតធំត្រូវមានអាជ្ញាបណ្ណពីក្រសួង។ ដើម្បីទទួលបានអាជ្ញាបណ្ណក្រុមហ៊ុន/ សហគ្រាសត្រូវដាក់ពាក្យស្នើសុំទៅនាយកដ្ឋានដោយបំពេញលក្ខខណ្ឌដូចខាងក្រោម÷

- ជានីតិបុគ្គលសញ្ជាតិខ្មែរ និងបានចុះបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់នៅព្រះរាជាណាចក្រកម្ពុជា (ចំពោះអាជីវកម្មខ្នាតធំកម្រិត២ត្រូវចុះបញ្ជីជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត)
- ត្រូវមានដើមទុនប្រកបអាជីវកម្មដូចមានចែងក្នុងប្រការ៩ នៃប្រកាសនេះ
- ត្រូវតម្កល់ប្រាក់ធានាអាជីវកម្ម១០%នៃដើមទុន
- អ្នកកាន់អាជ្ញាបណ្ណត្រូវមានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រផ្សេងៗទៀតដែលទាក់ទងនឹងអាជីវកម្ម ឬមានបទពិសោធន៍ពាក់ព័ន្ធទៅនឹងធុរៈកិច្ចស្រដៀងគ្នា ឬធ្លាប់បម្រើការងារផ្នែកនេះ។ ក្នុងករណីអ្នកឈរឈ្មោះមិនមែនជាភាគហ៊ុននិកត្រូវមានលិខិតបញ្ជាក់ពីក្រសួងពាណិជ្ជកម្ម។

- ត្រូវមានទីតាំងប្រកបអាជីវកម្មច្បាស់លាស់ដែលបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច។

លក្ខខណ្ឌលម្អិតសម្រាប់ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណត្រូវបានកំណត់ក្នុងពាក្យស្នើសុំអាជ្ញាបណ្ណរបស់ក្រសួង។

**ប្រការ៧.-**

រាល់ការប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានខ្នាតតូចត្រូវមានលិខិតអនុញ្ញាតប្រកបអាជីវកម្មពីមន្ទីរ។ ដើម្បីទទួលបានលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមហ៊ុន/សហគ្រាសត្រូវដាក់ពាក្យស្នើសុំនៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត ដោយបំពេញលក្ខខណ្ឌដូចខាងក្រោម÷

- ជានីតិបុគ្គលសញ្ជាតិខ្មែរ និងបានចុះបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់នៅព្រះរាជាណាចក្រកម្ពុជា
- ត្រូវមានដើមទុនប្រកបអាជីវកម្មដូចមានចែងក្នុងប្រការ៩ នៃប្រកាសនេះ
- ត្រូវតម្កល់ប្រាក់ធានាអាជីវកម្ម១០% នៃដើមទុន
- អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវមានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រផ្សេងៗ ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬមានបទពិសោធន៍ពាក់ព័ន្ធទៅនឹងធុរៈកិច្ចស្រដៀងគ្នា ឬធ្លាប់បម្រើការងារផ្នែកនេះ។ ក្នុងករណីអ្នកឈរឈ្មោះមិនមែនជាភាគហ៊ុននិកត្រូវមានលិខិតបញ្ជាក់ពីក្រសួងពាណិជ្ជកម្ម
- ត្រូវមានទីតាំងប្រកបអាជីវកម្មច្បាស់លាស់ដែលបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច។

លក្ខខណ្ឌលម្អិតសម្រាប់ការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្ម ត្រូវបានកំណត់ក្នុងពាក្យស្នើសុំស្នើសុំរបស់មន្ទីរ។

**ប្រការ៨.-**

ក្រសួង/មន្ទីរមានរយៈពេលយ៉ាងយូរ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការក្នុងការពិនិត្យ និងសម្រេចផ្តល់ ឬបដិសេធ ឬបន្តសុពលភាពជូនក្រុមហ៊ុន/សហគ្រាសគិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារពេញលេញ និងគ្រប់ចំនួន។

**ប្រការ៩.-**

ដើមទុនសម្រាប់ប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានត្រូវបានកំណត់ដូចខាងក្រោម÷

**ក- អាជីវកម្មទទួលបញ្ចាំរួមមាន÷**

- ខ្នាតតូច : ត្រូវមានដើមទុនចាប់ពី ២០ លានរៀល ដល់ ៤០ លានរៀល
- ខ្នាតមធ្យម : ត្រូវមានដើមលើសពី ៤០ លានរៀល ដល់ ២០០ លានរៀល
- ខ្នាតធំ (កម្រិត១) : ត្រូវមានដើមទុនលើសពី ២០០ លានរៀល ដល់ ៨០០ លានរៀល
- ខ្នាតធំ (កម្រិត២) : ត្រូវមានដើមទុនលើសពី ៨០០ លានរៀល ឡើងទៅ

**ខ- អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានរួមមាន÷**

- ខ្នាតតូច : ត្រូវមានដើមទុនចាប់ពី ២០ លានរៀល ដល់ ៤០ លានរៀល
- ខ្នាតមធ្យម : ត្រូវមានដើមទុនលើសពី ៤០ លានរៀល ដល់ ២០០ លានរៀល
- ខ្នាតធំ (កម្រិត១) : ត្រូវមានដើមទុនលើសពី ២០០ លានរៀល ដល់ ៨០០ លានរៀល
- ខ្នាតធំ (កម្រិត២) : ត្រូវមានដើមទុនលើសពី ៨០០ លានរៀល ឡើងទៅ

រាល់ការបន្ថែម ឬបន្ថយដើមទុនអាជីវកម្មខាងលើត្រូវមានការអនុញ្ញាតពីក្រសួង/មន្ទីរជាមុន។

**ប្រការ១០.-**

ប្រភេទ ខ្នាត ថ្លៃ និងសុពលភាពអាជ្ញាបណ្ណប្រកបអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានដែលចេញដោយក្រសួងត្រូវបានកំណត់ដូចខាងក្រោម÷

| លរ | ប្រភេទ | | ថ្លៃអាជ្ញាបណ្ណថ្មី/បន្ត | សុពលភាព |
|---|---|---|---|---|
| **-អាជីវកម្មទទួលបញ្ចាំ** | | | | |
| ១ | អាជ្ញាបណ្ណ | ខ្នាតមធ្យម | ២.០០០.០០០រៀល/ ០១ឆ្នាំ | ០៣ឆ្នាំ |
| | | ខ្នាតធំ (កម្រិត១) | ៣.០០០.០០០រៀល/ ០១ឆ្នាំ | |
| | | ខ្នាតធំ (កម្រិត២) | ៤.០០០.០០០រៀល/ ០១ឆ្នាំ | |
| ២ | អាជ្ញាបណ្ណសាខា | ខ្នាតមធ្យម | ១.០០០.០០០រៀល/ ០១ឆ្នាំ | ០៣ឆ្នាំ |
| | | ខ្នាតធំ (កម្រិត១) | ១.៥០០.០០០រៀល/ ០១ឆ្នាំ | |
| | | ខ្នាតធំ (កម្រិត២) | ២.០០០.០០០រៀល/ ០១ឆ្នាំ | |
| **-អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន** | | | | |
| ១ | អាជ្ញាបណ្ណ | ខ្នាតមធ្យម | ១.០០០.០០០រៀល/ ០១ឆ្នាំ | ០៣ឆ្នាំ |
| | | ខ្នាតធំ (កម្រិត១) | ១.៥០០.០០០រៀល/ ០១ឆ្នាំ | |
| | | ខ្នាតធំ (កម្រិត២) | ២.០០០.០០០រៀល/ ០១ឆ្នាំ | |
| ២ | អាជ្ញាបណ្ណសាខា | ខ្នាតមធ្យម | ៥០០.០០០រៀល/ ០១ឆ្នាំ | ០៣ឆ្នាំ |
| | | ខ្នាតធំ (កម្រិត១) | ៧៥០.០០០រៀល/ ០១ឆ្នាំ | |
| | | ខ្នាតធំ (កម្រិត២) | ១.០០០.០០០រៀល/ ០១ឆ្នាំ | |

ថ្លៃអាជ្ញាបណ្ណ ឬថ្លៃបន្តសុពលភាពអាជ្ញាបណ្ណដូចមានចែងក្នុងប្រការនេះត្រូវបង់រៀងរាល់០១ (មួយ) ឆ្នាំម្តងទៅក្នុងគណនីទោលរបស់រតនាគារជាតិដែលបើកនៅធនាគារជាតិ នៃកម្ពុជាតាមដីកាអមរបស់នាយកដ្ឋាន។

អ្នកកាន់អាជ្ញាបណ្ណត្រូវដាក់ពាក្យស្នើសុំបង់ថ្លៃបន្តសុពលភាពអាជ្ញាបណ្ណប្រចាំឆ្នាំឱ្យបាន៣០ ថ្ងៃមុន នៃឆ្នាំបន្ទាប់។

**ប្រការ១១.-**

ប្រភេទ ថ្លៃ និងសុពលភាពលិខិតអនុញ្ញាតប្រកបអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានខ្នាតតូចដែលចេញដោយមន្ទីរត្រូវបានកំណត់ដូចខាងក្រោម÷

| លរ | ប្រភេទ | | ថ្លៃលិខិតអនុញ្ញាតថ្មី/ បន្ត | សុពលភាព |
|---|---|---|---|---|
| **-អាជីវកម្មទទួលបញ្ចាំ** | | | | |
| ១ | លិខិតអនុញ្ញាត | ខ្នាតតូច | ១.០០០.០០០រៀល | ០១ឆ្នាំ |
| ២ | លិខិតអនុញ្ញាតសាខា | ខ្នាតតូច | ៥០០.០០០រៀល | ០១ឆ្នាំ |
| **-អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន** | | | | |
| ១ | លិខិតអនុញ្ញាត | ខ្នាតតូច | ៥០០.០០០រៀល | ០១ឆ្នាំ |
| ២ | លិខិតអនុញ្ញាតសាខា | ខ្នាតតូច | ២៥០.០០០រៀល | ០១ឆ្នាំ |

ថ្លៃលិខិតអនុញ្ញាតប្រកបអាជីវកម្មដូចមានចែងក្នុងប្រការនេះ ត្រូវបង់ចូលគណនីទោលរបស់សាខារតនាគារជាតិដែលបើកនៅសាខាធនាគារជាតិ នៃកម្ពុជានៅបណ្តារាជធានី-ខេត្ត តាមដីកាអមរបស់មន្ទីរសាមីរាជធានី-ខេត្ត នោះ។

អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតឱ្យបាន ៣០ ថ្ងៃមុនលិខិតអនុញ្ញាតនោះផុតសុពលភាព និងត្រូវបង់ថ្លៃបន្តសុពលភាពដូចមានចែងក្នុងប្រការនេះ។

**ប្រការ១២.-**

ក្រុមហ៊ុន/ សហគ្រាស អាចបង្កើតសាខាបានលុះត្រាតែមានអាជ្ញាបណ្ណពីក្រសួង/ លិខិតអនុញ្ញាតប្រកបអាជីវកម្មពីមន្ទីរ។

ដើម្បីបើកសាខាបានក្រុមហ៊ុន/ សហគ្រាសត្រូវបំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ៦ និងប្រការ ៧នៃប្រកាសនេះ។

## ជំពូកទី៤

## កិច្ចដំណើរការអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន

### ផ្នែកទី១

### ភារកិច្ចរបស់អ្នកកាន់អាជ្ញាបណ្ណ និងអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្ម

**ប្រការ១៣.-**

**អ្នកកាន់អាជ្ញាបណ្ណ និងអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មមានភារកិច្ចដូចខាងក្រោម÷**

- ត្រូវទទួលខុសត្រូវចំពោះអតិថិជនដែលពាក់ព័ន្ធនឹងអាជីវកម្មរបស់ខ្លួន
- ត្រូវមានស្លាកយីហោអាជីវកម្មនៅពីមុខកន្លែងធ្វើអាជីវកម្ម ហើយអាជ្ញាបណ្ណ/ លិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវដាក់បង្ហាញនៅកន្លែងដែលងាយមើលឃើញ
- ត្រូវធ្វើអាជីវកម្មឱ្យបានត្រឹមត្រូវស្របតាមឈ្មោះ អាសយដ្ឋានដែលបានបញ្ជាក់នៅក្នុងអាជ្ញាបណ្ណ/ លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ត្រូវមានកិច្ចសន្យា និងសៀវភៅកត់ត្រាប្រតិបត្តិការអាជីវកម្មទទួលបញ្ចាំ ឬទទួលប្រាតិភោគដោយអនុប្បទាន និងត្រូវថែរក្សាទុកដាក់ឱ្យបានល្អ។ ទម្រង់កិច្ចសន្យា និងសៀវភៅកត់ត្រាប្រតិបត្តការអាជីវកម្មនឹងមានផ្តល់ជូនដោយក្រសួង
- រាល់កិច្ចសន្យាដាក់បញ្ចាំ ឬដាក់ប្រាតិភោគដោយអនុប្បទានត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរជាមួយអតិថិជនព្រមទាំងមានការបញ្ជាក់ឱ្យបានច្បាស់លាស់នូវព័ត៌មានអប្បរមា លក្ខខណ្ឌ រយៈពេលកិច្ចសន្យាដូចមានចែងក្នុងកថាខណ្ឌទី២ នៃប្រការ១៦ និងភារកិច្ចដែលគូភាគីបានព្រមព្រៀងគ្នាដោយមានការចុះហត្ថលេខា ឬស្នាមមេដៃទទួលស្គាល់ត្រឹមត្រូវដោយគូភាគីនៃកិច្ចសន្យា
- ត្រូវរក្សាទុកទ្រព្យបញ្ចាំ និង/ ឬប្រាតិភោគដោយអនុប្បទាននៅកន្លែងដែលមានសុវត្ថិភាព និងមិនត្រូវយកទ្រព្យនោះទៅប្រើប្រាស់ឡើយ
- ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការខូចខាត ឬបាត់បង់លើទ្រព្យបញ្ចាំ ឬទ្រព្យប្រាតិភោគដោយអនុប្បទានកើតឡើងក្នុងអំឡុងពេលជាប់កិច្ចសន្យា
- ត្រូវផ្តល់ព័ត៌មានជាបន្ទាន់ឱ្យនគរបាល ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដែលមានទីតាំងនៅជិតកន្លែងអាជីវកម្មក្នុងករណីមានការសង្ស័យចំពោះអតិថិជន ឬទ្រព្យណាមួយដែលពាក់ព័ន្ធនឹងបទល្មើស
- ត្រូវផ្តល់ព័ត៌មាន ឬរបាយការណ៍អំពីអត្តសញ្ញាណនៃអតិថិជន និងទ្រព្យ (សៀវភៅចុះបញ្ជីទ្រព្យ) ជូនប៉ុស្តិ៍នគរបាលរដ្ឋបាល ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដែលមានទីតាំងនៅជិតកន្លែងអាជីវកម្មក្នុងរយៈពេល០៧ (ប្រាំពីរ )ថ្ងៃយ៉ាងយូរបន្ទាប់ពីកាលបរិច្ឆេទទទួលទ្រព្យបញ្ចាំ និង/ ឬទ្រព្យប្រាតិភោគដោយអនុប្បទាន
- ត្រូវធានាថារាល់ការផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុន/ សហគ្រាសត្រូវតែជាការពិត និងមានការបញ្ជាក់ពីអត្តលេខក្រុមហ៊ុន/ សហគ្រាស

- ត្រូវបិទផ្សាយថ្ងៃ និងពេលវេលាម៉ោងធ្វើការរបស់ខ្លួននៅមុខច្រកទ្វារចេញ- ចូលនៃកន្លែងអាជីវកម្មឱ្យបានត្រឹមត្រូវ និងមិនត្រូវមានប្រតិបត្តិការទទួលបញ្ចាំ ឬទទួលប្រាតិភោគដោយអនុប្បទាន និងប្រមូលការប្រាក់ឡើយក្រៅពីថ្ងៃ ឬម៉ោងដែលបានប្រកាសបិទមិនធ្វើការ
- ត្រូវផ្តល់របាយការណ៍ឱ្យបានទៀងទាត់ដូចមានចែងក្នុងប្រការ២៩នៃប្រកាសនេះ ដោយត្រូវបញ្ជាក់ថាពិតជាត្រឹមត្រូវដោយនាយកក្រុមហ៊ុន/ សហគ្រាស
- ត្រូវបំពេញកាតព្វកិច្ចពន្ធដារឱ្យបានត្រឹមត្រូវដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ
- ត្រូវរាយការណ៍ជាបន្ទាន់ទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជានៃធនាគារជាតិនៃកម្ពុជា ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ឬមកក្រសួង/មន្ទីរក្នុងករណីសង្កេតឃើញសកម្មភាពណាមួយដែលបម្រើដល់ការលាងសម្អាតប្រាក់ ឬបម្រើផលប្រយោជន៍ដល់ភេរវករ ឬបទល្មើសភេរវកម្មណាមួយ
- ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតដែលនៅជាធរមាន។

**ប្រការ១៤.-**

ក្រុមហ៊ុន/ សហគ្រាសត្រូវបានហាមឃាត់សកម្មភាពអាជីវកម្មមួយចំនួនដូចខាងក្រោម÷

- មិនត្រូវផ្សព្វផ្សាយពាណិជ្ជកម្មដែលមានលក្ខណៈមិនពិត ឬឆបោក ឬនាំឱ្យមានការយល់ខុស ឬធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍សាធារណៈ
- មិនត្រូវទទួលយកទ្រព្យអ្វីមួយពីអនីតិជន ឬពីជនណាមួយដែលកំពុងចិត្តក្នុងភាពស្រវឹងជោគជាំ ជនវិប្បល្លាសស្មារតី ឬពីជនណាមួយដែលសង្ស័យថាជាចោរ ឬអ្នកទទួលផលចោរកម្ម
- មិនត្រូវបង្កវិវាទប្បដិវាទក្នុងការធ្វើអាជីវកម្មជាមួយអ្នកទទួលបញ្ចាំ ឬប្រាតិភោគដោយអនុប្បទានដទៃទៀត
- មិនត្រូវចូលរួម ឬធ្វើអាជីវកម្ម ដើម្បីបម្រើដល់សកម្មភាពលាងសម្អាតប្រាក់ឬបម្រើផលប្រយោជន៍ដល់ភេរវករ ឬឧក្រិដ្ឋជនណាមួយឡើយ
- មិនត្រូវទទួលយកទ្រព្យបញ្ចាំ ឬទ្រព្យប្រាតិភោគដោយអនុប្បទានណាដែលពុំមានឯកសារ ឬលិខិតបញ្ជាក់អត្តសញ្ញាណទ្រព្យច្បាស់លាស់
- មិនត្រូវធ្វើអាជីវកម្មខុសពីកម្មវត្ថុនៃអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មទទួលបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន
- មិនត្រូវទទួលយកទ្រព្យណាមួយដែលច្បាប់ហាមឃាត់។

## ផ្នែកទី ២
## ការផ្តល់ប្រាក់កម្ចី

**ប្រការ១៥.-**

ចំពោះក្រុមហ៊ុន/ សហគ្រាស ដែលទទួលបានអាជ្ញាបណ្ណពីក្រសួង ការផ្តល់ប្រាក់កម្ចីដល់អ្នកដាក់បញ្ចាំ ឬដល់អ្នកដាក់ប្រាតិភោគដោយអនុប្បទាន ០១ ប្រតិបត្តិការមិនត្រូវលើសពី ២០ % (ម្ភៃភាគរយ) នៃដើមទុនអាជីវកម្មដែលបានប្រកាសឡើយ។ ការផ្តល់ប្រាក់កម្ចីសម្រាប់ឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុមិនត្រូវលើសពី ២០.០០០.០០០ (ម្ភៃលាន) រៀលឡើយក្នុងមួយប្រតិបត្តិការនៃទ្រព្យបញ្ចាំ។

ចំពោះក្រុមហ៊ុន/ សហគ្រាស ដែលទទួលបានលិខិតអនុញ្ញាតប្រកបអាជីវកម្មពីមន្ទីរ ការផ្តល់ប្រាក់កម្ចីដល់អ្នកដាក់បញ្ចាំ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទាន ០១ ប្រតិបត្តិការមិនត្រូវលើសពី ២០ % (ម្ភៃភាគរយ) នៃដើមទុនអាជីវកម្មដែលបានប្រកាសឡើយ។ ការផ្តល់ប្រាក់កម្ចីសម្រាប់ឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុមិនត្រូវលើសពី ៤.០០០.០០០ (បួនលាន) រៀលក្នុងមួយប្រតិបត្តិការនៃទ្រព្យបញ្ចាំនោះ។

## ផ្នែកទី ៣
## អត្រាការប្រាក់ និងរយៈពេលនៃការដាក់បញ្ចាំ និង/ឬប្រាតិភោគដោយអនុប្បទាន

**ប្រការ១៦.-**

អត្រាការប្រាក់ត្រូវកំណត់តាមការព្រមព្រៀងរវាងអ្នកទទួលបញ្ចាំ ឬអ្នកទទួលប្រាតិភោគដោយអនុប្បទាន និងអ្នកដាក់បញ្ចាំ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទាន និងត្រូវអនុលោមតាមបទប្បញ្ញត្តិ និងច្បាប់ដែលនៅជាធរមាន។

កិច្ចសន្យានេះមានសុពលភាពអនុវត្តយ៉ាងយូរត្រឹម០៤ (បួន) ខែ ចាប់ពីកាលបរិច្ឆេទនៃការដាក់ទ្រព្យបញ្ចាំ ឬដាក់ទ្រព្យប្រាតិភោគដោយអនុប្បទាន និងអាចបន្តសុពលភាពសារជាថ្មីបាន។

## ផ្នែកទី ៤
## ការចាត់ចែងទ្រព្យ

**ប្រការ១៧.-**

ក្នុងករណីអ្នកដាក់បញ្ចាំ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទានបានសងប្រាក់កម្ចី និងការប្រាក់គ្រប់ចំនួនដូចមានចែងក្នុងកិច្ចសន្យាក្រុមហ៊ុន/សហគ្រាសត្រូវប្រគល់ទ្រព្យបញ្ចាំ ឬទ្រព្យប្រាតិភោគដោយអនុប្បទានទៅឱ្យអ្នកដាក់បញ្ចាំ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទានវិញភ្លាម។

**ប្រការ១៨.-**

ក្រុមហ៊ុន/សហគ្រាស ពុំមានសិទ្ធិលក់ ផ្ទេរ ប្រើប្រាស់ ឬប្រគល់សិទ្ធិកាន់កាប់ទ្រព្យបញ្ចាំ ឬទ្រព្យប្រាតិភោគ-ដោយអនុប្បទាន ឱ្យទៅបុគ្គលផ្សេងទៀតក្នុងអំឡុងពេលដែលទ្រព្យបញ្ចាំ ឬទ្រព្យប្រាតិភោគដោយអនុប្បទាននោះកំពុងជាប់កិច្ចសន្យា ដោយពុំមានការឯកភាពពីអ្នកដាក់បញ្ចាំ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទានឡើយ។

**ប្រការ១៩.-**

ក្នុងករណីអ្នកដាក់បញ្ចាំ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទានពុំមានលទ្ធភាពសងប្រាក់កម្ចីនិងការប្រាក់តាមការកំណត់នៅពេលកិច្ចសន្យាដល់កាលវសានការចាត់ចែងលើទ្រព្យបញ្ចាំ ឬទ្រព្យប្រាតិភោគដោយអនុប្បទានមានដូចខាងក្រោម÷

- **សម្រាប់អាជីវកម្មទទួលបញ្ចាំ**÷ទ្រព្យបញ្ចាំត្រូវចាត់ចែងអនុលោមតាមនីតិវិធីដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។
- **សម្រាប់អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន**÷ទ្រព្យប្រាតិភោគដោយអនុប្បទាននឹងត្រូវចាត់ចែងតាមលទ្ធភាពជាក់ស្តែង ឬនីតិវិធីដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ផ្នែកទី៥
## ការផ្លាស់ប្តូរទីតាំង នាមករណ៍ ភាគទុនិក សមាជិកក្រុមប្រឹក្សាភិបាល
## អ្នកកាន់អាជ្ញាបណ្ណ ឬអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្ម

**ប្រការ២០.-**

រាល់ការផ្លាស់ប្តូរទីតាំងអាជីវកម្ម នាមករណ៍ ភាគទុនិក សមាជិកក្រុមប្រឹក្សាភិបាល អ្នកកាន់អាជ្ញាបណ្ណ ឬអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្ម ត្រូវមានការឯកភាពជាមុនពីក្រសួង/មន្ទីរ។

ក្រុមហ៊ុន/សហគ្រាសត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរមុននឹងធ្វើការផ្លាស់ប្តូរ។

ក្រសួង ឬមន្ទីរ ត្រូវជូនដំណឹងអំពីការសម្រេចឯកភាព ឬជំទាស់ ក្នុងរយៈពេល ៣០ ថ្ងៃនៃថ្ងៃធ្វើការ ឬរយៈពេលសមស្របណាមួយ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលសំណើ។

**ប្រការ២១..**

ការផ្លាស់ប្តូរទីតាំងអាជីវកម្ម នាមករណ៍ ភាគទុននិក សមាជិកក្រុមប្រឹក្សាភិបាល អ្នកកាន់អាជ្ញាបណ្ណ ឬអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មរបស់ក្រុមហ៊ុន/សហគ្រាសត្រូវផ្តល់ឯកសារដូចខាងក្រោម÷

**ក. ការស្នើសុំផ្លាស់ប្តូរទីតាំងអាជីវកម្មរបស់ក្រុមហ៊ុន/សហគ្រាស÷**

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរស្តីពីការស្នើសុំផ្លាស់ប្តូរដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- លិខិតឯកភាពពីអាជ្ញាធរដែនដីចំពោះទីតាំងអាជីវកម្មថ្មី
- លិខិតបញ្ជាក់ស្តីពីការបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវតាមច្បាប់ស្តីពីសារពើពន្ធ
- ឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុទីតាំងថ្មី ឬកិច្ចសន្យាជួលទីតាំងថ្មី
- ឯកសារបញ្ជាក់ពីការចុះផ្សាយលើទំព័រសារព័ត៌មានក្នុងស្រុកណាមួយដោយទុករយៈពេលយ៉ាងតិច០១ ខែគិតចាប់ពីកាលបរិច្ឆេទនៃការចុះផ្សាយ ដើម្បីឱ្យអតិថិជនបានជ្រាបអំពីការផ្លាស់ប្តូរទីតាំងអាជីវកម្ម និងជម្រះបញ្ជីប្រតិបត្តិការជាមួយអតិថិជនឱ្យបានរួចរាល់

**ខ. ការស្នើសុំផ្លាស់ប្តូរនាមករណ៍របស់ក្រុមហ៊ុន/សហគ្រាស÷**

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរស្តីពីការស្នើសុំផ្លាស់ប្តូរនាមករណ៍ដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលស្តីពីការផ្លាស់ប្តូរនាមករណ៍ ឬលិខិតសម្រេចរបស់នាយកក្រុមហ៊ុន/សហគ្រាស
- ឯកសារបញ្ជាក់ពីការចុះផ្សាយលើទំព័រសារព័ត៌មានក្នុងស្រុកណាមួយដោយទុករយៈពេលយ៉ាងតិច០១ ខែគិតចាប់ពីកាលបរិច្ឆេទនៃការចុះផ្សាយ ដើម្បីឱ្យអតិថិជនបានជ្រាបអំពីការផ្លាស់ប្តូរនាមករណ៍

**គ. ការស្នើសុំផ្លាស់ប្តូរភាគទុននិក ឬសមាជិកក្រុមប្រឹក្សាភិបាលប្រកបអាជីវកម្ម÷**

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរ ស្តីពីការស្នើសុំផ្លាស់ប្តូរភាគទុននិក ឬសមាជិកក្រុមប្រឹក្សាភិបាលដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលស្តីពីការផ្លាស់ប្តូរភាគទុននិក ឬសមាជិកក្រុមប្រឹក្សាភិបាល
- លិខិតទិញ-លក់ភាគហ៊ុនរបស់ភាគហ៊ុននិក
- លិខិតថ្កោលទោសឬលិខិតបញ្ជាក់កិរិយាមារយាទចេញដោយអាជ្ញាធរមានសមត្ថកិច្ច

**ឃ. ការស្នើសុំផ្លាស់ប្តូរអ្នកកាន់អាជ្ញាបណ្ណ/អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្ម÷**

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរ ស្តីពីការស្នើសុំផ្លាស់ប្តូរដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- អាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មច្បាប់ដើម
- សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រផ្សេងៗ ឬលិខិតបញ្ជាក់បទពិសោធន៍ពាក់ព័ន្ធធុរៈកិច្ចស្រដៀងគ្នា ឬធ្លាប់បម្រើការងារផ្នែកនេះចំពោះអ្នកកាន់អាជ្ញាបណ្ណ។
- សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រផ្សេងៗ ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬលិខិតបញ្ជាក់បទពិសោធន៍ពាក់ព័ន្ធធុរៈកិច្ចស្រដៀងគ្នា ឬធ្លាប់បម្រើការងារផ្នែកនេះ ចំពោះអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- លិខិតថ្កោលទោស ឬលិខិតបញ្ជាក់កិរិយាមាយាទចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

## ផ្នែកទី ៦
## ប្រាក់តម្កល់ធានាអាជីវកម្ម

**ប្រការ២២.-**

ក្រុមហ៊ុន/សហគ្រាស ខ្នាតមធ្យម និងខ្នាតធំត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ១០ % (ដប់ភាគរយ) នៃដើមទុនប្រកបអាជីវកម្មទៅក្នុងគណនីទោលរតនាគារជាតិដែលបើកនៅធនាគារជាតិ នៃកម្ពុជាតាមដីកាអមរបស់នាយកដ្ឋាន។

ក្រុមហ៊ុន/សហគ្រាសខ្នាតតូច ត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ១០% (ដប់ភាគរយ) នៃដើមទុនប្រកបអាជីវកម្មទៅក្នុងគណនីទោលរបស់សាខារតនាគារជាតិ ដែលបើកនៅសាខាធនាគារជាតិនៃកម្ពុជាតាមដីកាអមរបស់មន្ទីរសាមីនោះ។

ប្រាក់តម្កល់ធានាអាជីវកម្មដូចមានចែងក្នុងកថាខណ្ឌទី១ និងទី២ ខាងលើអាចដកវិញបានក្រោយពីក្រុមហ៊ុន/សហគ្រាសបានបញ្ឈប់សកម្មភាពអាជីវកម្មជាស្ថាពរ ហើយត្រូវគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ២៥ ។

**ប្រការ២៣.-**

នៅក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃបានទទួលលិខិតស្នើសុំដកប្រាក់តម្កល់ និងឯកសារតម្រូវផ្សេងៗ ក្រសួងត្រូវចេញលិខិតអនុញ្ញាតឱ្យដក ឬលិខិតបដិសេធដកប្រាក់តម្កល់នោះ ដោយបញ្ជាក់ហេតុផលត្រឹមត្រូវ។

## ជំពូកទី ៥
## ការផ្អាក និងការបញ្ឈប់សកម្មភាពអាជីវកម្ម

**ប្រការ២៤.-**

ក្នុងករណីផ្អាកសកម្មភាពអាជីវកម្ម ក្រុមហ៊ុន/សហគ្រាសត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរ ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធដូចខាងក្រោម÷

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរស្ដីពីការស្នើសុំផ្អាកដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- លិខិតបញ្ជាក់ស្ដីពីការបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវតាមច្បាប់សារពើពន្ធ
- លិខិតជូនដំណឹងទៅអាជ្ញាធរពន្ធដារមានសមត្ថកិច្ចស្ដីពីការផ្អាកសកម្មភាពអាជីវកម្ម
- ឯកសារពាក់ព័ន្ធការជម្រះបញ្ជីជាមួយអតិថិជនដែលដាក់បញ្ញើ ឬដាក់ប្រាតិភោគដោយអនុប្បទាន

ក្រសួង/មន្ទីរអនុញ្ញាតឱ្យ ក្រុមហ៊ុន/សហគ្រាសផ្អាកសកម្មភាពអាជីវកម្មរបស់ខ្លួនជាបណ្ដោះអាសន្នយ៉ាងយូរត្រឹម៤ (បួន) ខែ ក្នុង១ (មួយ) ឆ្នាំ ឬត្រឹមសុពលភាពអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មដែលនៅសល់តែប៉ុណ្ណោះ។

**ប្រការ២៥.-**

ក្នុងករណីបញ្ឈប់សកម្មភាពអាជីវកម្ម ក្រុមហ៊ុន/សហគ្រាសត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរ មុនបញ្ឈប់សកម្មភាពអាជីវកម្ម និងត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារដូចខាងក្រោម÷

- លិខិតស្នើសុំបញ្ឈប់អាជីវកម្មដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់
- អាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មច្បាប់ដើម
- លិខិតបញ្ជាក់ពីការបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវដែលចេញដោយអាជ្ញាធរពន្ធដារមានសមត្ថកិច្ច
- ឯកសារពាក់ព័ន្ធការចុះផ្សាយលើទំព័រសារព័ត៌មានក្នុងស្រុកណាមួយដោយទុករយៈពេលយ៉ាងតិច០១ ខែគិតចាប់ពីកាលបរិច្ឆេទនៃការចុះផ្សាយ ដើម្បីឱ្យអតិថិជនបានជ្រាបអំពីការបញ្ឈប់សកម្មភាពអាជីវកម្ម និងការជម្រះបញ្ជីប្រតិបត្តិការជាមួយអតិថិជន
- បង្កាន់ដៃបង់ប្រាក់តម្កល់ធានាអាជីវកម្ម។

**ប្រការ២៦.-**

នៅក្នុងរយៈពេលយ៉ាងយូរ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃបានទទួលលិខិតស្នើសុំផ្អាក ឬបញ្ឈប់សកម្មភាពអាជីវកម្ម ឯកសារតម្រូវផ្សេងៗក្រសួង/មន្ទីរ ត្រូវចេញលិខិតបញ្ជាក់យល់ព្រម ឬបដិសេធសំណើរបស់ក្រុមហ៊ុន/សហគ្រាសដោយបញ្ជាក់ហេតុផលត្រឹមត្រូវ។

## ជំពូកទី៦

## ការត្រួតពិនិត្យ និងរបាយការណ៍

**ប្រការ២៧.-**

ក្រសួង/មន្ទីរមានសិទ្ធិចាត់មន្ត្រីជំនាញចុះត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងដើម្បីធានាដល់ការអនុវត្តប្រកាសនេះ។

**ប្រការ២៨.-**

មន្ទីរត្រូវផ្តល់ជូននាយកដ្ឋាននូវរបាយការណ៍ដូចខាងក្រោម÷

-របាយការណ៍ប្រចាំត្រីមាសស្តីពីសកម្មភាពអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានឱ្យបានមុនថ្ងៃទី១៥ នៃត្រីមាសបន្ទាប់

-របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រុមហ៊ុន/សហគ្រាសទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានឱ្យបានមុនបំណាច់ត្រីមាសទី១ នៃឆ្នាំសារពើពន្ធ។

ទម្រង់នៃរបាយការណ៍ខាងលើត្រូវបានកំណត់ទៅតាមគំរូដែលនាយកដ្ឋានបានផ្តល់ជូន។

**ប្រការ២៩.-**

ក្រុមហ៊ុន/សហគ្រាសដែលទទួលបានអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម ត្រូវផ្តល់ជូនក្រសួង/មន្ទីរនូវរបាយការណ៍ដូចខាងក្រោម÷

- របាយការណ៍ប្រតិបត្តិការអាជីវកម្មប្រចាំខែមិនឱ្យលើសពីថ្ងៃទី១៥ នៃខែបន្ទាប់
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមិនឱ្យលើសពីត្រីមាសទី១ នៃឆ្នាំបន្ទាប់

ទម្រង់នៃរបាយការណ៍ខាងលើត្រូវបានកំណត់តាមគំរូដែលកំណត់ដោយក្រសួង។

**ប្រការ៣០.-**

ក្រសួង/មន្ទីរមានសិទ្ធិតែងតាំងសវនករឯករាជ្យ ដើម្បីធ្វើសវនកម្មក្រុមហ៊ុន/សហគ្រាសទាំងអស់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន ក្នុងករណីរកឃើញភាពមិនប្រក្រតីលើឯកសារពាក់ព័ន្ធនឹងប្រតិបត្តិការអាជីវកម្មដែលផ្តល់ដោយក្រុមហ៊ុន/សហគ្រាស ដោយរាល់ការចំណាយលើសវនករឯករាជ្យជាបន្ទុករបស់ក្រុមហ៊ុន/សហគ្រាស។

## ជំពូកទី៧

## ការផ្សះផ្សា និងដោះស្រាយវិវាទ

**ប្រការ៣១.-**

វិវាទរវាងក្រុមហ៊ុន/សហគ្រាសទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានជាមួយក្រុមហ៊ុន/សហគ្រាសទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន និង/ឬជាមួយអ្នកដាក់បញ្ចាំ/អ្នកដាក់ប្រាតិភោគដោយអនុប្បទានពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្មបញ្ចាំ ឬប្រាតិភោគដោយអនុប្បទានអាចជាកម្មវត្ថុនៃការសម្រុះសម្រួល និងផ្សះផ្សាដោយអគ្គនាយកដ្ឋាន/មន្ទីរ។

ក្រសួង/មន្ទីរសម្រុះសម្រួល និងផ្សះផ្សាវិវាទតាមការស្នើសុំរបស់ភាគីវិវាទក្នុងរយៈពេល០២ខែយ៉ាងយូរ។ ការផ្សះផ្សាវិវាទអាចឈានទៅដល់ការចុះកិច្ចព្រមព្រៀងផ្សះផ្សា ដែលត្រូវចុះហត្ថលេខាដោយគូភាគីវិវាទដោយមានប្រថាប់ត្រារបស់អគ្គនាយកដ្ឋាន/មន្ទីរ។ កិច្ចព្រមព្រៀងផ្សះផ្សាមានអានុភាពអនុវត្តភ្លាមៗចំពោះគូភាគី។

**ប្រការ៣២.-**

ក្រុមហ៊ុន/សហគ្រាស ឬអ្នកដាក់បញ្ចាំ ឬដាក់ប្រាតិភោគដោយអនុប្បទានដែលមិនពេញចិត្តចំពោះសេចក្តីសម្រេច ឬវិធានការផ្សេងៗរបស់ក្រសួង/មន្ទីរមានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ាមកក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មុននឹងអនុវត្តនីតិវិធីបណ្តឹងទៅតុលាការលើកលែងតែរឿងព្រហ្មទណ្ឌ។

ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវដោះស្រាយបណ្តឹងក្នុងរយៈពេល៩០ ថ្ងៃនៃថ្ងៃធ្វើការក្រោយពីទទួលបានពាក្យបណ្តឹងតវ៉ា ឬក្នុងរយៈពេលមួយសមស្រប។

ក្នុងការដោះស្រាយវិវាទក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចអញ្ជើញភាគីពាក់ព័ន្ធវិវាទដើម្បីសាកសួរ ឬផ្តល់ភស្តុតាងតាមការចាំបាច់។

សេចក្តីសម្រេច ស្តីពីការដោះស្រាយវិវាទត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដោយមានបញ្ជាក់អំពីអង្គហេតុសំអាងហេតុ និងការសន្និដ្ឋាន។

ក្នុងករណីមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សានីតិកម្ម ភាគីវិវាទអាចដាក់ពាក្យបណ្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៨

## ទោសប្បញ្ញត្តិ

**ប្រការ៣៣.-**

ត្រូវបានចាត់ទុកជាអំពើបំពាននឹងបទប្បញ្ញត្តិនៃប្រកាសនេះចំពោះអំពើដូចខាងក្រោម÷

- ប្រកបអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន គ្មានអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ក្លែងបន្លំអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ប្រើប្រាស់អាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មផុតសុពលភាព
- ប្រកបអាជីវកម្មខុសពីទីតាំងដែលបានបញ្ជាក់នៅលើអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ផ្តល់ប្រាក់កម្ចីខុសពីលក្ខខណ្ឌដូចមានចែងក្នុងប្រការ១៥ នៃប្រកាសនេះ
- យឺតយ៉ាវក្នុងការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃមុនពេលអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មនោះផុតសុពលភាព
- បង្កើតសាខាដោយគ្មានការអនុញ្ញាតពីក្រសួង/មន្ទីរ
- ប្រកបអាជីវកម្មខុសពីកម្មវត្ថុនៃអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មដែលបានផ្តល់ជូន
- អនុវត្តផ្ទុយនឹងប្រការ១៣ ប្រការ១៤ ប្រការ១៥ ប្រការ២០ ប្រការ២៤ និងប្រការ២៥ នៃប្រកាសនេះ
- មិនបានផ្តល់ ឬផ្តល់របាយការណ៍យឺតយ៉ាវតាមការកំណត់ដូចមានចែងក្នុងប្រការ២៩ នៃប្រកាសនេះ
- ពុំអនុវត្តតាមការណែនាំជាលាយលក្ខណ៍អក្សររបស់ក្រសួង។

**ប្រការ៣៤.-**

ក្រុមហ៊ុន/សហគ្រាសទាំងឡាយណាដែលបានប្រព្រឹត្តកំហុសដូចមានចែងក្នុងប្រការ៣៣នៃប្រកាសនេះនឹងត្រូវទទួលរងទណ្ឌកម្មរដ្ឋបាលដូចខាងក្រោម÷

- ព្រមានជាលាយលក្ខណ៍អក្សរ
- ហាមឃាត់ការធ្វើប្រតិបត្តិការឬរឹតត្បិតសកម្មភាពមួយចំនួន
- ព្យួរអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មបណ្តោះអាសន្នពី០៦ ខែទៅ១ ឆ្នាំ
- ដកហូតអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ផ្សព្វផ្សាយជាសាធារណៈនូវអំពើបំពាននឹងបទប្បញ្ញត្តិនៃប្រកាសនេះ

- ចាត់វិធានការផ្សេងៗទៀតទៅតាមច្បាប់ជាធរមាន។

**ប្រការ៣៥.-**

ក្រសួង/មន្ទីរមានសិទ្ធិព្យួរអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មនៅពេលដែលក្រុមហ៊ុន/សហគ្រាសបានប្រព្រឹត្តល្មើសក្នុងករណីណាមួយដូចខាងក្រោម÷

- ខកខានមិនបានផ្តល់របាយការណ៍ប្រចាំខែដោយចេតនា ឬអចេតនាក្រោយពីទទួលបានការព្រមានជាលាយលក្ខណ៍អក្សរ
- បង្កើតសាខាដោយគ្មានការអនុញ្ញាតពីក្រសួង/មន្ទីរជាមុន
- ប្រកបអាជីវកម្មខុសពីកម្មវត្ថុនៃអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មដែលបានផ្តល់ជូនដោយចេតនាក្រោយពីទទួលការព្រមានជាលាយលក្ខណ៍អក្សរ
- បន្តអនុវត្តផ្ទុយនឹងប្រការ១៣ ប្រការ១៤ ប្រការ១៥ ប្រការ២០ ប្រការ២៤ និងប្រការ២៥ នៃប្រកាសនេះក្រោយពីទទួលបានលិខិតព្រមានជាលាយលក្ខណ៍អក្សរ។

**ប្រការ៣៦.-**

ក្រសួង/មន្ទីរ មានសិទ្ធិដកហូតអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មនៅពេលដែលក្រុមហ៊ុន/សហគ្រាសបានប្រព្រឹត្តល្មើសក្នុងករណីណាមួយដូចខាងក្រោម÷

- ខកខានមិនបានផ្តល់របាយការណ៍ប្រចាំខែដោយចេតនា ឬអចេតនាចាប់ពី០៦ ខែឡើងទៅ
- ក្រោយពីទទួលការព្រមានជាលាយលក្ខណ៍អក្សរលើកទី២ ហើយនៅតែមិនរៀងចាលទៀត
- ខកខានមិនបានបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវតាមច្បាប់ស្តីពីសារពើពន្ធលើសពី០៦ ខែឡើងទៅ
- ប្រើប្រាស់អាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មផុតសុពលភាពលើសពី០៣ ខែឡើងទៅ
- ក្រោយពីទទួលការព្រមានជាលាយលក្ខណ៍អក្សរ ហើយនៅតែបន្តប្រកបអាជីវកម្មខុសពីទីតាំងដែលបានបញ្ជាក់នៅលើអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មទៀត
- ផ្តល់ប្រាក់កម្ចីខុសពីលក្ខខណ្ឌដូចមានចែងក្នុងប្រការ១៥ នៃប្រកាសនេះលើសពី០៥ ករណីឡើងទៅ
- យឺតយ៉ាវក្នុងការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មលើសពី០៣ ខែ ក្រោយពេលអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មនោះផុតសុពលភាព
- បង្កើតសាខាលើសពី០២(ពីរ) សាខាឡើងទៅដោយគ្មានការអនុញ្ញាតពីក្រសួង/មន្ទីរជាមុន
- ធ្វើអាជីវកម្មខុសពីកម្មវត្ថុនៃអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម ដែលបានផ្តល់ជូនដោយចេតនាក្រោយពីទទួលការព្រមានជាលាយលក្ខណ៍អក្សរលើកទី២ហើយ
- នៅបន្តអនុវត្តផ្ទុយនឹងប្រការ១៣ ប្រការ១៧ ប្រការ១៩ និងប្រការ២៥ នៃប្រកាសនេះក្រោយពីអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវបានព្យួររួចហើយ
- បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬប្រព្រឹត្តបទល្មើសហិរញ្ញវត្ថុ ឬអំពើមិនស្របច្បាប់ណាមួយដែលមានភស្តុតាងច្បាស់លាស់ពីអាជ្ញាធរមានសមត្ថកិច្ច។

ក្រសួង/មន្ទីរ នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរចំនួន៣០ (សាមសិប) ថ្ងៃមុននឹងដកហូតអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មពីក្រុមហ៊ុន/សហគ្រាសដែលបានប្រព្រឹត្តខុស។

**ប្រការ៣៧.-**

ការប្រកបអាជីវកម្មទទួលបញ្ញើ/ទទួលប្រាតិភោគដោយអនុប្បទានដោយគ្មានអាជ្ញាបណ្ណ ត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួងចំនួន១០.០០០.០០០ (ដប់លាន)រៀល និងត្រូវបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។ ដើម្បីអាចប្រកបអាជីវកម្មបាន ក្រុមហ៊ុន/សហគ្រាសត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមកក្រសួង។

ការប្រកបអាជីវកម្មទទួលបញ្ញើ/ទទួលប្រាតិភោគដោយអនុប្បទាន ដោយគ្មានលិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួងចំនួន ៥.០០០.០០០(ប្រាំលាន)រៀល និងត្រូវបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។ ដើម្បីអាចប្រកបអាជីវកម្មបានក្រុមហ៊ុន/សហគ្រាសត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មមកមន្ទីរ។

**ប្រការ៣៨.-**

ការក្លែងបន្លំអាជ្ញាបណ្ណត្រូវទទួលពិន័យអន្តរការណ៍ចំនួន ១០.០០០.០០០ (ដប់លាន) រៀល និងបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។

ការក្លែងបន្លំលិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវទទួលពិន័យអន្តរការណ៍ចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល និងបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។

**ប្រការ៣៩.-**

ការប្រើប្រាស់អាជ្ញាបណ្ណផុតសុពលភាពត្រូវទទួលពិន័យអន្តរការណ៍ចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល និងត្រូវរួសរាន់ដាក់ពាក្យស្នើសុំបន្តសុពលភាពក្នុងករណីមិនរាងចាលក្រសួងនឹងចាត់វិធានការបញ្ឈប់សកម្មភាពអាជីវកម្មជាស្ថាពរ។

ការប្រើប្រាស់លិខិតអនុញ្ញាតប្រកបអាជីវកម្មផុតសុពលភាពត្រូវទទួលពិន័យអន្តរការណ៍ចំនួន ២.៥០០.០០០ (ពីរលានប្រាំរយពាន់) រៀល និងត្រូវរួសរាន់ដាក់ពាក្យស្នើសុំបន្តសុពលភាពក្នុងករណីមិនរាងចាលមន្ទីរនឹងចាត់វិធានការបញ្ឈប់សកម្មភាពអាជីវកម្មជាស្ថាពរ។

**ប្រការ៤០.-**

ការប្រកបអាជីវកម្មខុសពីទីតាំងដែលបានបញ្ជាក់នៅលើអាជ្ញាបណ្ណត្រូវទទួលពិន័យអន្តរការណ៍ចំនួន ២.០០០.០០០ (ពីរលាន)រៀល និងត្រូវបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

ការប្រកបអាជីវកម្មខុសពីទីតាំងដែលបានបញ្ជាក់នៅលើលិខិតអនុញ្ញាតប្រកបអាជីវកម្ម ត្រូវទទួលពិន័យអន្តរការណ៍ចំនួន ១.០០០.០០០(មួយលាន) រៀល និងត្រូវបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

**ប្រការ៤១.-**

ការផ្តល់ប្រាក់កម្ចីលើសពីដើមទុនដែលបានប្រកាសជាមួយក្រសួងត្រូវទទួលពិន័យអន្តរការណ៍ចំនួន ៣.០០០.០០០ (បីលាន) រៀល។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការព្យួរអាជ្ញាបណ្ណបណ្តោះអាសន្ន។

ការផ្តល់ប្រាក់កម្ចីលើសពីដើមទុនដែលបានប្រកាសជាមួយមន្ទីរត្រូវទទួលពិន័យអន្តរការណ៍ចំនួន១.៥០០.០០០ (មួយលានប្រាំរយពាន់) រៀល។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការព្យួរអាជ្ញាបណ្ណបណ្តោះអាសន្ន។

**ប្រការ៤២.-**

ការយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំបង់ថ្លៃបន្តសុពលភាពអាជ្ញាបណ្ណប្រចាំឆ្នាំដូចមានចែងក្នុងប្រការ១០ ត្រូវទទួលពិន័យអន្តរការណ៍ចំនួន២០.០០០(ម្ភៃពាន់) រៀល ក្នុង ០១ ថ្ងៃសម្រាប់រយៈពេល៣០ថ្ងៃដំបូង។ ក្នុងករណីមិនរាងចាលចំនួនទឹកប្រាក់ផាកពិន័យត្រូវគុណទ្វេដង។

ការយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតប្រកបអាជីវកម្មក្នុងរយៈពេល៣០ថ្ងៃមុន លិខិតអនុញ្ញាតប្រកបអាជីវកម្មផុតសុពលភាពត្រូវទទួលពិន័យអន្តរការណ៍ចំនួន១០.០០០ (ដប់ពាន់)រៀល ក្នុង០១ថ្ងៃសម្រាប់រយៈពេល៣០ថ្ងៃដំបូង។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍ត្រូវគុណទ្វេដង។

**ប្រការ៤៣.-**

ការបង្កើតសាខាដោយគ្មានអាជ្ញាបណ្ណពីក្រសួងត្រូវទទួលពិន័យអន្តរការណ៍ចំនួន ៣.០០០.០០០ (បីលាន) រៀល ក្នុង០១សាខា និងត្រូវផ្អាកសកម្មភាពអាជីវកម្មសាខា។ ដើម្បីអាចបន្តសកម្មភាពអាជីវកម្មបាន ក្រុមហ៊ុន/សហគ្រាស ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណសាខានោះ។ ក្នុងករណីមិនរាងចាលក្រសួងនឹងព្យួរឬដកហូតអាជ្ញាបណ្ណក្រុមហ៊ុន/សហគ្រាសមេ។

ការបង្កើតសាខាដោយគ្មានលិខិតអនុញ្ញាតប្រកបអាជីវកម្មពីមន្ទីរត្រូវទទួលពិន័យអន្តរការណ៍ចំនួន ១.៥០០.០០០ (មួយលានប្រាំរយពាន់) រៀលក្នុង០១ សាខា និងត្រូវផ្អាកសកម្មភាពអាជីវកម្មសាខា។ ដើម្បីអាចបន្តសកម្មភាពអាជីវកម្មបាន ក្រុមហ៊ុន/សហគ្រាស ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសម្រាប់សាខានោះ។ ក្នុងករណីមិនរាងចាលមន្ទីរនឹងព្យួរ ឬដកហូតលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមហ៊ុន/ សហគ្រាសមេ។

**ប្រការ៤៤.-**

ការធ្វើអាជីវកម្មខុសពីកម្មវត្ថុនៃអាជ្ញាបណ្ណត្រូវទទួលពិន័យអន្តរការណ៍ចំនួន២.០០០.០០០ (ពីរលាន) រៀលក្នុង០១ករណី និងផ្អាកអាជីវកម្មនោះជាបន្ទាន់។ ក្នុងករណីមិនរាងចាលក្រសួងនឹងព្យួរ ឬដកហូតអាជ្ញាបណ្ណនោះ។

ការធ្វើអាជីវកម្មខុសពីកម្មវត្ថុនៃលិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវទទួលពិន័យអន្តរការណ៍ចំនួន១.០០០.០០០ (មួយលាន) រៀលក្នុង០១ ករណី និងផ្អាកអាជីវកម្មនោះជាបន្ទាន់។ ក្នុងករណីមិនរាងចាលមន្ទីរនឹងព្យួរ ឬដកហូតលិខិតអនុញ្ញាតប្រកបអាជីវកម្មនោះ។

**ប្រការ៤៥.-**

ក្រោយពីទទួលលិខិតព្រមានជាលាយលក្ខណ៍អក្សរ អ្នកកាន់អាជ្ញាបណ្ណនៅតែប្រព្រឹត្តផ្ទុយនឹងចំណុចណាមួយនៃប្រការ១៣ និងប្រការ១៤ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួងចំនួន៤០០.០០០ (បួនរយពាន់) រៀលក្នុង០១ ករណី។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការដកហូត ឬបញ្ឈប់សកម្មអាជីកម្ម។

ក្រោយពីទទួលលិខិតព្រមានជាលាយលក្ខណ៍អក្សរ ហើយអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មនៅតែប្រព្រឹត្តផ្ទុយនឹងចំណុចណាមួយនៃប្រការ១៣ និងប្រការ១៤ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ពីមន្ទីរចំនួន២០០.០០០ (ពីររយពាន់)រៀលក្នុង០១ ករណី។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការដកហូត ឬបញ្ឈប់សកម្មអាជីកម្ម។

**ប្រការ៤៦.-**

អ្នកកាន់អាជ្ញាបណ្ណទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងប្រការ១៥ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន ២.០០០.០០០(ពីរលាន) រៀលក្នុង០១ ករណី។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងប្រការ១៥ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន១.០០០.០០០ (មួយលាន) រៀលក្នុង០១ ករណី។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

**ប្រការ៤៧.-**

អ្នកកាន់អាជ្ញាបណ្ណទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងប្រការ២០ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន ១.០០០.០០០ (មួយលាន) រៀលក្នុង០១ ករណី និងត្រូវផ្អាកសកម្មភាពអាជីវកម្មជាបន្ទាន់ហើយត្រូវបំពេញឯកសារស្នើសុំ។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងប្រការ២០ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន៥០០.០០០ (ប្រាំរយពាន់) រៀលក្នុង០១ ករណី និងត្រូវផ្អាកសកម្មភាពអាជីវកម្មជាបន្ទាន់។ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

**ប្រការ៤៨.-**

អ្នកកាន់អាជ្ញាបណ្ណទាំងឡាយណាដែលផ្តល់របាយការណ៍យឺតយ៉ាវដូចមានចែងក្នុងប្រការ២៩ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន២០.០០០ (ម្ភៃពាន់) រៀលក្នុង០១ (មួយ) ថ្ងៃសម្រាប់រយៈពេល៣០ ថ្ងៃដំបូង។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការព្យួរ ឬដកហូតអាជ្ញាបណ្ណ។

អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មទាំងឡាយណាដែលផ្តល់របាយការណ៍យឺតយ៉ាវ ដូចមានចែងក្នុងប្រការ២៩ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន១០.០០០ (ដប់ពាន់) រៀល ក្នុង០១ (មួយ) ថ្ងៃសម្រាប់រយៈពេល៣០ ថ្ងៃដំបូង។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការព្យួរ ឬដកហូតលិខិតអនុញ្ញាតប្រកបអាជីវកម្ម។

## ជំពូកទី០៩
## អន្តរប្បញ្ញត្តិ

**ប្រការ៤៩.-**

អាជ្ញាបណ្ណទទួលបញ្ចាំ និង/ឬទទួលប្រាតិភោគដោយអនុប្បទានដែលក្រសួងផ្តល់ជូនមុនពេលដាក់ឱ្យអនុវត្តប្រកាសនេះនៅបន្តមានសុពលភាពរហូតដល់ផុតកាលកំណត់សុពលភាពរបស់អាជ្ញាបណ្ណនោះ។

## ជំពូកទី១០
## អវសានប្បញ្ញត្តិ

**ប្រការ៥០.-**

ប្រកាសលេខ០២៨សហវ.ប្រក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១០ ស្តីពីការផ្តល់អាជ្ញាបណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៥១.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្រុមហ៊ុន/សហគ្រាស និងបុគ្គលដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ តទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៦

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- ធនាគារជាតិនៃកម្ពុជា
- សាលារាជធានី-ខេត្ត
- ដូចប្រការ៥១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការក្រសួងយុត្តិធម៌**

លេខ: ១២៨ កយ.ប្រក/១១

រាជធានីភ្នំពេញ,ថ្ងៃទី២១ ខែ ៦ ឆ្នាំ ២០១១

# ប្រកាស

## ស្តីពី

## អត្រាការប្រាក់ដែលត្រូវបានកម្រិត

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើក្រមរដ្ឋប្បវេណី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី

**សម្រេច**

**ប្រការ ១.-**

អត្រាការប្រាក់ដែលត្រូវបានកម្រិតដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ១៧ (អត្រាការប្រាក់ដែលត្រូវបានកម្រិត ជាអាទិ៍) នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនឲ្យលើសពី ១៨% (ដប់ប្រាំបីភាគរយ) ក្នុង ១ (មួយ) ឆ្នាំ។

**ប្រការ ២.-**

អត្រាការប្រាក់ ដែលព្រមព្រៀងជាមុនក្នុងការសងសំណងក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាប្រាក់ ដែលបានកំណត់ក្នុងកថាខណ្ឌទី ៣ នៃមាត្រា ១៧ (អត្រាការប្រាក់ដែលត្រូវ

បានកម្រិត ជាអាទិ៍) នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនឲ្យលើសពីចំនួន ១,៥ (មួយក្បៀសប្រាំ) ដង នៃអត្រាការប្រាក់ដែលបានកំណត់ក្នុងប្រការ ១ ខាងលើ។

**ប្រការ ៣**.-

ប្រកាសនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

អង្គ_វង្សវឌ្ឍានៈ

**ចម្លងជូន ៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធ
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-តុលាការ និងមហាអយ្យការ -អយ្យការអមតុលាការគ្រប់ជាន់ថ្នាក់
-ឯកសារ-កាលប្បវត្តិ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចសន្យាខ្ចីប្រាក់-ដាក់បញ្ចាំ

រវាងខ្ញុំបាទ/នាងខ្ញុំឈ្មោះ…………..……អាយុ……..ឆ្នាំ កាន់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ លេខ……………………..មានទីលំនៅបច្ចុប្បន្នស្ថិតនៅ ផ្ទះលេខ………ផ្លូវ………ភូមិ……………….. ឃុំ/សង្កាត់…………………ស្រុក/ខណ្ឌ………..………រាជធានី/ខេត្ត…………………...………។ តទៅនេះហៅកាត់ថា ភាគី "ក" (ជាម្ចាស់ប្រាក់)

**និង**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ……………........……អាយុ……..ឆ្នាំ កាន់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ លេខ……………………..មានទីលំនៅបច្ចុប្បន្នស្ថិតនៅ ផ្ទះលេខ………ផ្លូវ………ភូមិ……………….. ឃុំ/សង្កាត់…………………ស្រុក/ខណ្ឌ………..………រាជធានី/ខេត្ត…………………...………។ តទៅនេះហៅកាត់ថា ភាគី "ខ" (ជាអ្នកខ្ចី)

**ភាគី "ក" និង ភាគី "ខ" បានព្រមព្រៀងគ្នាដូចខាងក្រោម៖**

**ប្រការ១៖** ភាគី "ក" យល់ព្រមឱ្យភាគី "ខ" ខ្ចីប្រាក់ចំនួន $………………..(…………………..ដុល្លារ) ដោយភាគី "ខ" យកចលនវត្ថុជា………………………ដែលជាកម្មសិទ្ធិរបស់ខ្លួនមកធានា។

**ប្រការ២៖** ភាគី "ខ" យល់ព្រមបង់ការប្រាក់ឱ្យភាគី "ក" ហើយភាគី "ក" យល់ព្រមទទួលការប្រាក់ពីភាគី "ខ" ក្នុងអត្រាការប្រាក់…………ភាគរយក្នុងមួយខែ ស្មើនឹង $……………(…………ដុល្លារ)។

**ប្រការ៣៖** ភាគី "ខ" យល់ព្រមបង់ការប្រាក់ឱ្យ ភាគី "ក" នៅថ្ងៃទី……….ដើមខែនីមួយៗ ។ ភាគី "ក" យល់ព្រមឱ្យភាគី "ខ" បង់សងនូវចំនួនទឹកប្រាក់ខ្ចីទាំងអស់ ឬមួយផ្នែកណាមួយនោះ នៃកិច្ចសន្យានៅពេលណាក៏បានក្នុងអំឡុងពេលអនុវត្តកិច្ចសន្យានេះ បើកាលណាភាគី "ខ" មានបំណងចង់ចេញសងរួមទាំងប្រាក់ដើម និងការប្រាក់ផង។ ក្នុងករណីភាគី "ខ" ពុំបានបង់ការប្រាក់ក្នុងរយៈពេល ០៣ខែជាប់ៗគ្នា នោះភាគី "ខ" យល់ព្រមឱ្យភាគី "ក" រំលាយកិច្ចសន្យានេះ និងទាមទារប្រាក់ដើម និងការប្រាក់ដែលនៅសល់។

**ប្រការ៤៖** យោងកិច្ចសន្យានេះ ដើម្បីធានាដល់ការអនុវត្តកាតព្វកិច្ច ភាគី "ខ" បានដាក់ចលនវត្ថុដើម្បីធានា មានដូចជា៖

១. រថយន្តម៉ាក………………ផ្លាកលេខ…………………..តួម៉ាស៊ីនលេខ…………………
មានប័ណ្ណសម្គាល់យានយន្តលេខ……………………………..ចុះថ្ងៃទី……ខែ……...……

ឆ្នាំ……………របស់មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី/ខេត្ត……………………។

២. ម៉ូតូម៉ាក……………………ផ្លាកលេខ…………………..ម៉ាស៊ីនលេខ…………………..

មានប័ណ្ណសម្គាល់យានយន្តលេខ………………………ចុះថ្ងៃទី……….ខែ……………...

ឆ្នាំ……………របស់មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី/ខេត្ត……………………។

**ប្រការ៥៖** កិច្ចសន្យានេះធ្វើឡើងជាភាសាខ្មែរចំនួន៣ ច្បាប់ មានតម្លៃស្មើៗគ្នា ដោយរក្សាទុកនៅគូភាគីម្នាក់១ ច្បាប់។

**ប្រការ៦៖** កិច្ចសន្យានេះធ្វើឡើងរវាងភាគ "ក" និងភាគី "ខ" ដោយគ្មានការបង្ខិតបង្ខំពីភាគីណាម្ខាង ឬតតិយជនឡើយ ហើយមានសុពលភាពនៅពេលចុះហត្ថលេខា និងស្នាមមេដៃជាភស្តុតាង។

…………………., ធ្វើនៅថ្ងៃទី……..ខែ…………ឆ្នាំ………

| | | | |
|---|---|---|---|
| ភាគី "ខ" | សាក្សីភាគី "ខ" | សាក្សីភាគី "ក" | ភាគី "ក" |
| ឈ្មោះ………… | ឈ្មោះ………….. | ឈ្មោះ……….. | ឈ្មោះ………….. |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចសន្យាប្រាតិភោគដោយអនុប្បទាន

រវាងខ្ញុំបាទ/នាងខ្ញុំឈ្មោះ………….……អាយុ……..ឆ្នាំ កាន់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ លេខ……………………..មានទីលំនៅបច្ចុប្បន្នស្ថិតនៅ ផ្ទះលេខ………ផ្លូវ………ភូមិ……………….. ឃុំ/សង្កាត់……………………ស្រុក/ខណ្ឌ………..……….រាជធានី/ខេត្ត…………………….……….។ តទៅនេះហៅកាត់ថា ភាគី "ក" (ជាម្ចាស់ប្រាក់)

**និង**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ……………..……….អាយុ……..ឆ្នាំ កាន់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ លេខ……………………..មានទីលំនៅបច្ចុប្បន្នស្ថិតនៅ ផ្ទះលេខ………ផ្លូវ………ភូមិ……………….. ឃុំ/សង្កាត់……………………ស្រុក/ខណ្ឌ………..……….រាជធានី/ខេត្ត…………………….……….។ តទៅនេះហៅកាត់ថា ភាគី "ខ" (ជាអ្នកខ្ចី)

**ភាគី "ក" និង ភាគី "ខ" បានព្រមព្រៀងគ្នាដូចខាងក្រោម៖**

**ប្រការ១៖** ភាគី "ក" យល់ព្រមឱ្យភាគី "ខ" ខ្ចីប្រាក់ចំនួន $……………..(…………………..ដុល្លារ) ដោយភាគី "ខ" យកចលនវត្ថុជា………………………ដែលជាកម្មសិទ្ធិរបស់ខ្លួនមកធានា។

**ប្រការ២៖** ភាគី "ខ" យល់ព្រមបង់ការប្រាក់ឱ្យភាគី "ក" ហើយភាគី "ក" យល់ព្រមទទួលការប្រាក់ពីភាគី "ខ" ក្នុងអត្រាការប្រាក់…………ភាគរយក្នុងមួយខែ ស្មើនឹង $……………(…………ដុល្លារ)។

**ប្រការ៣៖** ភាគី "ខ" យល់ព្រមបង់ការប្រាក់ឱ្យ ភាគី "ក" នៅថ្ងៃទី………..ដើមខែនីមួយៗ ។ ភាគី "ក" យល់ព្រមឱ្យភាគី "ខ" បង់សងនូវចំនួនទឹកប្រាក់ខ្ចីទាំងអស់ ឬមួយផ្នែកណាមួយនោះ នៃកិច្ចសន្យានៅពេលណាក៏បានក្នុងអំឡុងពេលអនុវត្តកិច្ចសន្យានេះ បើកាលណាភាគី "ខ" មានបំណងចង់ចេញសងរួមទាំងប្រាក់ដើម និងការប្រាក់ផង។ ក្នុងករណីភាគី "ខ" ពុំបានបង់ការប្រាក់ក្នុងរយៈពេល ០៣ខែជាប់ៗគ្នា នោះភាគី "ខ" យល់ព្រមឱ្យភាគី "ក" រំលាយកិច្ចសន្យានេះ និងទាមទារប្រាក់ដើម និងការប្រាក់ដែលនៅសល់។

**ប្រការ៤៖** យោងកិច្ចសន្យានេះ ដើម្បីធានាដល់ការអនុវត្តកាតព្វកិច្ច ភាគី "ខ" បានដាក់ចលនវត្ថុដើម្បីធានាមានដូចជា៖

១. រថយន្តម៉ាក………………ផ្លាកលេខ…………………..តួម៉ាស៊ីនលេខ…………………
មានប័ណ្ណសម្គាល់យានយន្តលេខ…………………………..ចុះថ្ងៃទី……ខែ……..……

ឆ្នាំ……………របស់មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី/ខេត្ត……………………។

២. ម៉ូតូម៉ាក……………………ផ្លាកលេខ…………………..ម៉ាស៊ីនលេខ…………………..

មានប័ណ្ណសម្គាល់យានយន្តលេខ………………………ចុះថ្ងៃទី……….ខែ……………...

ឆ្នាំ……………របស់មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី/ខេត្ត……………………។

**ប្រការ៥៖** កិច្ចសន្យានេះធ្វើឡើងជាភាសាខ្មែរចំនួន៣ ច្បាប់ មានតម្លៃស្មើៗគ្នា ដោយរក្សាទុកនៅគូភាគីម្នាក់១ ច្បាប់។

**ប្រការ៦៖** កិច្ចសន្យានេះធ្វើឡើងរវាងភាគ "ក" និងភាគី "ខ" ដោយគ្មានការបង្ខិតបង្ខំពីភាគីណាម្ខាង ឬតតិយជនឡើយ ហើយមានសុពលភាពនៅពេលចុះហត្ថលេខា និងស្នាមមេដៃជាភស្តុតាង។

…………………., ធ្វើនៅថ្ងៃទី……..ខែ…………..ឆ្នាំ………

| | | | |
|---|---|---|---|
| ភាគី "ខ" | សាក្សីភាគី "ខ" | សាក្សីភាគី "ក" | ភាគី "ក" |
| ឈ្មោះ………… | ឈ្មោះ………….. | ឈ្មោះ……….. | ឈ្មោះ…………. |

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀងប្រាតិភោគ

**ម្ចាស់សិទ្ធិប្រាតិភោគ៖** លោក............... អាយុ............ ជនជាតិ.......កាន់អត្តសញ្ញាណប័ណ្ណលេខ......................ចុះថ្ងៃទី........ខែ......ឆ្នាំ........ មានទីលំនៅស្ថិតនៅ ផ្ទះលេខ......ក្រុមទី........ភូមិ........ ឃុំ ........... សង្កាត់............ ខេត្ត/រាជធានី.................ជាម្ចាស់បំណុលហៅកាត់ថា ភាគី "ក" ទូរស័ព្ទលេខ: xxxxxxxx ។

**និង**

**អ្នកបង្កើតប្រាតិភោគ៖** លោក.................អាយុ............ ជនជាតិ.......កាន់អត្តសញ្ញាណប័ណ្ណលេខ......................ចុះថ្ងៃទី........ខែ......ឆ្នាំ........ មានទីលំនៅស្ថិតនៅ ផ្ទះលេខ......ក្រុមទី........ភូមិ........ ឃុំ ........... សង្កាត់............ ខេត្ត/រាជធានី.................ជាកូនបំណុលហៅកាត់ថា ភាគី "ខ" ទូរស័ព្ទលេខ: xxxxxxxxxx។

ភាគីទាំងពីរបានព្រមព្រៀងនិងឯកភាពគ្នាដោយសុឆន្ទៈអនុវត្តន៍តាមប្រការដូចខាងក្រោម៖

**ប្រការ១៖** ភាគី "ក" បានឲ្យភាគី "ខ" ខ្ចីប្រាក់ចំនួន........... ដុល្លាអាមេរិកគត់

**ប្រការ២៖** ភាគី "ខ" បានទទួលប្រាក់ចំនួន. ........... ដុល្លាអាមេរិកគត់ ពីភាគី "ក"នៅថ្ងៃទី......ខែ......ឆ្នាំ......... សម្រាប់រយៈពេល............ គិតចាប់ពីថ្ងៃចុះកិច្ចសន្យារហូត ដល់ថ្ងៃទី......ខែ..........ឆ្នាំ.......... នឹងត្រូវសងប្រាក់ជំពាក់ឲ្យមកភាគី "ក" វិញយ៉ាងយូរត្រឹមថ្ងៃទី...........ខែ..........ឆ្នាំ..........។

**ប្រការ៣៖** ថ្ងៃនេះ ភាគី "ខ" បានផ្ទេរកម្មសិទ្ធនៃទ្រព្យសម្បត្តិដែលបានរៀបរាប់ខាងក្រោម ( ការពណ៌នាពី"លក្ខណៈនៃទ្រព្យសម្បត្តិ") ទៅភាគី"ក" ក្នុងគោលបំណងជានាសិទ្ធិលើ


រក្សាសិទ្ធិគ្រប់បែបយ៉ាង ©

បំណុលរបស់ភាគី "ក" សម្រាប់ការទូទាត់សងប្រាក់ពីភាគី "ខ" ដែលបានខ្ចីដោយយោងលើមាត្រាទី 1 និងទី 2 នៃកិច្ចសន្យានេះ។

## ការពណ៌នាពីលក្ខណៈនៃទ្រព្យសម្បត្តិ

**ប្រការ៤៖** ថ្ងៃនេះ ភាគី"ខ" បានផ្ទេរការកាន់កាប់នៃទ្រព្យសម្បត្តិទៅភាគី "ក" ដោយការប្តូលក្ខណៈនៃការកាន់កាប់។

**ប្រការ៥៖** ភាគី "ក" យល់ព្រមនិងបានអនុញ្ញាតឲ្យភាគី "ខ" បន្តការកាន់កាប់និងប្រើប្រាស់ទ្រព្យសម្បត្តិនោះ ហើយភាគី "ខ" បានយល់ព្រម។

**ប្រការ៦៖** ភាគី"ខ"ត្រូវចាត់វិធានការសមស្របជូនដំណឹងជាសាធារណៈពីទ្រព្យសម្បត្តិដែលស្ថិតនៅក្រោមសិទ្ធិប្រាតិភោគដោយអនុប្បទានរបស់ភាគី "ក"។ ប្រសិនបើភាគី "ខ" មិនចាត់វិធានការណាមួយទេ នោះភាគី "ក" អាចចាត់វិធានកាជំនួសភាគី "ខ" ហើយនៅក្នុងករណីនេះ ភាគី "ក" អាចទាមទារសំណងនៃការចំណាយក្នុងការចាត់វិធានការនោះពី ភាគី"ខ" ។

**ប្រការ៧៖** ក្នុងអំឡុងពេលខ្ចីប្រាក់ ភាគី "ខ" បានយល់ព្រមបង់ការប្រាក់ ........... ស្មើ ....... % ក្នុងមួយខែនៅលើចំនួនទឹកប្រាក់សរុបទៅភាគី "ក" យ៉ាងយូរនៅថ្ងៃ ..... ... ..... .....

**ប្រការ៨៖** ភាគី"ខ" នឹងបាត់បង់ផលប្រយោជន៍នៃការកំណត់ពេលនៅក្នុងករណីដូចខាងក្រោមនេះ៖

(1) ភាគី"ខ" បានផ្ទេរកម្មសិទ្ធិនៃទ្រព្យសម្បត្តិនោះទៅតតិយជនមួយដោយគ្មានការយល់ព្រមពី ភាគី"ក" ។

(2) ភាគី"ខ" ដកយកចេញវិធានការនៃការជូនដំណឹងតាមមាត្រា 6 នៃកិច្ចសន្យានេះ។

**ប្រការ៨៖** ការកែប្រែណាមួយនៃកិច្ចសន្យាឬបន្ថែមខ្លឹមសារផ្សេងៗ អាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមនិងកិច្ចព្រមព្រៀងពីភាគីទាំងសងខាង។

រក្សាសិទ្ធិគ្រប់បែបយ៉ាង ©